**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**


## របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា

# នីតិវិធីនៃការធ្វើសវនកម្មសារពើពន្ធសហគ្រាស និងការតវ៉ាលើការកំណត់ពន្ធឡើងវិញរបស់ អគ្គនាយកដ្ឋានពន្ធដារ


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ហាន់ ខេង**

សាស្ត្រាចារ្យណែនាំ

លោកស្រីបណ្ឌិត **ព្រុំ ទេវី**


ថ្នាក់**បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច**

ឯកទេស**ហិរញ្ញវត្ថុ** ជំនាន់១៩ ជំហាន២

ឆ្នាំចូលសិក្សា ២០២២

ឆ្នាំសរសេររបាយការណ៍ ២០២៣

# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
# និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា

# នីតិវិធីនៃការធ្វើសវនកម្មសារពើពន្ធសហគ្រាស
# និងការតវ៉ាលើការកំណត់ពន្ធឡើងវិញរបស់
# អគ្គនាយកដ្ឋានពន្ធដារ


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ហាន់ ខេង**

សាស្ត្រាចារ្យណែនាំ

លោកស្រីបណ្ឌិត **ព្រុំ ទេវី**


ថ្នាក់**បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច**

ឯកទេស**ហិរញ្ញវត្ថុ** ជំនាន់១៩ ជំហាន២

ឆ្នាំចូលសិក្សា ២០២២

ឆ្នាំសរសេររបាយការណ៍ ២០២៣

# អារម្ភកថា

ប្រទេសកម្ពុជាស្ថិតនៅក្នុងដំណាក់កាលអភិវឌ្ឍន៍គួរឲ្យកត់សម្គាល់ដូចសព្វថ្ងៃ គឺដោយសារតែការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការកំណែទម្រង់គ្រប់វិស័យ តួយ៉ាង ដូចជាការកែទម្រង់វិស័យទូរគមនាគមន៍ វិស័យសុខាភិបាល វិស័យអប់រំ និងវិស័យផ្សេងៗទៀត។ ដោយឡែកអគ្គនាយកដ្ឋានពន្ធដារស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់ថវិកាលើការចំណាយរបស់រាជរដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍន៍លើគ្រប់វិស័យ។

ជាក់ស្តែងជារយៈពេល៥ឆ្នាំចុងក្រោយនេះអគ្គនាយកដ្ឋានពន្ធប្រមូលចំណូលបានគ្រប់ចំនួន និងលើសផែនការជារៀងរាល់ឆ្នាំ ចំណូលសារពើពន្ធប្រមូលដោយអគ្គនាយកដ្ឋានពន្ធ ដែលមានការកើនឡើងនេះ គឺកើតចេញពីការខិតខំប្រឹងប្រែងក្នុងកំណែទម្រង់ គោលនយោបាយសារពើពន្ធ លើកកំពស់វប្បធម៌នៃការបង់ពន្ធ កែលម្អប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន កែលម្អនូវអភិបាលកិច្ចសម្រាប់អ្នកជាប់ពន្ធ កែលម្អការផ្តល់សេវាជូនអ្នកជាប់ពន្ធ និងការចូលរួមបង់ពន្ធពីអ្នកជាប់ពន្ធ ជាពិសេសសហការចូលរួមយ៉ាងសកម្មពីប្រមុខរាជរដ្ឋាភិបាល សម្រាប់ការអភិវឌ្ឍន៍ប្រទេសជាតិ ដូចជាសាងសងមន្ទីរពេទ្យ សាងសង់ផ្លូវថ្នល់ ការពារព្រំដែន សាងសង់សាលារៀន សាងសង់ស្ពាន បើកប្រាក់ខែជូនទាហានកងកម្លាំងប្រដាប់អាវុធ និងបើកប្រាក់ខែជូនមន្ត្រីរាជការឲ្យទាន់ពេលវេលា។

ទន្ទឹមនឹងការរីកចម្រើនលើគ្រប់វិស័យ ជាពិសេសវិស័យសេដ្ឋកិច្ចទីផ្សារសេរីនៅប្រទេសកម្ពុជាដែលបានទាក់ទាញ វិនិយោគិន និងពាណិជ្ជករពីគ្រប់ទិសទីនោះ ការធ្វើសវនកម្មមានសារៈសំខាន់ណាស់លើ ការធ្វើសវនកម្មលើសហគ្រាស និងស្ថាប័ននានាដើម្បីឱ្យមានការកាន់កាប់បញ្ជីការគណនេយ្យ និង ការប្រកាសពន្ធជូនរដ្ឋបាលសារពើពន្ធឲ្យបានត្រឹមត្រូវច្បាស់លាស់ និងតម្លាភាព ស្របតាមបទបញ្ញត្តិពីពន្ធដារ។

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំឈ្មោះ ហាន់ ខេង ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច ឯកទេសហិរញ្ញវត្ថុ ជំនាន់ទី១៩ ជំហាន២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្តែងនូវសេចក្តីដឹងគុណ និងការគោរពយ៉ាងជ្រាលជ្រៅចំពោះ៖

ឯកឧត្តម សាកលវិទ្យាធិការសាកល វិទ្យាធិការរង នាយកសាលាក្រោយបរិញ្ញាបត្រ ព្រឹទ្ធបុរស លោកស្រីសាស្ត្រាចារ្យ និងមន្ត្រីរាជការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទាំងអស់ ពិសេស សាស្ត្រាចារ្យបណ្ឌិត ព្រុំ ទេវី ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ទាំងកម្លាំងកាយ កម្លាំងចិត្ត អប់រំ ណែនាំ និងផ្តល់ដំបូន្មានល្អៗ និងព្រមទាំងកែសម្រួលនូវចំណុចខ្វះខាតក្នុងការសិក្សា និងទទួលបានជោគជ័យ ។

ជាទីបញ្ចប់ខ្ញុំ សូមគោរព ឯកឧត្តមសាកលវិទ្យាធិការ វិទ្យាធិការរង លោកព្រឹទ្ធបុរស និងសាស្ត្រាចារ្យបណ្ឌិត ព្រុំ ទេវី សូមឱ្យមានសុខភាពល្អ រកទទួលទានមានបាន មានសុខសុភមង្គល ប្រកបការងារទទួលបានជោគជ័យគ្រប់ភារកិច្ច និងគ្រប់ពេលវេលា។

**សូមគោរពអរគុណ**!

# អំណះអំណាង

នាងខ្ញុំសូមធ្វើការអះអាងថារបាយការណ៍ស្រាជ្រាវ និងទទួលខុសត្រូវចំពោះខ្លឹមសារនៃរបាយការណ៍ស្រាវជ្រាវស្តីពី "នីតិវិធីនៃការធ្វើសវនកម្មសារពើពន្ធសហគ្រាស និងការតវ៉ាឡើងវិញលើការកំណត់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារកម្ពុជា "គឺរៀបរៀងដោយនាងខ្ញុំពិតជាប្រាកដមែន។

ម៉្យាងទៀត ចំពោះការរៀបចំចាត់ចែងចងក្រងរបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នេះមិនពាក់ព័ន្ធនេះមិនពាក់ពន្ធជាមួយរបាយការណ៍ ឬស្នាដៃរបស់អ្នកដទៃឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី ខែធ្នូ ឆ្នាំ២០២៣

ហត្ថលេខា

ហាន់ ខេង

# សង្ខេបសេចក្តី

សវនកម្មពន្ធដារគឺជាការត្រួតពិនិត្យលើបញ្ជីកាគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់អ្នកជាប់ពន្ធ ដើម្បីបញ្ជាក់ថាការគណនា ការប្រកាស និងការបង់ប្រាក់ពន្ធបាន ត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិពន្ធដារ។ ក្នុងនោះផងដែរ យើងសង្កេតឃើញថាការធ្វើសវកម្មពន្ធដារគឺធ្វើ ឡើងក្នុងគោលបំណងចម្បងគឺជម្រុញឲ្យមានការគោរពច្បាប់ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធដោយស្ម័គ្រចិត្ត និង ដើម្បីធានាថាការអនុវត្តន៍កាតព្វកិច្ចពន្ធដារក្រោមរបបស្វ័យប្រកាសបានទទួលកម្រិតអនុលោមភាពខ្ពស់។ យោងតាមច្បាប់ស្តីពីសារពើពន្ធ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធបានធ្វើការបែងចែកសវនកម្ម ពន្ធដារជា៣ប្រភេទគឺ៖ សវនកម្មលើលិខិតស្នាម សវនកម្មមានកម្រិតនិងសវនកម្មពេញលេញ។

សវនកម្មលើលិខិតស្នាមគឺជាការពិនិត្យវិនិច្ឆ័យលើលិខិតប្រកាសសារពើពន្ធប្រចាំខែ ឬប្រចាំឆ្នាំ ដែល មានភាពមិនត្រឹមត្រូវ ភាពមិនប្រក្រតី និងភាពមិនស៊ីសង្វាក់គ្នានៃលិខិតប្រកាសសារពើពន្ធប្រចាំខែ។ទូទៅសវន កម្មនេះ ត្រូវផ្តោតសំខាន់ទៅលើតែបញ្ហាជាក់លាក់ និងងាយស្រួលដោះស្រាយក្នុងទិនានុប្បវត្តិទិញ លក់ ព្រម ទាំងចំណុចមិនប្រក្រតីទាំងឡាយ ដែលរកឃើញនៅលើលិខិតប្រកាសសារពើពន្ធ និងព័ត៌មានដែលរដ្ឋបាល សារពើពន្ធទទួលបានពីប្រភពផ្សេងៗ ដូចជាអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាជាដើម។

សវនកម្មមានកម្រិត គឺជាប្រភេទសវនកម្មដែលវិសាលភាពរបស់វាមានកម្រិត និងត្រូវធ្វើនៅទីកន្លែង អាជីវកម្មរបស់សហគ្រាស។ សវនកម្មនេះរួមមាន សវនកម្មអាករលើតម្លៃបន្ថែម សវនកម្មលើការបង្វិលសង សវនកម្មជាគម្រោង និងសវនកម្មតាមប្រភេទពន្ធ និងអាករផ្សេងៗក្នុងលិខិតប្រកាសប្រចាំខែ និងសវនកម្មជា គម្រោងចំណាយជាក់លាក់ណាមួយ ឬលើធាតុណាមួយក្នុងតារាងតុល្យការ ឬក្នុងរបាយការណ៍លទ្ធផល។

សវនកម្មពេញលេញគឺជាសវនកម្មរួមលើ ពន្ធប្រាក់ចំណេញ អាករលើតម្លៃបន្ថែមអាករពិសេស និង ប្រភេទពន្ធអាករផ្សេងទៀតក្នុងឆ្នាំសារពើពន្ធនីមួយៗ ដែលអ្នកជាប់ពន្ធមានកាតព្វកិច្ចត្រូវបង់តាមបទប្បញ្ញត្តិស្តី ពីពន្ធដារ។ សវនកម្មពេញលេញតម្រូវឲ្យធ្វើសវនកម្មនៅទីកន្លែងរបស់សហគ្រាសលើគ្រប់ប្រភេទពន្ធអាករទាំង អស់ ដែលរួមមានការត្រួតពិនិត្យលើបញ្ជីកាគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ ឯកសារផ្សេងៗដែល ពាក់ព័ន្ធ និងអាជីវកម្មដើម្បីធានាថាសហគ្រាសបានរៀបចំរបាយការណ៍គណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ បានត្រឹម ត្រូវតាមច្បាប់ជាធរមាន និងបានបំពេញកាតព្វកិច្ចបង់ពន្ធត្រឹមត្រូវតាមច្បាប់ស្តីពីសារពើពន្ធ។

ការសិក្សានេះផ្តោតទៅលើការជ្រើសរើសសហគ្រាស សម្រាប់ធ្វើសវនកម្មដោយធ្វើឡើងដោយផ្អែកលើ ការវិភាគហានិភ័យ និងព័ត៌មានផ្សេងៗរួមមាន (១) ការវិភាគហានិភ័យ (២) ព័ត៌មានទទួលបានពីតតិយជន (៣) វិស័យជាក់លាក់(៤)បញ្ហាជាក់លាក់ចំពោះប្រភេទពន្ធ ឬអ្នកជាប់ពន្ធណាមួយ (៥) ទីតាំងរបស់សហគ្រាស

ជាដើម។ ចំពោះដំណើរការនៃការធ្វើសវនកម្មពន្ធដារគឺ (១) ការជូនដំណឹងស្តីពីការធ្វើសវនកម្មពន្ធដារ (២) ការស្នើសុំពន្យាពេលចុះធ្វើសវនកម្ម (បើមាន)(៣) ការផ្តល់ឯកសារ (៤) ការធ្វើបទសម្ភាសន៍ (៥)ការត្រួតពិនិត្យឯកសារ (៦) ការពន្យល់ការធ្វេសប្រហែសរកឃើញ(៧) ការជូនលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធ និងការកំណត់ពន្ធឡើងវិញ (៨)ការតវ៉ាចំពោះការកំណត់ពន្ធ និងការកំណត់ពន្ធឡើងវិញ (៩) ការបង់ប្រាក់ពន្ធ។

ក្នុងករណីអ្នកជាប់ពន្ធដែលមិនពេញចិត្តនឹងការកំណត់ពន្ធ ឬការកំណត់ពន្ធឡើងវិញ ដែលធ្វើឡើងដោយសារពើពន្ធ អាចតវ៉ាទៅអគ្គនាយកដ្ឋានពន្ធដារ។ ការតវ៉ាត្រូវមានកម្រិតព្រំដែនតែត្រឹមដើមហេតុ ឬព័ត៌មានផ្សេងទៀត ដែលមាននៅក្នុងការកំណត់ពន្ធ ឬការកំណត់ពន្ធឡើងវិញប៉ុណ្ណោះ។ មាត្រា ១២១នៃច្បាប់ស្តីពីសារពើពន្ធ ក្នុងការតវ៉ាអ្នកជាប់ពន្ធត្រូវដាក់ពាក្យតវ៉ា ដែលមានខ្លឹមសារជាអាទិ៍ (១) ឈ្មោះ និងលេខអត្តសញ្ញាណកម្មរបស់សហគ្រាស (២) សេចក្តីយោងទៅរកការកំណត់សេចក្តីសម្រេច ឬលទ្ធផលដែលជាកម្មវត្ថុនៃពាក្យតវ៉ា (៣)ដើមហេតុ ឬជាកម្មវត្ថុនៃពាក្យតវ៉ា(៤) ហេតុផលនៃការតវ៉ា (៥) កាលបរិច្ឆេទ និងហត្ថលេខារបស់អ្នកជាប់ពន្ធឬ និងហត្ថលេខារបស់តំណាងដែលមានការអនុញ្ញាត របស់អ្នកជាប់ពន្ធ។

រដ្ឋបាលសារពើពន្ធនឹងចេញសេចក្តីសម្រេចសារជាថ្មីក្នុងរយៈពេល៦០ថ្ងៃ ក្រោយពីថ្ងៃទទួលពាក្យតវ៉ាដើម្បីបញ្ជាក់ភាពត្រឹមត្រូវ ឬចំណែកណាមួយនៃការកំណត់ពន្ធ ឬការកំណត់ពន្ធឡើងវិញដែលអ្នកជាប់ពន្ធតវ៉ា។ ប្រសិនបើអ្នកជាប់ពន្ធមិនយល់ព្រមលើសេចក្តីសម្រេចថ្មីនេះទេ អ្នកជាប់ពន្ធអាចដាក់ពាក្យទៅគណៈកម្មាធិការសម្រុះសម្រួលសារពើពន្ធក្នុងរយៈពេលយ៉ាងយូរចំនួន៣០ថ្ងៃ។ អ្នកជាប់ពន្ធនៅតែមានសិទ្ធិ ក្នុងការបដិសេធលើការសម្រេចរបស់គណៈកម្មាធិការសម្រុះសម្រួលសារពើពន្ធនេះ ដោយធ្វើការប្តឹងទៅតុលាការដែលមានសមត្ថកិច្ចក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីទទួលបាន សេចក្តីសម្រេច ពីគណៈកម្មាធិការនេះ។ យ៉ាងណាក៏ដោយដើម្បីឲ្យបណ្តឹងនោះមានសុពលភាព អ្នកជាប់ពន្ធត្រូវតម្កល់ទុក នៅរតនាគារជាតិនូវប្រាក់ចំនួនស្មើនឹងប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ ផ្សេងៗដែលទាក់ទិននឹងវិវាទ តាមការកំណត់របស់រដ្ឋបាលសារពើពន្ធមុននឹងដាក់ពាក្យបណ្តឹងនេះទៅកាន់តុលាការ។ យោងតាមមាត្រា៩១កថាខណ្ឌទី២នៃច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធត្រូវបង់ប្រាក់ពន្ធ ពន្ធបន្ថែមនិងការប្រាក់ផ្សេងៗក្នុងរយៈពេល៣០ថ្ងៃក្រោយទទួលបានលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធ ឬការកំណត់ ពន្ធឡើងវិញ។

# មាតិកា


បញ្ជីអក្សរកាត់.......... ix

បញ្ជីតារាង.......... x

បញ្ជីរូបភាព.......... xi

បញ្ជីឧបសម្ព័ន្ធ.......... xii

សេចក្តីផ្តើម.......... 1

១.លំនាំនៃការស្រាវជ្រាវ.......... 1

២.ចំណោទបញ្ហានៃការស្រាវជ្រាវ.......... 3

៣.គោលបំណង និងសារៈសំខាន់នៃការស្រាវជ្រាវ.......... 3

៤.សំណួរនៃការស្រាវជ្រាវ.......... 4

៥.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ.......... 4

៥.១.ទំហំនៃការស្រាវជ្រាវ.......... 4

៥.២.ដែនកំណត់នៃការស្រាវជ្រាវ.......... 4

៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.......... 5

៧. វិធីសាស្ត្រប្រមូលទិន្នន័យ.......... 5

ជំពូកទី១៖ រំលឹកទ្រឹស្តី.......... 6

១.១.និយមន័យ.......... 6

១.១.១.សវនកម្ម.......... 6

១.១.២.ប្រភេទសវនកម្មពន្ធដារ.......... 6

១.១.៣.ទស្សនទានផ្សេងៗពាក់ព័ន្ធនឹងសវនកម្មពន្ធដារ.......... 7

១.២. ទ្រឹស្តីពាក់ព័ន្ធផ្សេងៗ.......... 7

១.២.១.ពន្ធ.......... 7

១.២.២.ពន្ធ និងអាករគ្រប់ប្រភេទ.......... 8

១.២.៣.របបកំណត់ពន្ធ.......... 15

១.២.៤.ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមស្វ័យប្រកាស.......... 15

១.២.៥.សិទ្ធិនិងកាតព្វកិច្ចអ្នកជាប់ពន្ធ.......... 15

១.២.៥.១.សិទ្ធិអ្នកជាប់ពន្ធ.......... 15

១.២.៥.២.កាតព្វកិច្ចអ្នកជាប់ពន្ធ ..... 15
ជំពូកទី២៖ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ ..... 17
២.១. ទិដ្ឋភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ ..... 17
២.១.១.ប្រវត្តិរបស់អគ្គនាយដ្ឋានពន្ធដារ ..... 17
២.១.២.ប្រវត្តិនៃការកកើតការិយាល័យ ..... 20
២.១.៣.ចក្ខុវិស័យនិងបេសកកម្មរបស់អគ្គនាយដ្ឋានពន្ធដារ ..... 20
២.១.៣.១.ចក្ខុវិស័យរបស់អគ្គនាយដ្ឋានពន្ធដារ ..... 20
២.១.៣.២.បេសកកម្មរបស់អគ្គនាយដ្ឋានពន្ធដារ ..... 20
២.២.ទីតាំង និងនិមិត្តសញ្ញា ..... 21
២.២.១.ទីតាំង ..... 21
២.២.២.និមិត្តសញ្ញា ..... 21
២.៣.ភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ ..... 21
២.៤.តួនាទីនិងភារកិច្ចរបស់ការិយាល័យសវនកម្មពន្ធដារសហគ្រាស ..... 22
២.៥.ការបែងចែករចនាសម្ព័ន្ធ ..... 23
២.៦.លទ្ធផលការងារសម្រេចបាន ..... 25
ជំពូកទី៣៖ នីតិវិធីនៃការធ្វើសវនកម្មនិងការវិភាគលទ្ធផលរបស់អគ្គនាយដ្ឋានពន្ធដារ ..... 27
៣.១.នីតិវិធីនៃការធ្វើសវនកម្មរបស់អគ្គនាយដ្ឋានពន្ធដារ ..... 27
៣.២.ការជ្រើសរើសសហគ្រាសធ្វើសវនកម្ម ..... 27
៣.៣.ដំណើរការនៃការធ្វើសវនកម្ម ..... 27
៣.៣.១.ការជូនដំណឹងស្តីពីការធ្វើសវនកម្ម ..... 28
៣.៣.២.ការផ្តល់ឯកសារ ..... 29
៣.៣.៣.ការផ្តល់បទសម្ភាសន៍ ..... 29
៣.៣.៤.ការត្រួតពិនិត្យឯកសារ ..... 30
៣.៣.៥.ការពន្យល់ពីលទ្ធផលធ្វើសវនកម្ម ..... 30
៣.៣.៦.នីតិវិធីនៃការកំណត់ពន្ធឡើងវិញ ..... 30
៣.៣.៧.លិខិតជូនដំណឹងនៃការកំណត់ពន្ធឡើងវិញ ..... 32
៣.៣.៨.ការតវ៉ាចំពោះការកំណត់ពន្ធឡើងវិញ ..... 32

៣.៣.៩.ពន្ធបន្ថែមនិងការប្រាក់ ..... 32
៣.៣.១០.ការបង់ការប្រាក់ ..... 33
៣.៣.១១.ការទូទាត់បំណុលពន្ធ ..... 33
៤.១.ចំណុចខ្លាំងនៃការធ្វើសវនកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ ..... 34
៤.២.ចំណុចខ្សោយនៃការអនុវត្តន៍សវនកម្ម ..... 34
សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ ..... 36
១.សេចក្តីសន្និដ្ឋាន ..... 36
២.ការផ្តល់អនុសាសន៍ ..... 36
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| អក្សរកាត់ | អក្សរពេញ |
|---|---|
| កហវ | ក្រសួងហិរញ្ញវត្ថុ |
| ក្រ.ច | ក្រឹត្យច្បាប់ |
| ចសព | ច្បាប់សារពើពន្ធ |
| ប្រក | ប្រកាស |
| ពបច | ពន្ធលើប្រាក់ចំណូល |
| សហវ.ប្រក | ប្រកាសក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| សរច | សេចក្តីសម្រេច |
| អនក្រ.បក | អនុក្រឹតស្តីពីការបង្កើត |
| អនក្រ | អនុក្រឹត |

ប្រភពះអគ្គនាយដ្ឋានពន្ធដារ

# បញ្ជីតារាង

ចំណងជើង ទំព័រ


១. តារាងទី១៖ តារាងអត្រាពន្ធប្រាក់ចំណូលប្រចាំឆ្នាំកំណើនតាមថ្នាក់................................................8

២. តារាងទី២៖ តារាងភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ.............................................................10

៣. តារាងទី៣៖ របាយការណ៍ប្រៀបធៀបការទទួលពាក្យបណ្ដឹងតវ៉ា រវាងឆ្នាំ២០២១ និងឆ្នាំ២០២២........26

# បញ្ជីរូបភាព

ចំណងជើង ទំព័រ

១. រូបភាពទី១៖ទីស្នាក់ការអគ្គនាយកដ្ឋានពន្ធដារ.......................................................................... 21

២. រូបភាពទី២៖និមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារ..........................................................................21

៣. រូបភាពទី៣៖អង្គការលេខរបស់អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ.......................23

# បញ្ជីឧបសម្ព័ន្ធ

១. ប្រកាសស្តីពីសវនកម្មពន្ធដារ លេខ២៧០ សហវ.ប្រក

២. ប្រកាសស្តីពីការគ្រប់គ្រងបំណុលពន្ធដារ លេខ៩៦២ សហវ.ប្រក

៣. អនុក្រឹតស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធលេខ០៣ អនក្រ.បក

# សេចក្តីផ្តើម

## ១. លំនាំនៃការស្រាវជ្រាវ

ក្រោយពេលដែលស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ចព្រមទាំងជីវភាពរបស់ប្រជាជនមានលំនឹងជាបង្គួរ ហើយក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ បានសម្រេចបង្កើតនាយកដ្ឋានពន្ធដារ តាមសេចក្តីសម្រេចលេខ៤១សរ ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ១៩៦១ ដែលមានឈ្មោះដើមថា "នាយកដ្ឋានពន្ធដារ" ឧស្សាហពាណិជ្ជ ស្ថិតនៅក្រោមចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតាមខេត្ត ក្រុងចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងតាមខេត្ត ក្រុង ហៅថា "សាខាពន្ធដារឧស្សាហពាណិជ្ជខេត្ត ក្រុង" ចំណុះមន្ទីរហិរញ្ញវត្ថុ និងធនាគារខេត្ត-ក្រុង។ ចាប់ពីឆ្នាំ ១៩៩១ មកនាយកដ្ឋានពន្ធដារឧស្សាហពាណិជ្ជ និងការិយាល័យពន្ធដារឧស្សាហពាណិជ្ជខេត្ត-ក្រុងត្រូវបានប្តូរឈ្មោះជានាយកដ្ឋានពន្ធដារ និងជាសាខាពន្ធដារខេត្ត-ក្រុ ផ្អែកតាមអនុក្រឹត្យលេខ២៤ អនក្រ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩០ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី និងសារាចរណ៍ណែនាំអនុវត្តន៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ០៥៧ សហវចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៩១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បច្ចុប្បន្នគ្រប់ខេត្ត-ក្រុងទាំងអស់ត្រូវបានបង្កើតជាសាខាពន្ធដារចំនួន ២៣សាខា និងស្រុក-ខណ្ឌបង្កើតបានជាទីស្នាក់ការពន្ធដារ១៣៦ស្នាក់ការ។ ដើម្បីឱ្យរដ្ឋមានចំណូលផ្គត់ផ្គង់រដ្ឋបាលរបស់ខ្លួន បានការប្រមូលពន្ធត្រូវបានបង្កើតឡើង ហើយនៅប្រទេសកម្ពុជា របបពន្ធមានពីរប្រភេទគឺ របបពិត និងម៉ៅការ។ របបទាំងនេះធ្វើសវនកម្មលើបញ្ជីគណនេយ្យពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណេញទាំងអស់។ របបពិតកំណត់ប្រាក់ពន្ធត្រូវបង់ដោយខ្លួនឯងពីស្ថានភាពពិតនៃអាជីវកម្មរបស់ខ្លួនផ្ទាល់ និងកំណត់ប្រាក់ពន្ធដែលត្រូវបង់ដោយខ្លួនឯងពីស្ថានភាពពិតបន្ទាប់មកសវនករពន្ធដារធ្វើការត្រួតពិនិត្យជាក្រោយដោយផ្អែកលើបញ្ជីគណនេយ្យ និងស្ថានភាពអាជីវកម្មពិតរបស់អ្នកជាប់ពន្ធនោះ។

ដោយស្ថានភាពជីវភាពរបស់ប្រជាជនមានភាពល្អប្រសើរ ទន្ទឹមនឹងការរីកចម្រើនផ្នែកសេដ្ឋកិច្ចទីផ្សារសេរីនៅប្រទេសកម្ពុជាបានទាក់ទាញ វិនិយោគគិន និងពាណិជ្ជករពីគ្រប់ទិសទីនោះ អគ្គនាយកដ្ឋានពន្ធដារដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រមូលពន្ធ ហើយរបបពន្ធនៅកម្ពុជាបានធ្វើបច្ចុប្បន្នភាពជាថ្មីឡើងវិញគឺ ស្វ័យប្រកាស ចំពោះរបបស្វ័យប្រកាសត្រូវបានបែងចែកជាបីប្រភេទមានដូចជា អ្នកជាប់ពន្ធតូច អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ ហើយការការប្រមូលពន្ធតាមរបបស្វ័យប្រកាស គឺតម្រូវឱ្យអ្នកជាប់ពន្ធធ្វើការប្រកាសចំណូលពន្ធ និងចំណាយអាជីវកម្មរបស់អ្នកជាប់ពន្ធដោយខ្លួនឯង បន្ទាប់មកក្រុមសវនករនៃអគ្គនាយកដ្ឋានពន្ធដារដូចរបបពិត ដើម្បីបង្ហាញថារាល់ការប្រកាសចំណូលរបស់អ្នកជាប់ពន្ធអនុវត្តត្រឹមត្រូវតាមច្បាប់ និងបទបញ្ញត្តិនានាស្តីពីពន្ធដារ និងការបង់ប្រាក់ពន្ធគ្រប់

គ្រាន់ចូលថវិកាជាតិ។ ដោយសារតែការប្រឹងប្រែងក្នុងការកំណែទម្រង់គ្រប់វិស័យ ជាពិសេសការកែទម្រង់នៅក្នុងវិស័យពន្ធដារបានធ្វើឲ្យវិស័យពន្ធបានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ តួយ៉ាងការគ្រប់គ្រងការប្រមូលពន្ធសម្រាប់ត្រីមាសទី៣ ខែកញ្ញា ឆ្នាំ២០២០ ដោយសម្រេចបាននូវជោគជ័យ គួរជាទីមោទនៈជាលទ្ធផល សម្រាប់ខែកញ្ញានេះ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានបង្ហាញថាលទ្ធផលប្រមូលចំណូលពន្ធរបស់អគ្គនាយកដ្ឋានទទួលបានពន្ធ-អាករគ្រប់ប្រភេទ ដែលប្រមូលបាន (តាមប្រព័ន្ធគ្រប់គ្រង់ទិន្នន័យចំណូល Online របស់អគ្គនាយកដ្ឋានពន្ធដារ) មានចំនួន ៧៥៤,២០ ប៊ីលានរៀល ( ប្រមាណជា ១៨៦,២២ លានដុល្លាអាមេរិក) ស្មើនឹង ៦,៥៣% នៃផែនការប្រចាំឆ្នាំ។ ប្រសិនបើប្រៀបធៀបទៅនឹងចំណូលពន្ធ-អាករប្រចាំ ខែកញ្ញា ឆ្នាំ២០១៩ (តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូល Online) ឃើញថា ការប្រមូលចំណូលពន្ធ-អាករ គ្រប់ប្រភេទក្នុងខែកញ្ញា ឆ្នាំ២០១៩ មានការថយចុះចំនួន ១៧៤,០៥ ប៊ីលាន (ប្រមាណ ៤២,៩៨ លានដុល្លអាមេរិក) ស្មើនឹង ១៨,៧៥% ។

សរុបក្នុងរយៈពេល៩ខែ ឆ្នាំ២០២០ ចំណូលពន្ធ-អាករ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន (តាមប្រព័ន្ធគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនិងត្រូវមានភាពទន់ភ្លន់តែម៉ឺងម៉ាត់។ទិន្នន័យចំណូលអនឡាញ Online របស់អគ្គនាយកដ្ឋានពន្ធដារ)មានចំនួន៩ ០១៥,០៨ ប៊ីលានរៀល(ប្រមាណ ២ ២២៥,៩៥លានដុល្លារអាមេរិក) ស្មើនឹង៧៨,១០% នៃផែនការប្រចាំឆ្នាំ។ ប្រសិនបើប្រៀបធៀបនឹងរយៈពេលដូចគ្នា នៃឆ្នាំ២០១៩ ឃើញថា ចំណូលពន្ធ-អាករសម្រាប់ត្រីមាសទី៣ ឆ្នាំ២០២០ កើនឡើងចំនួន ៣២៥,២៧ ប៊ីលានរៀល (ប្រមាណជា ៨០,៣១ លានដុល្លារអាមេរិក) ស្មើនឹង ៣,៧១%។ អគ្គនាយកដ្ឋានពន្ធដាររំពឹងថាចំណូលពន្ធ-អាករគ្រប់ប្រភេទសម្រាប់ឆ្នាំ២០២០ អាចប្រមូលគ្រប់ផែនការដែលកំណត់ដោយច្បាប់។

ក្នុងទិសដៅបង្កើតប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូលសារពើរពន្ធក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកំណត់ឱ្យនាយកដ្ឋានពន្ធដារបង្កើតសកម្មភាព ក្នុងការធ្វើសវនកម្មដោយរៀបចំកម្មវិធីប្រចាំឆ្នាំទាំងសវនកម្មលើលិខិតស្នាម និងសវនកម្មទូទៅដល់ទីកន្លែងសហគ្រាស ដែលបដិភាគនៃការស្វ័យប្រកាសដើម្បីប្រមូលពន្ធឱ្យអស់និងគ្រប់ចំនួនប្រាក់ពន្ធឱ្យបានត្រឹមត្រូវ និងកំណត់ពន្ធឡើងវិញព្រមទាំងអនុវត្តទោសទណ្ឌចំពោះការប្រកាសបង់ពន្ធមិនត្រឹមត្រូវ និងកំណត់ពន្ធអំពើរាំងស្ទះការអនុវត្តបទបញ្ញត្តិស្តីពីពន្ធដារ និងបិទចន្លោះប្រហោងដែលបង្កលក្ខណៈដល់ការបាត់បង់ពន្ធ។

ការងារសវនកម្មគឺជាការងារមានសារៈសំខាន់ណាស់ សម្រាប់អគ្គនាយកដ្ឋាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរាជរដ្ឋាភិបាលកម្ពុជា ពីព្រោះកិច្ចការសវនកម្មត្រូវផ្តោតទៅលើភាពមិនប្រក្រតីដែលលេចធ្លោ និងធ្វើឱ្យសវនកម្មពន្ធដារសន្និដ្ឋានបានយ៉ាងប្រាកដពីការបន្លំពន្ធ។

កិច្ចការសវនកម្មបានកាត់បន្ថយ និងរកឃើញចំណោញវិញបានព្រមទាំងការកំណត់ពន្ធឡើងវិញក្រោយធ្វើសវនកម្ម។សវនកម្មបានរួមចំណែកបង្កើតចំណូលពន្ធចូលក្នុងថវិកាជាតិ សម្រាប់ធានាដល់ការកើនឡើងនូវ

ចំណាយថវិកាក្នុងការកសាងប្រទេសឱ្យមានការអភិវឌ្ឍន៍យ៉ាងឆាប់រហ័ស និងដើម្បីឆ្លើយបតទៅនឹងដំណើរការធ្វើសមាហរណកម្មរបស់កម្ពុជាចូលអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក។

ដោយឈរលើមូលដ្ឋានខាងលើនេះហើយ ទើបខ្ញុំបានសម្រេចចិត្តជ្រើសរើសយកប្រធានបទស្តីពីៈ " នីតិវិធីនៃការធ្វើសវនកម្មសារពើពន្ធសហគ្រាស និងការតវ៉ាលើការកំណត់ពន្ធឡើងវិញរបស់អគ្គនាយកដ្ឋានពន្ធដារ " មកសិក្សាស្រាវជ្រាវក្នុងក្របខណ្ឌនៃរបាយការណ៍ស្រាវជ្រាវថ្នាក់អនុបណ្ឌិតនេះ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយការអនុវត្តរបបស្វ័យប្រកាសនាំអោយមានការគេចវេសពន្ធ ការបន្លំពន្ធ ការមិនព្រមបង់ពន្ធចូលថវិការដ្ឋពីអ្នកជាប់ពន្ធ ដោយសារតែការប្រកាសពន្ធគឺស្ថិតទៅលើអ្នកជាប់ពន្ធ ហេតុដូច្នេះហើយទើបអគ្គនាយកដ្ឋានបានដាក់ចេញនូវកម្មវិធីសវនកម្មចំពោះក្រុមហ៊ុនណាដែលមានហានិភ័យខ្ពស់ ។ ដើម្បីសម្រេចបាននូវផែនការថវិកាជាតិ អគ្គនាយកដ្ឋានពន្ធដារបានធ្វើកំណែទម្រង់យុទ្ធសាស្ត្រជាច្រើនដែលសមស្របតាមសម័យនគររូបនីយកម្ម ដើម្បីផ្តល់សេវាដល់អ្នកជាប់ពន្ធអោយកាន់តែមានប្រសិទ្ធភាពដូចជា ការផ្តល់ព័ត៌មាន អប់រំពន្យល់ណែនាំ ដើម្បីឱ្យអ្នកជាប់ពន្ធប្រតិបត្តិ និងការអនុវត្តត្រឹមត្រូវតាមច្បាប់ និងបទបញ្ញត្តិនានាស្តីពីពន្ធដារដល់អ្នកជាប់ពន្ធកាន់តែយល់ច្បាស់ ចៀសវាសពីកាតព្វកិច្ចសារពើពន្ធដែលនាំអោយមានការបាត់បង់ចំណូលពន្ធហេតុនេះហើយការធ្វើសវនកម្ម គឺជាចំណុចសំខាន់មួយដែលធ្វើអោយសេដ្ឋកិច្ចជាតិរីកចំរើន។

## ៣. គោលបំណង និងសារៈសំខាន់នៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវលើរបាយការណ៍ស្រាវជ្រាវនេះ គឺដើម្បីឆ្លុះបញ្ចាំងពីការពិនិត្យបញ្ជាក់បញ្ជីគណនេយ្យរបស់សហគ្រាសដែលបានប្រកាសបង់ពន្ធនៅពន្ធដារ ជាពិសេសពន្ធលើប្រាក់ចំណូល។ ការសិក្សានេះផ្តោតសំខាន់ទៅលើៈ

១. ការធ្វើអោយប្រសើរឡើងនូវនីតិវិធីនៃការធ្វើសវនកម្មរបស់អគ្គនាយដ្ឋានពន្ធដារ ។

២. ដើម្បីធានានូវតម្លាភាពក្នុងការបង់ពន្ធ និងការបង្កើនបរិយាកាសប្រកួតប្រជែងដោយស្មើភាពក្នុងការប្រកបអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា។

រីឯសារៈសំខាន់នៃការសិក្សានេះគឺៈ

- ដើម្បីយល់ដឹងនូវផ្នែកនៃបញ្ហាក្នុងការធ្វើសវនកម្មរបស់អគ្គនាយដ្ឋានពន្ធដារ
- ដើម្បីបង្កើនការយល់ដឹងពីការងារសវនកម្មរបស់អគ្គនាយដ្ឋានពន្ធដារនិងគណនេយ្យ
- កាតព្វកិច្ចរបស់សហគ្រាសក្នុងការកាន់កាប់បញ្ជីការគណនេយ្យត្រឹមត្រូវ

- លក្ខណៈ និងមធ្យោបាយការអនុវត្តជាក់ស្តែងរវាងការត្រួតពិនិត្យពន្ធលើប្រាក់ចំណូលតាមរបបស្វ័យប្រកាស
- សិក្សាទ្រឹស្តីប្រៀបធៀបការអនុវត្តជាក់ស្តែងរវាងការត្រួតពិនិត្យបញ្ជីគណនេយ្យនិងត្រួតពិនិត្យសារពើពន្ធ។
- ធ្វើសេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍។

## ៤. សំណួរស្រាវជ្រាវ

ដោយផ្អែកលើគោលបំណងខាងលើ យើងអាចចោទជាសំណួរមួយចំនួនដូចខាងក្រោម៖

១.តើអគ្គនាយកដ្ឋានពន្ធដារមានភារកិច្ចក្នុងការធ្វើសវនកម្មនេះត្រូវមានវិធានការបែបណាខ្លះដើម្បីទប់ទល់នឹងការគេចវេសពន្ធ?

២.តើត្រូវពង្រឹងវិធីសាស្ត្រសវនកម្មអ្វីខ្លះដើម្បីរួមចំណែកក្នុងការបង្កើនប្រសិទ្ធភាពរដ្ឋបាលសារពើពន្ធឆ្ពោះទៅកាត់បន្ថយការគេចវេសពីកាតព្វកិច្ច និងការជំពាក់បំណុលពន្ធហួសកាលកំណត់?

៣.តើត្រូវធ្វើដូចម្តេចខ្លះដើម្បីជំរុញឱ្យការអនុវត្តច្បាប់របស់មន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារប្រកបដោយគុណភាព ប្រសិទ្ធភាព និងតម្លាភាព?

## ៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

### ៥.១. ទំហំនៃការស្រាវជ្រាវ

ទំហំនៃការស្រាវជ្រាវនេះកំណត់ធ្វើនៅអគ្គនាយដ្ឋានពន្ធដារទាំងមូល ដោយសិក្សាលើលទ្ធផលដែលសម្រេចបានក្នុងរយៈពេលកន្លងមកដោយគិតចាប់ពីឆ្នាំ ២០២០ ដល់ឆ្នាំ២០២៣ របស់អគ្គនាយដ្ឋានពន្ធដារដើម្បីជ្រើសរើសយកមកបម្រើឱ្យការសិក្សាស្រាវជ្រាវនេះ។

### ៥.២. ដែនកំណត់នៃការស្រាវជ្រាវ

ចំពោះដែនកំណត់នៃការសិក្សានេះ គឺផ្តោតតែទៅលើនីតិវិធីនៃការធ្វើសវនកម្មសារពើពន្ធសហគ្រាស និងការតវ៉ាលើការកំណត់ពន្ធឡើងវិញ របស់អគ្គនាយកដ្ឋានពន្ធដារតែប៉ុណ្ណោះ ជាពិសេសការធ្វើសវនកម្មនិងការតវ៉ាលើការកំណត់ពន្ធឡើងវិញទៅលើសហគ្រាសអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះត្រូវធ្វើឡើងតាមរចនាសម្ព័ន្ធដូចខាងក្រមះ

- សេចក្តីផ្តើមៈ លំនាំបញ្ហា ចំណោទបញ្ហា គោលបំណងនៃការស្រាវជ្រាវ ទំហំ និងដែនកំណត់ វិធីសាស្ត្រនៃការស្រាវជ្រាវ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ
- ជំពូកទី១ រំលឹកទ្រឹស្តីៈ និយមន័យពន្ធ ទ្រឹស្តីពាក់ព័ន្ធផ្សេងៗ ទស្សនទានផ្សេងៗទាក់ទងនឹងសវនកម្មពន្ធដារ
- ជំពូកទី២ លទ្ធផលនៃការស្រាវជ្រាវៈ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ ការបែងចែករចនាសម្ព័ន្ធគ្រប់គ្រង លទ្ធផលការងារសម្រេចបាន
- ជំពូកទី៣ នីតិវិធីនៃការធ្វើសវនកម្ម និងនីតិវិធីក្រោយសវនកម្មៈ នីតិវិធីនៃការធ្វើសវនកម្ម នីតិវិធីក្រោយសវនកម្ម ចំណុចខ្លាំងនៃការធ្វើសវនកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ ចំណុចខ្សោយនៃការអនុវត្តន៍សវនកម្ម សេចក្តីសន្និដ្ឋាន និងអនុសាសន៍។

## ៧. វិធីសាស្ត្រប្រមូលទិន្នន័យ

ទិន្នន័យដែលប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវនេះដែលបានពីការស្រាវជ្រាវ មានទាំងបែបបរិមាណនិងបែបគុណភាព គឺប្រៀបធៀបលទ្ធផលមុនពេលធ្វើការសវនកម្ម និងក្រោយពេលធ្វើសវនកម្ម ដោយទិន្នន័យទាំងនោះផ្អែកលើទិន្នន័យបន្ទាប់បន្សំ (Secondary Data) តែប៉ុណ្ណោះ។ ទិន្នន័យបន្ទាប់បន្សំដែលនាងខ្ញុំយកមកប្រើប្រាស់គឺជាទិន្នន័យដែលបានមកពីសៀវភៅនិង ឯកសារផ្សេងៗដូចជាៈ

- ការស្វែងរកតាមរយៈប្រព័ន្ធអេឡិត្រូនិច
- ឯកសារដែលបានដោយអគ្គនាយកដ្ឋានពន្ធដារ
- ឯកសារផ្សេងៗដែលមាននៅក្នុងបណ្ណាល័យ
- បានពីការសាកសួរពីមន្ត្រីផ្នែករដ្ឋបាលពន្ធដារ

# ជំពូកទី១

# រំលឹកទ្រឹស្តី

## ១.១. និយមន័យ

### ១.១.១.សវនកម្ម

សវនកម្មពន្ធដារសំដៅដល់ការពិនិត្យបញ្ជាក់លើបញ្ជីកាគណនេយ្យរបាយការណ៍ហិរញ្ញវត្ថុ និងឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់អ្នកជាប់ព័ន្ធ ដើម្បីបញ្ជាក់ថាការគណនាការប្រកាសនិងការបង់ប្រាក់ពន្ធបានត្រឹមត្រូវតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ[១]។

សវនកម្មពន្ធដារគឺជាវិធានការដ៏សំខាន់ក្នុងការគ្រប់គ្រងនិងប្រមូលពន្ធឱ្យមានតម្លាភាពនិងប្រសិទ្ធភាពដើម្បីធានាសមធម៌ក្នុងការបង់ពន្ធ។

### ១.១.២. ប្រភេទសវនកម្មពន្ធដារ

យោងតាមច្បាប់ស្តីពីសារពើពន្ធ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ បានធ្វើការបែងចែកសវនកម្មពន្ធដារដូចជា៖ សវនកម្មលើលិខិតស្នាម សវនកម្មពន្ធដល់ទីកន្លែង។

ក.សវនកម្មលើលិខិតស្នាម (Desk Audit)៖ ធ្វើឡើងនៅទីកន្លែងរដ្ឋបាលសារពើពន្ធ ដោយពិនិត្យវិនិច្ឆ័យលើលិខិតប្រកាសសារពើពន្ធ ដែលមានភាពមិនប្រក្រតី ឬភាពមិនស៊ីសង្វាក់គ្នាលើលិខិតប្រកាស។

ខ.សវនកម្មពន្ធដល់ទីកន្លែង ៖ គឺជាការចុះធ្វើសវនកម្មដល់ទីតាំងប្រកបអាជីវកម្មរបស់សហគ្រាសដែលជាកម្មវត្ថុនៃការធ្វើសវនកម្ម ដើម្បីពិនិត្យស្ថានភាពអាជីវកម្មជាក់ស្តែង បញ្ជីកាគណនេយ្យ លិខិតយុត្តិការ និងឯកសារផ្សេងៗ ហើយសវនកម្មពន្ធដល់ទីកន្លែងនិងត្រូវបានបែងចែកជាពីរប្រភេទដូចជា៖

- សវនកម្មមានកម្រិត (Limited Audit) ៖ គឺជាការធ្វើសវនកម្មរយៈពេលខ្លីនិងភ្លាមៗទៅលើប្រភេទពន្ធអាករមួយចំនួន វៀរលែងតែពន្ធលើប្រាក់ចំណូល និងអាចធ្វើឡើងចំពោះតែរយៈពេលជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធចរន្ត(N) និងឆ្នាំជាប់ពន្ធមុនឆ្នាំជាប់ ពន្ធចរន្ត(N-1) ។
- សវនកម្មពេញលេញ (Comprehensive Audit)៖ គឺជាការធ្វើសវនកម្មទៅលើពន្ធអាករគ្រប់ប្រភេទដែលធ្វើឡើងក្នុងរង្វង់៣ឆ្នាំជាប់ពន្ធថយក្រោយ(N-3) និងមិនតម្រូវឱ្យធ្វើគ្រប់ឆ្នាំជាប់ពន្ធ ឬរយៈពេលជាប់ពន្ធនោះទេ គឺធ្វើឡើងតែឆ្នាំជាប់ពន្ធណា ដែលមានហានិភ័យខ្ពស់ប៉ុណ្ណោះ។ វៀរលែងតែករណី៖

[១] ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីសវនកម្មពន្ធដារ, លេខ២៧០សហវ.ប្រក, ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩

- មានការស្នើសុំពីអ្នកជាប់ពន្ធ
- មានខាតយោង ឬឥណទានយោងពីឆ្នាំជាប់ពន្ធមុន
- មានភស្តុតាងថាសហគ្រាសបានគេចវេះពន្ធ

#### ១.១.៣. ទស្សនទានផ្សេងៗពាក់ព័ន្ធនឹងសវនកម្មពន្ធដារ

សវនកម្មពន្ធដារគឺជាវិធានការដ៏សំខាន់ជាយុទ្ធសាស្ត្រក្នុងការគ្រប់គ្រង និងប្រមូលពន្ធហើយការធ្វើសវនកម្មនេះមានការគោលដៅដូតទៅះ

- បង្ហាញពីសមត្ថភាពនៃការគ្រប់គ្រងរបស់រដ្ឋបាលសារពើពន្ធ
- ជំរុញនិងកែតម្រង់អ្នកជាប់ពន្ធឲ្យបានត្រឹមត្រូវតាមបទបញ្ញត្តិពន្ធដារដោយស្ម័គ្រចិត្តនិងដាក់ទោសទណ្ឌចំពោះអ្នកដែលអនុវត្តមិនបានត្រឹមត្រូវតាមបទបញ្ញត្តិពន្ធដារ
- ប្រមូលចំណូលពន្ធដែលបាត់បង់ចូលក្នុងថវិកាជាតិ
- កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ ឬភ្នាក់ងារកាត់ទុកផ្អែកលើការអង្កេត និងផ្តុំព័ត៌មាន
- គណនា និងប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម ពន្ធប្រថាប់ត្រា ការប្រាក់ និងចំណូលផ្សេងៗ

### ១.២. ទ្រឹស្តីពាក់ព័ន្ធផ្សេងៗ

#### ១.២.១. ពន្ធ

ពន្ធសំដៅដល់ពន្ធអាករដែលក្នុងនោះរួមមាន ពន្ធផ្ទាល់ និង ពន្ធប្រយោល។ ពន្ធគឺជាបន្ទុករបស់ប្រជាពលរដ្ឋបង់ចូលថវិកាជាតិ។ប្រជាពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចបង់ពន្ធហើយទទួលតម្លៃតបស្នងពីរដ្ឋាភិបាលវិញតាមរយៈទំនិញ ឬសេវាសាធារណៈ។ ពន្ធគឺជាឧបករណ៍របស់រាជរដ្ឋាភិបាល ដែលបានបង្កើតឡើងដើម្បីកៀរគរចំណូលចូលថវិកាសម្រាប់ចំណាយសាធារណៈហើយពន្ធត្រូវបានប្រមូលចូលថវិកាជាតិ ដើម្បីសម្រាប់ចំណាយសេវាសាធារណៈ[២]។

ពន្ធផ្ទាល់ គឺជាប្រភេទពន្ធដែលរដ្ឋបាលកំណត់កម្មវត្ថុផ្ទាល់នៃពន្ធលើបុគ្គល ឬទ្រព្យសម្បត្តិហើយទ្រព្យសម្បត្តិដែលជាប់ពន្ធរួមមានចលនទ្រព្យនិងអចលនទ្រព្យ។ពន្ធផ្ទាល់រួមមានជាអាទិ៍[៣]៖ ពន្ធលើថ្លៃឈ្នួលផ្ទះ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ពន្ធប្រថាប់ត្រា ពន្ធប៉ាតង់ ពន្ធលើប្រាក់បៀវត្ស ពន្ធលើប្រាក់ចំណូល ពន្ធអប្បបរមា ពន្ធតែមប្រ៊ី និងផ្លាកយីហោ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ពន្ធលើប្រាក់ចំណេញមូលធន ពន្ធលើឈ្នួលផ្ទះ និងដី។

ពន្ធប្រយោល គឺជាប្រភេទដែលមានកម្មវត្ថុជាការប្រើប្រាស់ទំនិញឬសេវាកម្ម ។ ពន្ធប្រយោលរួមមានជាអាទិ៍ ៖ អាករបំភ្លឺសាធារណៈ អាករលើការស្នាក់នៅ អាករលើផលរបរ អាករលើទំនិញនិងសេវាមួយចំនួន ពន្ធនាំចេញនាំចូលឬពន្ធគយ។

### ១.២.២. ពន្ធ និងអាករគ្រប់ប្រភេទ

១.ពន្ធលើប្រាក់ចំណូល(ពបច)[៤] គឺជាបំណុលរបស់បុគ្គលអនិវាសនជនចំពោះប្រាក់ចំណូលកម្ពុជា និងប្រាក់ចំណូលប្រភពបរទេស ឬរបស់បុគ្គលអនិវាសនជនចំពោះប្រាក់ចំណូលប្រភពកម្ពុជា។

អត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំមានដូចតទៅ៖

- ២០ ភាគរយ ចំពោះប្រាក់ចំណូលដែលសម្រេចបានដោយនីតិបុគ្គល
- ៣០ ភាគរយ ចំពោះប្រាក់ចំណូលដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និងឧស្ម័នធម្មជាតិ ឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិរួមទាំង ព្រៃឈើ រ៉ែ មាស ឬត្បូងថ្មមានតម្លៃនានា
- 0 ភាគរយ ចំពោះប្រាក់ចំណូលរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធដែលកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

តារាងទី១៖តារាងអត្រាពន្ធប្រាក់ចំណូលប្រចាំឆ្នាំកំណើនតាមថ្នាក់ ៖

| ភាគនៃប្រាក់ចំណូលប្រចាំឆ្នាំដែលត្រូវជាប់ពន្ធ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | 0 ៛ | ដល់ | ១៨ 000 000 ៛ | 0% |
| ពី | ១៨ 000 00១ ៛ | ដល់ | ២៤ 000 000 ៛ | ៥% |
| ពី | ២៤ 000 00១ ៛ | ដល់ | ១0២ 000 000 ៛ | ១0% |
| ពី | ១0២ 000 00១ ៛ | ដល់ | ១៥0 000 000 ៛ | ១៥% |
| | លើសពី ១៥0 000 000 ៛ | | | ២0% |

ប្រភព ៖ អគ្គនាយដ្ឋានពន្ធដារ

[២] តាម website https://www.britannica.com/topic/taxation, បានចូលទស្សនាថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣

[៣] ច្បាប់ស្តីពីសារពើពន្ធ, លេខ០៥២៣/00៤, នស/រកម, ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣

[៤]ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីពន្ធលើប្រាក់ចំណូល, លេខ០៩៨ សហវ. ប្រក,ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០, មាត្រា២០

២.ពន្ធប៉ាតង់[៥] គឺជាពន្ធប្រចាំឆ្នាំ ដែលត្រូវបានកំណត់លើសកម្មភាពអាជីវកម្មដោយផ្អែកលើប្រភេទអ្នកជាប់ពន្ធ និងកម្រិតផលរបរដែលតម្រូវឲ្យគ្រប់ក្រុមហ៊ុនដែលប្រកបអាជីវកម្មនៅក្នុងប្រទេសកម្ពុជាទាំងអស់បង់នៅត្រឹមចុងខែមីនាជារៀងរាល់ឆ្នាំ។ បែបបទនៃការបង់ពន្ធប៉ាតង់ត្រូវបានកំណត់ និង បែងចែកដូចតទៅ៖ ៤០០ ០០០រៀល សម្រាប់អ្នកជាប់ពន្ធតូច ១ ២០០ ០០០រៀល សម្រាប់អ្នកជាប់ពន្ធមធ្យម និងត្រូវបង់ពី ៣ ០០០ ០០០រៀល ទៅ ៥ ០០០ ០០០រៀល សម្រាប់អ្នកជាប់ពន្ធធំ។ អ្នកជាប់ពន្ធត្រូវមាន កាតព្វកិច្ច ដាក់តាំងបង្ហាញប័ណ្ណប៉ាតង់ដែលមានសុពលភាពនៅតាមទីតាំងប្រកបអាជីវកម្មរបស់ខ្លួន ។

៣.អាករលើតម្លៃបន្ថែម(អតប)[៦] ជាទូទៅជាបន្ទុករបស់អ្នកប្រើប្រាស់ឬអាជីវកម្មដែលមានការលើកលែងពន្ធខណៈដែលគេមិនអាចទទួលបានមកវិញនូវតម្លៃពន្ធដែលបានបង់រួចហើយ។អាស្រ័យតាមប្រព័ន្ធពន្ធដារលើតម្លៃបន្ថែមនៅកម្ពុជា លទ្ធផលពន្ធប្រមូលបានពីអតិថិជនដោយបូក បន្ថែមអាករលើតម្លៃបន្ថែមទៅលើចំនួនដែលត្រូវគិតចំពោះទំនិញ ឬសេវាកម្ម។ ទោះបីជាយ៉ាងណាក៏ដោយអាជីវកម្មមួយក៏ត្រូវទូទាត់ពន្ធដែលបានដាក់បញ្ចូលទៅឲ្យអ្នកផ្គត់ផ្គង់លើការទិញដែលបានធ្វើឡើង។ អត្រានៃអាករលើតម្លៃបន្ថែមមានដូចខាងក្រោម៖

- 0% អត្រានេះអនុវត្តចំពោះតែទំនិញនាំចេញពីព្រះរាជាណាចក្រកម្ពុជា និងសេវាកម្មដែល ប្រើប្រាស់នៅក្រៅប្រទេសកម្ពុជា។ ការនាំចេញកំណត់ថាជាការដឹកជញ្ជូនដោយរួមបញ្ចូល ទាំងអ្នកដំណើរ និងទំនិញជាអន្តរជាតិ ។

- ១០% អត្រាស្តង់ដានេះអនុវត្តន៍ចំពោះគ្រប់ការផ្គត់ផ្គង់ទាំងអស់ជាជាងការនាំចេញ និងការផ្គត់ផ្គង់មិនជាប់ពន្ធផង។

៤. ពន្ធអប្បបរមា[៧] ជាពន្ធមួយដាច់ដោយឡែក និងផ្សេងពីពន្ធលើប្រាក់ចំណេញ។ ពន្ធនេះត្រូវបង់ដោយអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស លើកលែងតែគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមមាត្រា១ភាគរយនៃផលរបរប្រចាំឆ្នាំរួមបញ្ចូលទាំងពន្ធអាករនានាវៀរលែងតែអាករលើតម្លៃបន្ថែម។ ពន្ធនេះត្រូវបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ហើយអាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ។

[៥] ច្បាប់ស្តីពីពន្ធប៉ាតង់, លេខ២២ ក្រ. ច, ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ១៩៨៥, មាត្រា៣៩

[៦] ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីអាករលើតម្លៃបន្ថែម, លេខ១០៣១ សហវ. ពដ., ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៨, មាត្រា ៥៦

[៧] ច្បាប់សារពើពន្ធស្តីពីពន្ធអប្បបរមា, លេខ នស.រកម.០២៩៣.០៣, ប្រកាសអោយប្រើថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧, មាត្រា២៤

៥. ពន្ធលើប្រាក់បៀវត្ស[៩] គឺជាពន្ធប្រចាំខែកំណត់លើប្រាក់បៀវត្សដែលរូបវន្តបុគ្គលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបំរើការងារ។ រូបវន្តបុគ្គលនិវាសនជន នៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជានិង ប្រាក់បៀវត្សប្រភពបរទេស។ រូបវន្តបុគ្គលអនិវាសនជនត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា សហគ្រាសដែលជានិយោជកត្រូវមានកាតព្វកិច្ចកាត់ទុកពន្ធលើប្រាក់បៀវត្សនៅមុនពេលបើកប្រាក់បៀវត្សអោយដល់និយោជិត និងបង់ប្រាក់ពន្ធនេះជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតនៅថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលប្រាក់បៀវត្សត្រូវបានបើក។

សម្រាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែនិងត្រូវកាត់ទុក តាមអត្រាកំណើនតាមថ្នាក់ដូចតទៅៈ

តារាងទី២៖ តារាងអត្រាកំណើនតាមថ្នាក់ថ្មី និងលម្អៀងលើសប្រាក់ពន្ធតាមប្រភេទនីមួយៗ

| ភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ | | | | អត្រាពន្ធ | លម្អៀងលើសនៃប្រាក់បៀវត្សពន្ធតាមថ្នាក់នីមួយៗ |
|---|---|---|---|---|---|
| ពី | 0 ៛ | ដល់ | ១ ៥00 000 ៛ | 0% | 0៛ |
| ពី | ១ ៥00 00១ ៛ | ដល់ | ២ 000 000 ៛ | ៥% | ៧៥ 000៛ |
| ពី | ២ 000 00១ ៛ | ដល់ | ៨ ៥00 000 ៛ | ១0% | ១៧៥ 000៛ |
| ពី | ៨ ៥00 00១ ៛ | ដល់ | ១២ ៥00 000 ៛ | ១៥% | ៦00 000៛ |
| | | លើសពី | ១២ ៥00 000 ៛ | ២0% | ១ ២២៥ 000៛ |

ប្រភព៖ អគ្គនាយដ្ឋានពន្ធដារ

សម្រាប់និយោជិតអនិវាសនជន ពន្ធលើប្រាក់បៀវត្សត្រូវបានកាត់ទុកតាមអត្រា ២0% នៃទឹកប្រាក់ត្រូវបើកឱ្យមុនការកាត់ទុក។ ពន្ធកាត់ទុកនេះ គឺជាពន្ធចុងក្រោយនៃប្រាក់បៀវត្សសម្រាប់អនិវាសនជនជាអ្នកទទួលប្រាក់បៀវត្ស។

ចំពោះអត្ថប្រយោជន៍បន្ថែមជារៀងរាល់ខែ សហគ្រាស ក្រុមហ៊ុនត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធតាមអត្រា ២0%នៃតម្លៃសរុបរបស់អត្ថប្រយោជនបន្ថែមដែលបានផ្តល់ឱ្យនិយោជិតទាំងអស់។តម្លៃនៃអត្ថប្រយោជន៍បន្ថែមគឺជាតម្លៃទីផ្សាររួមទាំងពន្ធអាករទាំងអស់។

[៩]ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសេចក្តីណែនាំស្តីពីការអនុវត្តអត្រាពន្ធលើប្រាក់បៀវត្សថ្មី,លេខ ០១៧ សហវ. ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២, មាត្រា៤២ថ្មី

៦. ពន្ធអាករពិសេសលើទំនិញ និងសេវាមួយចំនួន[៩] មានភេសជ្ជៈ ស្រា ស្រាបៀរ (២០%) និងបារី (១៥%) សេវាមួយចំនួនមានសេវាលំហែកំសាន្ត(១០%) ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាស (១០%) និងសេវាទូរស័ព្ទ(៣%)។ អ្នកជាប់ពន្ធដែលផលិតទំនិញ ឬផ្គត់ផ្គង់សេវាទាំងនោះត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់អាករនេះជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ដែលមានការផ្គត់ផ្គង់។

៧. ពន្ធប្រថាប់ត្រា[១០] គឺជាប្រភេទពន្ធដែលកំណត់លើ ៖

- ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន
- ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់មធ្យោបាយដឹកជញ្ជូនឬយានយន្តគ្រប់ប្រភេទ
- ការផ្ទេរចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន
- កិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវា ដែលប្រើប្រាស់ថវិការដ្ឋ
- លិខិតមានលក្ខណៈគតិយុត្ត ដូចជា ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងលិខិតស្តីពីការបិទក្រុមហ៊ុនត្រូវជាប់ពន្ធប្រថាប់ត្រាតាមអត្រាសមាមាត្រ ៤%ចំពោះការផ្ទេរកម្មសិទ្ធិមធ្យោបាយដឹកជញ្ជូននិងយានជំនិះដូចខាងក្រោម៖
    - រថយន្តដឹកទំនិញធុនធ្ងន់ រថយន្តដឹកទំនិញធុនស្រាល រថយន្ត ទោចក្រយាន្ត
    - កាណូត សាឡង់ កាប៉ាល់
    - លិខិតមានលក្ខណៈសម្បត្តិគតិយុត្តិដូចខាងក្រោម ត្រូវជាប់ពន្ធប្រថាប់ត្រា៖
    - លិខិតស្តីពីការបង្កើតក្រុមហ៊ុន ១ ០០០ ០០០រៀល
    - លិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូកគ្នា ១ ០០០ ០០០រៀល
    - លិខិតស្តីពីការបិទក្រុមហ៊ុន ១ ០០០០០០រៀល
    - 0.១% នៃតម្លៃចុះកិច្ចសន្យាចំពោះផ្គត់ផ្គង់ទំនិញ ឬសេវាកម្មប្រើប្រាស់ថវិការដ្ឋ។
    - 0.១% នៃតម្លៃភាគហ៊ុនចំពោះការចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន
    - ពន្ធប្រថាប់ត្រាត្រូវបានបង់ដោយអ្នកទទួលកម្មសិទ្ធិ ទទួលសិទ្ធិកម្មកាប់ដីធ្លី ដែលគ្មានសំណង់

---

[៩]ច្បាប់ស្តីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រង១៩៩៥ ស្តីពីពន្ធអាករពិសេសលើទំនិញ និងសេវាមួយចំនួន, ប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ជស/រកម/០៩៩៥/០១,ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥, មាត្រា១៨

[១០]ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធប្រថាប់ត្រា,លេខ ៥០៧ សហវ. ប្រក.,ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០១៧, មាត្រា៤០

គិតជាសមាមាត្រលើតម្លៃពិតប្រាកដនៃទ្រព្យសម្បត្តិនាថ្ងៃផ្ទេរកម្មសិទ្ធិកាន់កាប់។ ប៉ុន្តែដើម្បីឱ្យ មានភាពងាយស្រួល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចកំណត់តម្លៃសម្រាប់រយៈកាលនីមួយៗដើម្បី ធ្វើជាមូលដ្ឋានសម្រាប់ការគិតគូរប្រាក់ដែលត្រូវបង់។

៨. ពន្ធលើដីធ្លីមិនប្រើប្រាស់[១១] គឺជាប្រភេទពន្ធប្រចាំកំណត់លើដីដែលគ្មានសំណង់ និងដីដែលមានសំណង់បោះបង់ស្ថិតក្នុងទីក្រុងនានា និងក្នុងតំបន់ទាំងឡាយដែលកំណត់ដោយគណៈកម្មការវាយតម្លៃដីធ្លីមិនបានប្រើប្រាស់។ពន្ធលើដីធ្លីមិនបានប្រើប្រាស់ មានគោលបំណងដើម្បី៖

- ទប់ស្កាត់រាល់រូបភាពទិញដីទុកមិនប្រើប្រាស់ រង់ចាំពេលឡើងថ្លៃលក់យកកម្រៃលើស
- ជំរុញការប្រើប្រាស់ដីធ្លីឱ្យបានសមស្រប និងមានការអភិវឌ្ឍន៍
- បង្កើនសកម្មភាពសេដ្ឋកិច្ចនិងកម្លាំងការងាររួមចំណែកដល់ប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។

៩. អាករលើការស្នាក់នៅ[១២] ដែលត្រូវបានកំណត់តាមអត្រា២% លើថ្លៃស្នាក់នៅសណ្ឋាគារ ផ្ទះសំណាក់ផ្សេងៗក្នុងព្រះរាជាណាចក្រកម្ពុជា។

១០. អាករបំភ្លឺសាធារណៈ[១៣] អាកនេះត្រូវបានប្រមូលពន្ធលើអត្រា ៣%លើតម្លៃស្រាមេរ៉ៃ និងបារីដែលបានលក់ក្នុងព្រះរាជាណាចក្រកម្ពុជា។ អ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់ផលិតផលទាំងនេះត្រូវទទួលខុសត្រូវក្នុងការបងពន្ធប្រាក់អាករនេះ ជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ដែលមានក្នុងការផ្គត់ផ្គង់។

១១. ពន្ធកាត់ទុក[១៤] ជាទូទៅត្រូវបានកំណត់ថាអ្នកបង់ពន្ធជានិវាសនជនដែលបានចំណូលពី អត្រាការប្រាក់ ប្រាក់សួយសារ និងចំណូលដែលទាក់ទងនឹងការប្រើប្រាស់ ទ្រព្យសម្បត្តិ ភាគលាភ និងប្រាក់ចំណូលដែលបានទទួលពីការបំពេញសេវាកម្មបច្ចេកទេស ឬគ្រប់គ្រងរបស់បុគ្គលអនិវាសនជន ត្រូវកាត់ទុក និងបង់នូវប្រាក់ពន្ធចំនួន១៤ភាគរយ។

---

[១១]ប្រកាសលេខ ២២៤ សហវ. ប្រក. ពដ.ប្រកាសស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ ,ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៦, ប្រការ១

[១២]ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការអនុវត្តន៍អាករលើការស្នាក់នៅ, លេខ ៣៨០ សហវ.ពដ., ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ ២០០៥, មាត្រា៨

[១៣]ប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីអាករបំភ្លឺសាធារណៈ លេខ១៧៥ សហវ ពដ.ប្រក.,ថ្ងៃទី២២ ខែមករា ឆ្នាំ២០០២, ប្រការ២

ពន្ធកាត់ទុកត្រូវដល់កាលកំណត់នៅពេលណាមួយដែលការ បង់ប្រាក់ត្រូវបានធ្វើឡើង ឬនៅពេលដែលការចំណាយត្រូវបានកត់ត្រាទុក។ ប្រាក់ដែលទូទាត់ឱ្យបុគ្គលនិវាសនជនត្រូវជាប់ពន្ធកាត់ទុកតាមអត្រាដូចខាងក្រោម៖

- ជួល (១០%)
- ការប្រាក់ (១៥%) លើកលែងតែការបង់ប្រាក់ទៅឱ្យស្ថាប័នហិរញ្ញវត្ថុក្នុងស្រុក
- សេវាកម្ម (១៥%) លើកលែងតែការបង់ប្រាក់ទៅឱ្យអ្នកជាប់ពន្ធដែលបានចុះបញ្ជីដែលមាន
- វិក្កយប័ត្រមានអាករលើតម្លៃបន្ថែម
- ប្រាក់សួយសារ (១៥%)

ពន្ធកាត់ទុក មិនត្រូវអនុវត្តន៍ចំពោះការប្រាក់ដែលត្រូវបង់ទៅឱ្យធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុក ឬប្រាក់ចំណូលលើកលែងពន្ធ។

១២.ពន្ធលើប្រាក់ចំណេញមូលធន[១៥] ត្រូវអនុវត្តន៍លើចំណេញមូលធនសម្រេចបានពីការលក់ឬផ្ទេរ៖

- មូលធននៅក្នុងព្រះរាជាណាចក្រកម្ពុជានិងនៅបរទេសចំពោះរូបវន្តបុគ្គលនិវាសនជន
- មូលធននៅក្នុងព្រះរាជាណាចក្រកម្ពុជាចំពោះរូបវន្តបុគ្គលនិងនីតិបុគ្គលអនិវាសនជន។

មូលធនរួមមាន៖ អចលនទ្រព្យ ភតិសន្យា ទ្រព្យវិនិយោគ កេរ្តិ៍ឈ្មោះអាជីវកម្ម កម្មសិទ្ធិបញ្ញា រូបិយវត្ថុបរទេស។

១៣. ពន្ធតែមប្រិ៍ និងផ្លាកយីហោ[១៦] ត្រូវបានកំណត់លើលិខិតរដ្ឋបាល លិខិតតុលាការ លិខិតក្រៅតុលាការ និងបណ្ណប្រកាសផ្សាយដំណឹង ឬផ្លាកផ្សាយពាណិជ្ជកម្មផ្សេងៗដែលយកពន្ធតាមតារាងតម្លៃ។

១៤. ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ[១៧] ត្រូវប្រមូលលើម្ចាស់យានជំនិះគ្រប់ប្រភេទ ប្រាក់ពន្ធដែលប្រមូលបាន ត្រូវបង់ចូលថវិការដ្ឋដើម្បីរួមចំណែកជួសជុល និងការកសាងផ្លូវគមនាគមន៍ដែលយកពន្ធតាមប្រភេទមធ្យោបាយ និងយានជំនិះ។

[១៤]ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីពន្ធកាត់ទុកទូទៅ, លេខ១១២៩ សហវ.ប្រក.ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨, មាត្រា ២៥ ២៦ថ្មី

[១៥]ប្រកាសលេខរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពីពន្ធលើចំណេញមូលធន, លេខ៣៤៦ សហវ.ប្រក.,ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១, មាត្រា៧ថ្មី

[១៦]ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការអនុវត្តអនុក្រឹតលេខ ០៤ អនក្រ.បក ស្តីពីការកែសម្រួលតារាងពន្ធតែមប្រិ៍ និងផ្លាកយីហោ ,លេខ ៩៨២ សហវ.ប្រក,ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥, មាត្រា១១៨

១៥. ពន្ធលើអចលនទ្រព្យ[១៨] ជាប្រភេទពន្ធប្រចាំឆ្នាំ។ពន្ធនេះប្រមូលចំពោះអចលនទ្រព្យដែលមានតម្លៃលើសពី១០០លានរៀល និងមានទីតាំងស្ថិតនៅក្នុងភូមិសាស្ត្ររដ្ឋបាលរាជធានី និងរដ្ឋបាលក្រុងនៃខេត្តនានាក្នុងព្រះរាជាណាចក្រកម្ពុជា។ការប្រមូលពន្ធលើអចលនទ្រព្យនេះគឺសម្រាប់ជាផលប្រយោជន៍ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។

១៦. ប្រាក់រំដោះពន្ធលើប្រាក់ចំណូល[១៩] សហគ្រាសដែលជាប់ពន្ធលើប្រាក់ចំណេញ តាមរបបពិត រួមទាំងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលជាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ៩% មានកាតព្វកិច្ចបង់ប្រាក់រំដោះប្រចាំខែសម្រាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ១% នៃផលរបបរួមបញ្ចូលទាំងពន្ធអាករទាំងអស់វៀរលែងតែអាករលើតម្លៃបន្ថែមដែលសម្រេចបានក្នុងខែមុន។ប្រាក់រំដោះនឹងត្រូវបានយកមកកាត់កងពីន្ធលើប្រាក់ចំណេញ នៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ។

១៧. ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ[២០] ត្រូវបានកំណត់យកលើប្រាក់ឈ្នួលដែលបានមកពីការជួលៈ

- អាគារដែលសង់លើដីដូចជាផ្ទះ រោងចក្រ សណ្ឋាគារ ការិយាល័យ
- យន្តូបករណ៍ដែលជាប់ជាមួយគ្រឹះស្ថានឧស្សាហ៍កម្ម
- ឋាបនភ័ណ្ឌពាណិជ្ជកម្ម ឧស្សាហ៍កម្ម ដែលនៅនឹងមួយកន្លែង អាគារធំៗដែលដាក់ជាតុរាវឬផលិតផលផ្សេងៗ ដូចជាប្រេងឥន្ទនៈ កៅស៊ូចាក់ថ្នល់ គ្រាប់ធញ្ញជាតិ
- ផ្ទះបណ្តែតទឹក កប៉ាល់សំរាប់ធ្វើលំនៅដ្ឋាន ឬដើម្បីប្រកបអាជីវកម្មផ្សេងៗ
- ដីធ្លីដែលគ្មានសំណង់ដោយរាប់បញ្ចូលទាំងកន្លែងយកថ្ម យករ៉ែ ផ្សូងថ្ម បឹងបួរឬស្រែអំបិល។

[១៧]ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ,លេខ៥៣១,ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨

[១៨] ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសារាចរណែនាំស្តីពីការអនុវត្តប្រមូលពន្ធអចលនទ្រព្យ, លេខ ០១៥ សហវ.អពដ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១,មាត្រា១៦

[១៩]ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីពន្ធរំដោះលើប្រាក់ចំណូល, លេខ ០៩៨ សហវ. ប្រក,ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០, មាត្រា២៨ថ្មី

[២០]ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការគ្រប់គ្រងប្រមូលពន្ធលើឈ្នួលផ្ទះ និងដី,លេខ០២១ ប្រក.សហវ.,ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៩៤, មាត្រា២៦

### ១.២.៣. របបកំណត់ពន្ធ

ប្រព័ន្ធពន្ធដារកម្ពុជាមុនឆ្នាំ២០១៥ មានរបបពន្ធ២របបគឺ

- របបម៉ៅការ
- របបពិត(ស្វ័យប្រកាស)

ប៉ុន្តែក្រោយឆ្នាំ២០១៥ រដ្ឋាភិបាលកម្ពុជាអនុវត្តកំណត់ទម្រង់សារពើពន្ធថ្មីដែលមានរបបកំណត់ពន្ធតែមួយដែលរបបនោះគឺរបបពិត(ស្វ័យប្រកាស)។

### ១.២.៤. ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស

ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសចែកចេញជា៣ប្រភេទគឺ[២១]៖

- អ្នកជាប់ពន្ធតូចគឺជាសហគ្រាសឯកបុគ្គលឬសហគ្រាសសហកម្មសិទ្ធិដែល៖
  - មានផលរបរប្រចាំឆ្នាំចាប់ពី២៥០លានរៀល ដល់៧០០លានរៀល
  - មានផលរបរក្នុងរយៈពេល៣ខែជាប់គ្នានាពេលណាមួយដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តចាប់ពី៦លានរៀលឡើងទៅ
  - រំពឹងថាមានផលរបរក្នុងរយៈពេល៣ខែជាប់គ្នាខាងមុខចាប់ពី៦០លានរៀលឡើង
  - ចូលរួមដេញថ្លៃ ពិគ្រោះយោបល់ ឬស្នង់ថ្លៃក្នុងការផ្គត់ផ្គង់ទំនិញ ឬដែលប្រើប្រាស់ថវិការដ្ឋ រួមទាំងភាស៊ី
- អ្នកជាប់ពន្ធមធ្យមគឺជាបុគ្គលដែលស្ថិតក្នុងលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌខាងក្រោម៖
  - មានផលរបរប្រចាំឆ្នាំ លើសពី៧០០លានរៀល ដល់ ៤០០០លានរៀល
  - សហគ្រាសដែលបានចុះបញ្ជីជានីតិបុគ្គល
  - ស្ថាប័នរដ្ឋថ្នាក់ក្រោមជាតិ អង្គការ ឬសមាគមគ្រប់ប្រភេទ រួមទាំងអង្គការមិនមែនរដ្ឋាភិបាល
  - ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារ សហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា។
- អ្នកជាប់ពន្ធធំគឺជាបុគ្គលដែលស្ថិតក្នុងលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌខាងក្រោម៖
  - មានផលរបរប្រចាំឆ្នាំ លើសពី ៤០០០លានរៀល
  - គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP)

[២១]ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស, លេខ០២៥សហវ.ប្រក.អពដ,២៤ មករា ២០១៨, ប្រកាស៤

- សាខាក្រុមហ៊ុនបរទេស
- ស្ថាប័នរាជរដ្ឋាភិបាល ស្ថានទូត និងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារ សហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា។

## ១.២.៥. សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ

### ១.២.៥.១. សិទ្ធិរបស់អ្នកជាប់ពន្ធ

ក្នុងកំឡុងពេលធ្វើសវនកម្មអ្នកជាប់ពន្ធមានសិទ្ធិដូចខាងក្រោម[២២]៖

- ទទួលបាននូវការរក្សាទុកជាការសម្ងាត់ និងត្រូវបានយកមកប្រើប្រាស់តែក្នុងគោលដៅដែលមានបញ្ជាក់នៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ នូវព័ត៌មាននានាទាក់ទិននឹងកិច្ចការអាជីវកម្មរបស់ខ្លួនដែលបានផ្តល់អោយរដ្ឋបាលសារពើពន្ធ
- ទទួលព័ត៌មានជាប្រចាំអំពីកិច្ចដំណើរការនៃប្រព័ន្ធពន្ធដារ និងនីតិវិធីនៃការកំណត់ពន្ធ
- ទទួលព័ត៌មានអំពីសិទ្ធិរបស់ខ្លួន រួមទាំងសិទ្ធិក្នុងការប្តឹងតវ៉ា
- ទទួលព័ត៌មានអំពីសិទ្ធិរបស់ខ្លួន រួមទាំងសិទ្ធិក្នុងការប្តឹងតវ៉ា

### ១.២.៥.២. កាតព្វកិច្ចរបស់អ្នកជាប់ពន្ធ

ក្នុងកំឡុងពេលធ្វើសវនកម្មអ្នកជាប់ពន្ធមានកាតព្វកិច្ចដូចខាងក្រោម៖

- ចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ
- ដាក់លិខិតប្រកាសសារពើពន្ធនិងផ្តល់ព័ត៌មានតាមតម្រូវនៃបទប្បញ្ញត្តិស្តីពីពន្ធដារ
- បង់ពន្ធតាមកាលបរិច្ឆេទកំណត់ដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ
- កាន់កាប់ ថែរក្សា និងត្រូវបង្ហាញបញ្ជី លិខិតយុត្តិការ និងឯកសារផ្សេងៗដល់រដ្ឋបាលពើពន្ធ
- បង្ហាញខ្លួនចំពោះរដ្ឋបាលសារពើពន្ធតាមកាលបរិច្ឆេទដែលបានចុះក្នុងលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ
- បង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗទៀតដែលរដ្ឋបាលសារពើពន្ធបានកំណត់ទៅតាមកាលបរិច្ឆេទ ឬដែលរដ្ឋបាលសារពើពន្ធបានជូនដំណឹងជាលាយលក្ខណ៍អក្សរ។

[២២] ច្បាប់ស្តីពីសារពើពន្ធ សិទ្ធិនិងកាតព្វកិច្ច អ្នកជាប់ពន្ធ, លេខ១៦៦, ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣, មាត្រា១៩៣

# ជំពូកទី២

# ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ

## ២.១. ទិដ្ឋភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ

### ២.១.១. ប្រវត្តិរបស់អគ្គនាយដ្ឋានពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារ «អ.ព.ដ.» បានឆ្លងកាត់ដំណាក់កាលនៃការវិវឌ្ឍន៍ដូចខាងក្រោម៖

ក. សម័យកាល (១៩៥៣-១៩៧០)

យោងតាមខ្លឹមសារនៃសៀវភៅស្ដីពីហិរញ្ញវត្ថុកម្ពុជា (Les Finances du Cambodge) បោះពុម្ពជាភាសាបារាំងដោយលោក ALAIN GOURDON សញ្ជាតិបារាំង និងជាអ្នកជំនាញការ អមរាជរដ្ឋាភិបាលសម័យកាលនោះ ដែលបានរក្សាទុកដោយអតីតអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ឯកឧត្តម ស៊ុម អៀង បានបញ្ជាក់ឱ្យឃើញថារដ្ឋបាលពន្ធដារកម្ពុជា ត្រូវបានបង្កើតឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៥៣ តាមក្រមលេខ ៨៣០ NG ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៥៣ ដែលមានឈ្មោះថា **នាយកដ្ឋានពន្ធដារកម្ពុជា**។

យោងតាមឯកសារខាងលើនេះ នាយកដ្ឋានពន្ធដារកម្ពុជានៅសម័យកាលនោះ មានរចនាសម្ព័ន្ធថ្នាក់កណ្ដាលនៅរាជធានីភ្នំពេញ ដែលមានការិយាល័យពន្ធដារចំនួន៦ និងថ្នាក់ខេត្ត ក្រុង មានការិយាល័យពន្ធដារចំនួន១៤ និងមានប៉ុស្តិ៍ពន្ធដារចំនួន១៣០ នៅទូទាំងផ្ទៃប្រទេសកម្ពុជា[២៣]។ មុនពេលបង្កើតជានាយកដ្ឋានពន្ធដារកម្ពុជានៅក្នុងឆ្នាំ១៩៥៣ ក៏មានការប្រមូលពន្ធផងដែរតាមបែបរចនាសម្ព័ន្ធ ពិសេសម៉្យាងកំណត់ដោយអាណាព្យាបាលបារាំង ដែលគ្រប់គ្រងដោយនាយកដ្ឋានចំនួន៣ខុសៗគ្នាក្រោមការទទួលខុសត្រូវរបស់រដ្ឋអំណាចសហព័ន្ធឥណ្ឌូចិន។

ខ. សម័យសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥)

យោងតាមខ្លឹមសារនៃកម្រងអត្ថបទសារពើពន្ធ (Recueil des Textes Fiscaux)[២៤] ដែល បានរៀបចំដោយលោក ខែម ប៊ុនឆាន់ អគ្គនាយកនៃរដ្ឋបាលពន្ធដារកម្ពុជានៅក្នុងឆ្នាំ១៩៧១ បានបញ្ជាក់ឱ្យឃើញថាក្នុងសម័យកាលសាធារណរដ្ឋខ្មែររដ្ឋបាលពន្ធដារកម្ពុជាធ្វើការបន្តអនុវត្តការប្រមូលពន្ធស្របតាមច្បាប់ ប្រកាស និងសារាចរស្តីពីពន្ធដារ ដែលមានចែងមុនឆ្នាំ១៩៧០ ដោយគ្រាន់តែធ្វើការកែប្រែ និងបំពេញបន្ថែមចំណុចខ្វះខាតនានា ស្របតាមកាលៈទេសៈ និងពេលវេលា នៅពេលនោះតែប៉ុណ្ណោះ។

---

[២៣] ច្បាប់ពីស្តីពីហិរញ្ញវត្ថុកម្ពុជា Alain Gourdon, (Les Finances du Cambodge)

[២៤] ច្បាប់ស្តីពីកិច្ចការសារពើពន្ធ (Recueil des Textes fiscaux) ខែម ប៊ុនឆាន់, បោះផ្សាយឆ្នាំ១៩៧២

គ. សម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យក្រោមការដឹកនាំរបស់ ប៉ុល ពត រាល់រចនាសម្ព័ន្ធ សង្គម និងសេដ្ឋកិច្ច ទាំងមូលត្រូវបានកម្ទេចចោល ដូចជាការបំបាត់ទីផ្សារ លុបចោលការប្រើប្រាស់ រូបិយវត្ថុ បិទសាលារៀន មន្ទីរពេទ្យ និងវត្តអារាម រួមបញ្ចូលទាំងរដ្ឋបាលសារពើពន្ធផងដែរ។ល។

ឃ. សម័យក្រោយថ្ងៃរំដោះ (១៩៧៩-១៩៩០)

បន្ទាប់ពីថ្ងៃរំដោះជាតិមាតុភូមិ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដែលត្រូវបានគេទទួលស្គាល់ថាជារបបប្រល័យពូជសាសន៍ពោរពេញទៅដោយសោកនាដកម្ម ដែលស្ថានភាពនិងហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសទាំងមូល ត្រូវបានកម្ទេចរំលាយចោល និងធ្លាក់ចុះដុនដាបក្រោមកម្រិតសូន្យធ្វើឱ្យប្រជាជនកម្ពុជា និង ពិភពលោកទាំងមូលមិនអាចបំភ្លេចបាន។

នៅដើមឆ្នាំ១៩៨០ក្រុមប្រឹក្សារដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានដាក់ឱ្យដំណើរការនូវការប្រមូលចំណូលថវិការដ្ឋនៅតាមផ្ទះលក់ទំនិញ និងកន្លែងធ្វើអាជីវកម្មធំៗមួយចំនួនតែប៉ុណ្ណោះ ក្រោមរូបភាពជាការធ្វើវិភាគទាន ដែលជាដែនសមត្ថកិច្ចរបស់អង្គភាពមន្ទីរហិរញ្ញវត្ថុ ដើម្បីជំរុញ វិស័យសេដ្ឋកិច្ចឱ្យកាន់តែមានសកម្មភាពផុសផុលឡើង។

នៅឆ្នាំ១៩៨១ ក្រុមប្រឹក្សារដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាបានចេញសេចក្តីសម្រេចអនុញ្ញាតឱ្យក្រសួងហិរញ្ញវត្ថុអនុវត្តជាគំរូនូវកិច្ចប្រតិបត្តិការចុះឈ្មោះអាជីវកម្ម ប្រមូលពន្ធអាជីវកម្ម និងពន្ធលើទំនិញនាំចូលចំពោះមូលដ្ឋានមួយចំនួន តាមរយៈសេចក្តីសម្រេចលេខ ៧៨ សរច ចុះថ្ងៃ ទី០៩ ខែកក្កដា ឆ្នាំ១៩៨១[២៥]។ ផ្អែកតាមខ្លឹមសារនៃសារាចរលេខ ២៤៩-៨១ កហវ.ពដ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៨១ ការអនុវត្តជាគំរូនេះ គឺអនុវត្តតែនៅក្នុងរដ្ឋធានីភ្នំពេញ ទីរួមខេត្តកណ្តាល និង ស្រុកពញាឮតែប៉ុណ្ណោះ ហើយប្រមូលពន្ធតែទៅលើមូលដ្ឋានអាជីវកម្ម ផ្អែកពាណិជ្ជកម្ម ហូបចុក និងបម្រើ (សេវាកម្ម) ដែលកិច្ចការនេះស្ថិតក្រោមដែនសមត្ថកិច្ចរបស់នាយកដ្ឋានពន្ធដារ ឧស្សាហពាណិជ្ជ[២៦]។

នៅចុងឆ្នាំ១៩៨២ ជាជំហានបន្ទាប់ ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាបានដាក់ឱ្យអនុវត្តការប្រមូលពន្ធកាន់តែទូលំទូលាយក្នុងក្របខ័ណ្ឌទូទាំងប្រទេសលើកលែងតែ ខេត្តព្រះវិហារ ខេត្តមណ្ឌលគិរី និង ខេត្តរតនគិរី តាមរយៈក្រឹត្យច្បាប់លេខ ១៤ ក្រ.ច ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៨២[២៧]។ បន្ទាប់មក ក្រសួង

[២៥]សេចក្តីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា, លេខ ៧៨ សរច ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៨១

[២៦]សារាចរស្តីពីកិច្ចប្រតិបត្តិការសាកល្បងគំរូលើកិច្ចការពន្ធអាជីវកម្ម, លេខ ២៤៩-៨១ កហវ. ពដ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៨១

[២៧]ក្រឹត្យច្បាប់ស្តីពីពន្ធអាជីវកម្ម, លេខ ១៤ ក្រ. ច ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៨២

ហិរញ្ញវត្ថុបានដាក់ឱ្យអនុវត្តប្រកាសលេខ ២១៤៩-៨២ កហវ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៨២ ស្តីពីការណែនាំអនុវត្តក្រឹត្យច្បាប់ពន្ធអាជីវកម្មចំពោះមុខ[២៨] ដែលតម្រូវឱ្យប្រមូលពន្ធលើមូលដ្ឋានអាជីវកម្មចល័ត និងអចល័តក្នុងផ្នែកពាណិជ្ជកម្ម ហូបចុក និង បម្រើការងារ ដែលមានសកម្មភាពក្រោមរូបភាពជាឯកជន ឬសមូហភាព ដូចជាក្រុមហ៊ុន សមាគម ក្រុមសាមគ្គី សហករណ៍ ក្រុមហ៊ុនចម្រុះរដ្ឋជាដើម។ ចំពោះរបៀបរបបនៃការកំណត់ពន្ធសម្រាប់ ការប្រមូលពន្ធនេះ គឺមិនគិតតាមអត្រាទេ ប៉ុន្តែត្រូវគិតតាមផលរបរប្រចាំខែ និងកំណត់ប្រាក់ពន្ធត្រូវបង់តែម្តង ដែលមានន័យថាបើផលរបរប្រចាំខែតិចគឺបង់ពន្ធតិច បើផលរបរច្រើនគឺបង់ពន្ធច្រើន។

ង. សម័យកាល (១៩៩០-២០០៨)

រហូតដល់ឆ្នាំ១៩៩០ នាយកដ្ឋានពន្ធដារឧស្សាហាពាណិជ្ជត្រូវបានប្តូរឈ្មោះមកជានាយកដ្ឋានពន្ធដារ ហើយនៅតាមបណ្តារាជធានី ខេត្ត ក៏បានប្តូរឈ្មោះពីការិយាល័យពន្ធដារឧស្សាហាពាណិជ្ជ ទៅជាសាខាពន្ធដាររដ្ឋធានី ខេត្ត[២៩]។

ក្រោយពីការបោះឆ្នោតជាសកលនៅឆ្នាំ១៩៩៣ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបាន តាក់តែងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ដោយមានកំណត់នូវមូលដ្ឋានសម្រាប់ការប្រមូលពន្ធចាប់ពីឆ្នាំ១៩៩៤ រហូតមកក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានពន្ធដារ។

នៅក្នុងឆ្នាំ២០០០ នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ[៣០]។

ច. សម័យកាល (២០០៨-២០១២)

នៅក្នុងឆ្នាំ២០០៨ នាយកដ្ឋានពន្ធដារត្រូវបានដំឡើងទៅជាអគ្គនាយកដ្ឋានពន្ធដារ ដែលមានភារកិច្ចគ្រប់គ្រងរដ្ឋបាលប្រមូលពន្ធដារក្នុងស្រុក (ពន្ធផ្ទៃក្នុង) បង្កើតគោលនយោបាយពន្ធដារ ក៏ដូចជាធ្វើសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការយកពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការកែសម្រួល និងបង្កើតការិយាល័យថ្មីបន្ថែមមួយចំនួនទៀត ដើម្បីសម្រួលដល់ការងារប្រមូលចំណូល

---

[២៨] ប្រកាសស្តីពីការណែនាំអនុវត្តក្រឹត្យ-ច្បាប់ពន្ធអាជីវកម្មចំពោះមុខ, លេខ ២១៤៩-៨២ កហវ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៨២

[២៩] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងហិរញ្ញវត្ថុ , លេខ ២៤ អនក្រ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩០
សារាចរ ណែនាំអនុវត្តន៍លេខ ០៥៧ កហវ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៩១

[៣០] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ០៤ អនក្រ. បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០

ពន្ធតាមរយៈអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃ ទី១៥ ខែកញ្ញា ឆ្នាំ២០០៨[៣១] ដើម្បីឆ្លើយតប និងសម្រប ទៅតាមការវិវត្ត និងការបន្តរីកធំឡើង ជាបន្តបន្ទាប់នៃវិសាលភាពប្រតិបត្តិការ របស់អគ្គនាយកដ្ឋានពន្ធដារទាំងមូល។

### ២.១.២. ប្រវត្តិនៃការកកើតការិយាល័យ

ការិយាល័យសវនកម្មសារពើពន្ធសហគ្រាស គឺជាការិយាល័យថ្នាក់ជាតិ ស្ថិតនៅក្នុងនាមនាយកដ្ឋានពន្ធដារក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ការិយាល័យនេះបង្កើតក្នុងឆ្នាំ១៩៩៦ ដែលមានសមាសធាតុមន្ត្រីសុទ្ធតែឆ្លងកាត់ការប្រឡងជ្រើសរើស និងឆ្លងកាត់ការបង្ហាត់បង្រៀនពីជំនាញការសាធារណរដ្ឋបារាំងប្រចាំនៅកម្ពុជា។

### ២.១.៣. ចក្ខុវិស័យនិងបេសកកម្មរបស់អគ្គនាយដ្ឋានពន្ធដារ

#### ២.១.៣.១. ចក្ខុវិស័យរបស់អគ្គនាយដ្ឋានពន្ធដារ

ចក្ខុវិស័យរបស់អគ្គនាយកដ្ឋានពន្ធដារ គឺធ្វើឱ្យមានការទទួលស្គាល់ និងការគោរពពីសំណាក់អ្នកជាប់ពន្ធ ចំពោះភាពត្រឹមត្រូវ និងគុណភាពនៃការគ្រប់គ្រង។

#### ២.១.៣.២.បេសកកម្មរបស់អគ្គនាយដ្ឋានពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារ ផ្តល់នូវសេវាដែលមានគុណភាព និងពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារប្រកបដោយភាពសុចរិត និងស្មើភាពចំពោះអ្នកជាប់ពន្ធទាំងអស់ ដើម្បីជំរុញអនុលោមភាពដោយស្ម័គ្រចិត្តឈានទៅសម្រេចបាននូវការអភិវឌ្ឍន៍ និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។

[៣១] អនុក្រឹត្យស្តីពីការដំឡើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យទៅជា អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ លេខ ១៣៤ អនក្រ. បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨

## ២.២. ទីតាំង និងនិមិត្តសញ្ញា

### ២.២.១. ទីតាំង

អគ្គនាយកដ្ឋានពន្ធដារ «អ.ដ.ព.» មានទីចាត់ការកណ្តាលស្ថិតនៅ អគារកែងមហាវិថីសហព័ន្ធរូស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដោយមានទូរស័ព្ទទំនាក់ទំនងលេខ ០២៣ ២៦៦ ២៣១ ៦៦៨ អ៊ីម៉ែល gdt@tax.gov.kh ។

រូបភាពទី១៖ ទីស្នាក់ការអគ្គនាយកដ្ឋានពន្ធដារ



ប្រភព៖ អគ្គនាយដ្ឋានពន្ធដារ

### ២.២.២. និមិត្តសញ្ញា

រូបភាពទី២៖ និមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារ




ប្រភព៖ អគ្គនាយដ្ឋានពន្ធដារ

## ២.៣. ភារកិច្ចរបស់អគ្គនាយដ្ឋានពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារជារដ្ឋបាលសារពើពន្ធមានប្រព័ន្ធចាត់តាំងឯកភាពទទួលខុសត្រូវគ្រប់គ្រងទាំងប្រទេសនិងត្រួតពិនិត្យការអនុវត្តបទបញ្ញត្តិស្តីពីពន្ធដារតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ចជាអាទិ៍ដូចតទៅ៖

- រៀបចំគោលនយោបាយសារពើពន្ធ និងការប្រមូលពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ
- រៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋាននានាស្តីពីពន្ធដារ កំណត់បញ្ជីឯកសារចាំបាច់នានា និងលិខិតយុត្តិការ ដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់កាប់រក្សាទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ
- កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកដោយផ្អែកលើការអង្កេត និងផ្តុំព័ត៌មាន
- គណនា និងប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងចំណូលផ្សេងៗ
- កសាងកម្មវិធី និងអនុវត្តការងារសវនកម្មចំពោះអ្នកជាប់ពន្ធ
- ទទួលបន្ទុកសហប្រតិបត្តិការអន្តរជាតិក្នុងផ្នែកពន្ធដារ
- អនុវត្តទោសទណ្ឌតាមច្បាប់ចំពោះអ្នកជាប់ពន្ធ និងភ្នាក់ងារកាត់ទុក ដែលល្មើសបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- ចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ

## ២.៤. តួនាទីនិងភារកិច្ចរបស់ការិយាល័យសវនកម្មពន្ធដារសហគ្រាស

- សវនកម្មទូទៅរួមមាន សវនកម្មពេញលេញ សវនកម្មលម្អិត និងសវនកម្មមានកម្រិតលើគ្រប់ប្រភេទពន្ធ និងគ្រប់អ្នកជាប់ពន្ធក្នុងទូទាំងប្រទេស
- រៀបចំរចនាសម្ព័ន្ធសម្រាប់គាំទ្រ កម្មវិធីយុទ្ធសាស្ត្រ អាទិភាព និងគោលដៅនានានៃសវនកម្មជាតិ
- ចូលរួមកសាង កំណត់គោលដៅអាទិភាព និងអនុវត្តកម្មវិធីសវនកម្ម
- កំណត់ពេញនូវលទ្ធផលដែលនឹងត្រូវបានសម្រេច ដោយផ្អែកលើកម្មវិធីសវនកម្ម និងការបែងចែកសវនករ
- សម្របសម្រួលជាមួយថ្នាក់ប្រតិបត្តិ ដែលទាក់ទងទៅនឹការគ្រប់គ្រងព័ត៌មានរបស់សហគ្រាសដែលត្រូវធ្វើសវនកម្ម
- គ្រប់គ្រងករណីរសើបជាមួយនឹងថ្នាក់កណ្តាល
- កំណត់បញ្ហាដើម្បីកែលម្អការអភិវឌ្ឍនូវគោលនយោបាយសវនកម្ម កម្មវិធីសវនកម្ម និងប្រព័ន្ធសវនកម្ម
- គ្រប់គ្រងព័ត៌មាន និងតាមដានរបស់ក្រុមសវនកម្មនីមួយៗ
- ធ្វើសវនកម្មអ្នកជាប់ពន្ធឲ្យបានត្រឹមត្រូវ និងទាន់ពេលវេលា
- ផ្តល់ព័ត៌មានស្តីពីលទ្ធផលនៃការធ្វើសវនកម្មប្រចាំខែ ត្រីមាស និងឆ្នាំដល់ថ្នាក់កណ្តាល

- រៀបចំផែនការសវនកម្មលើសំណុំឯកសារនីមួយៗ និងត្រួតពិនិត្យសំណុំឯកសារនីមួយៗឡើងវិញដើម្បីរកឱ្យឃើញបញ្ហាដែលពាក់ព័ន្ធនឹងសំណុំឯកសារទាំងនោះ
- ធ្វើសេចក្តីជូនដំណឹងជាលម្អិតដល់អ្នកជាប់ពន្ធស្តីពីលទ្ធផល ឬការផ្លាស់ប្តូរលទ្ធផលសវនកម្ម
- ធ្វើរបាយការណ៍បញ្ចប់ស្តីពីលទ្ធផលសវនកម្មលើអ្នកជាប់ពន្ធនីមួយៗ និងបញ្ជូនសំណុំឯកសារសវនកម្មទៅផ្នែកពិនិត្យការងារសវនកម្មឡើងវិញ
- លទ្ធផលនៃការកំណាយត់ពន្ធឡើងវិញលើអ្នកជាប់ពន្ធទៅថ្នាក់ប្រតិបត្តិដែលពាក់ព័ន្ធរៀបចំកម្មវិធី និងបណ្តុះបណ្តាលសវនករ។

## ២.៥. ការបែងចែករចនាសម្ព័ន្ធ

រូបភាពទី២៖ អង្គការលេខរបស់នាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ




ប្រភព៖ អគ្គនាយដ្ឋានពន្ធដារ

រចនាសម្ព័ន្ធ ឬអង្គការលេខនៅក្នុងអគ្គនាយកដ្ឋានពន្ធដារ ជាប្រភេទរចនាសម្ព័ន្ធតាមមុខងារ ដែលអាចធ្វើអោយអង្គភាពនីមួយៗមានការទទួលខុសត្រូវខ្ពស់ចំពោះការងារដែលអគ្គនាយកដ្ឋានផ្តល់អោយ។ រាល់ការសម្រេចគឺប្រតិបត្តិទៅតាមបណ្តាមុខងារនីមួយៗ ហើយប្រព្រឹត្តឡើងតាមបែបវិមជ្ឈការនៃអំណាចតាមរយៈអគ្គនាយករងប្រធាននាយកដ្ឋាននីមួយៗពីថ្នាក់ក្រោមទៅថ្នាក់លើ។

**រចនាសម្ព័ន្ធគ្រប់គ្រងរបស់អគ្គនាយដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារស្ថិតក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖

- អគ្គនាយកជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ
- អគ្គនាយកដ្ឋានពន្ធដារ មានថ្នាក់ដឹកនាំអគ្គនាយករងចំនួន (ចំនួន៧នាក់) ជាជំនួយការដល់អគ្គនាយកតាមលិខិតបង្គាប់ការបែងចែកភារកិច្ច និងការទទួលខុសត្រូវ
- អគ្គនាយកដ្ឋានពន្ធដារចែកជា ១១នាយកដ្ឋាន ៩សាខាខណ្ឌ(រាជធានី) និង២៤សាខាខេត្ត។ សាខាពន្ធដារខចែកជាស្នាក់ការពន្ធដារស្រុក ឬក្រុង
- អគ្គនាយកដ្ឋានពន្ធដារ មានបុគ្គលិកសរុបជាង១៦៧១នាក់ទូទាំងប្រទេស នោះស្រីមានចំនួន ៤៤៣នាក់។

នាយកដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដាររួមមាន៖

- នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
- នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក
- នាយកដ្ឋាននិតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិ្តបត្តការអន្តរជាតិ
- នាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ
- នាយកដ្ឋានគ្រប់គ្រងអ្នកជាបើពន្ធធំ
- នាយកដ្ឋានគ្រប់គ្រង អ្នកជាបើពន្ធតូច និងមធ្យម
- នាយកដ្ឋានសវនកម្មសហគ្រាស
- សាលាជាតិពន្ធដារ
- ទីចាត់ការពន្ធដាររាជធានីភ្នំពេញ។

សាខាខណ្ឌ(រាជធានីភ្នំពេញ)៖

- សាខាពន្ធដារខណ្ឌ៧មករា

- សាខាពន្ធដារខណ្ឌចំការមន
- សាខាពន្ធដារខណ្ឌទួលគោក
- សាខាពន្ធដារខណ្ឌមានជ័យ
- សាខាពន្ធដារខណ្ឌសែនសុខ
- សាខាពន្ធដារខណ្ឌដង្កោ
- សាខាពន្ធដារខណ្ឌពោធិ៍សែនជ័យ
- សាខាពន្ធដារខណ្ឌឬស្សីកែវ

## ២.៦. លទ្ធផលការងារសម្រេចបាន

ដើម្បីប្រមូលចំណូលពន្ធបានតាមផែនការ និងដើម្បីធានាបាននូវភាពជឿទុកចិត្តផ្នែកថវិកាដើម្បីបម្រើនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា និងការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំយុទ្ធសាស្ត្រកៀគរចំណូលចប្រមូលចំណូលបង់ចូលថវិកាជាតិស្រប ទៅតាមច្បាប់ថវិកា ដែលបានអនុម័តដោយរដ្ឋសភា។ជាក់ស្តែងស្ថានភាពនៃចំណូលពីវិស័យពន្ធដារបានកើនឡើងជារៀងរាល់ឆ្នាំរហូតកមដល់បច្ចុប្បន្ន។ ការកើនឡើងនៃចំណូលពន្ធនេះ គឺដោយសារសូចនាការពីសំខាន់ គឺការពង្រឹងផ្នែកសារពើពន្ធ និងការវិធានតឹងទារបំណុល។

យោងតាមរបាយការណ៍សរុបក្នុងរយៈពេល១២ខែ ឆ្នាំ២០២២ អគ្គនាយកដ្ឋានពន្ធដារបានធ្វើសវនកម្មមានសំណុំឯកសារបណ្តឹងតវ៉ាកំពុងដំណើរការមានចំនួន ៥០៧ ករណី ដែលក្នុងនោះបានទទួលពាក្យស្នើសុំថ្មីចំនួន ៣០៩ ករណី និងសល់យោងគ្រាមុនមានចំនួន ១៩៨ ករណី។ ជាលទ្ធផល បានដោះស្រាយសំណុំឯកសារបណ្តឹងតវ៉ាចំនួន ១៦៤ ករណី មានប្រាក់ពន្ធ ៣០០,០១ ប៊ីលានរៀល ប្រៀបធៀបនឹង រយៈពេលដូចគ្នា ឆ្នាំ ២០២១ គឺមានការកើនឡើងចំនួន ១៨ ករណី ប្រាក់ពន្ធកើនឡើងចំនួន ១៣៧,៣០ ប៊ីលានរៀល។ បំណុលពន្ធបានបង់ក្នុងរយៈពេល ១២ខែ ឆ្នាំ២០២២ មានចំនួន ៣៨,១៩ ប៊ីលានរៀល ប្រៀបធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ ២០២១ កើនឡើងចំនួន ២៥,៩៤ ប៊ីលានរៀល។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ សំណុំឯកសារនៅសល់ចុងគ្រាសរុបមានចំនួន ៣៤៣ ឯកសារ។

| តារាងទី៣៖ របាយការណ៍ប្រៀបធៀបការទទួលពាក្យបណ្តឹងតវ៉ា រវាងឆ្នាំ២០២១ និងឆ្នាំ២០២២ | | | | |
|---|---|---|---|---|
| សកម្មភាព | ឆ្នាំ២០២១ | ឆ្នាំ២០២២ | ប្រៀបធៀបឆ្នាំ២០២១ | |
| | | | តុល្យភាព | ភាគរយ |
| ការទទួលពាក្យបណ្តឹងតវ៉ាកំពុងដំណើរការ | ១៩៨ | ៥០៧ | ៣០៩ | ១៥៦.០៦% |

ប្រភព៖ អគ្គនាយដ្ឋានពន្ធដារ

# ជំពូកទី៣

# នីតិវិធីនៃការធ្វើសវនកម្មនិងការវិភាគលទ្ធផលរបស់អគ្គនាយដ្ឋានពន្ធដារ

## ៣.១. នីតិវិធីនៃការធ្វើសវនកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ

អនុទ្បោមតាមបទបញ្ញត្តិនៃច្បាប់សារពើពន្ធដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជាណាចក្រកម្ពុជា ប្រកាសលេខ នស.រកម ០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ១៩៩៧ច្បាប់ស្តីពីសារពើពន្ធដែលត្រូវបាន ប្រកាសអោយប្រើដោយព្រះរាជក្រមលេខនសរ/រកម០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែមិនា ឆ្នាំ ២០០៣ និងបទ បញ្ញត្តិពន្ធដារដទៃទៀត សំដៅដល់ការបង្កើតប្រសិទ្ធភាព ភាពត្រឹមត្រូវ តម្លាភាព សមភាព និងជម្រុញអោយ មានការសវនកម្មពន្ធដារដូចខាងក្រោមៈ

- គោលបំណងចំបងនៃការធ្វើសវនកម្មពន្ធដារ គឺដើម្បីអប់រំ ជម្រុញអោយអ្នកជាប់ពន្ធគោរពច្បាប់ បទបញ្ញត្តិស្តីពីពន្ធដារដោយស្ម័គ្រចិត្ត
- ធានាថាការអនុវត្តកាតព្វកិច្ចពន្ធដារក្រោមរបបស្វ័យប្រកាសទទួលបានជោគជ័យក្នុងកម្រិតខ្ពស់ នេះមានន័យថាសវនកម្មពន្ធដារមានភារកិច្ចធ្វើអោយប្រាកដថា ប្រតិបត្តិការអាជីវកម្មត្រូវបាន ប្រកាស ហើយប្រាក់ពន្ធបានបង់ត្រឹមត្រូវតាមច្បាប់ និងបទបញ្ញត្តិស្តីពីពន្ធដារ។

## ៣.២. ការជ្រើសរើសសហគ្រាសធ្វើសវនកម្ម

សវនកម្មពន្ធដារត្រូវធ្វើឡើងតាមនីតិវិធី និងការជ្រើសរើសសហគ្រាសធ្វើសវនកម្ម ធ្វើឡើងដោយផ្អែក លើការវិភាគហានិភ័យ និងព័ត៌មានផ្សេងៗរួមមានៈ

- ការិយាល័យហានិភ័យ
- ព័ត៌មានទទួលបានពីតតីយជន
- វិស័យជាក់លាក់
- បញ្ហាជាក់លាក់ចំពោះប្រភេទពន្ធ ឬអ្នកជាប់ពន្ធណាមួយ
- ទីតាំងរបស់សហគ្រាសជាដើម។

## ៣.៣. ដំណើរការនៃការធ្វើសវនកម្ម

មុនពេលចាប់ផ្តើមសវនកម្មរដ្ឋបាលសារពើពន្ធ ត្រូវជូនដំណឹងស្តីពីការធ្វើសវនកម្មដល់ប្រធានសហគ្រាស ឬតំណាងអ្នកជាប់ពន្ធជាមុន។ លិខិតជូនដំណឹងស្តីពីការធ្វើសវនកម្មពន្ធដារត្រូវចេញដោយប្រធាននាយកដ្ឋាន ឬប្រធានសាខាពន្ធដារ ខេត្ត ខណ្ឌ និងត្រូវបង្ហាញនូវសញ្ញាណដូចខាងក្រោម៖

១ - ការជូនដំណឹងស្តីពីកាធ្វើសវនកម្ម

២ - ការផ្តល់ឯកសារ

៣ - ការធ្វើបទសម្ភាសន៍

៤ - ការត្រួតពិនិត្យឯកសារ

៥ - ការពន្យល់ពីការធ្វេសប្រហែសរកឃើញ

៦ - លិខិតជូនដំណឹងស្តីពីការកំណត់ពន្ធ

៧ - ការតវ៉ាលើការកំណត់ពន្ធ

៨ - ការបង់ប្រាក់ពន្ធ

### ៣.៣.១. ការជូនដំណឹងស្តីពីការធ្វើសវនកម្ម

ការជូនដំណឹងស្តីពីការធ្វើសវនកម្មត្រូវដោយប្រធាននាយកដ្ឋាន ឬប្រធានសាខាពន្ធដារខេត្ត ខណ្ឌ និងត្រូវបង្ហាញពី៖

- កាលបរិច្ឆេទនៃការចុះធ្វើសវនកម្ម
- ការិយបរិច្ឆេទដែលត្រូវចុះធ្វើសវនកម្ម

- ប្រភេទសវនកម្ម (សវនកម្មលើលិខិតស្នាម សវនកម្មមានកម្រិត និងសវនកម្មពេញលេញ)
- ឈ្មោះមន្ត្រីដែលទទួលភារកិច្ចធ្វើសវនកម្ម

ក្នុងករណីដោយមូលហេតុណាមួយ ដែលលិខិតជូនដំណឹងមិនអាចផ្តល់ដល់អ្នកជាប់ពន្ធដូចបាន បរិយាយខាងលើលិខិតជូនដំណឹង ត្រូវបានចាត់ទុកថាបានប្រគល់យ៉ាងត្រឹមត្រូវ ប្រសិនបើរដ្ឋបាលសារពើពន្ធបាន៖

- បិទលិខិតជូនដំណឹងភ្ជាប់ទៅនឹងទ្វារនិវាសនដ្ឋាន ឬទីកន្លែងប្រកបអាជីវកម្មរបស់អ្នកជាប់ពន្ធ
- ផ្សព្វផ្សាយតាមសារព័ត៌មាន ដោយតម្រូវឲ្យអ្នកជាប់ពន្ធចូលមករដ្ឋបាលសារពើពន្ធមិនឲ្យលើសពី ១៥ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទផ្សព្វផ្សាយ។

### ៣.៣.២. ការផ្តល់ឯកសារ

ក្រោយពីបានទទួលលិខិតជូនដំណឹងស្តីពីការចុះធ្វើសវនកម្ម អ្នកជាប់ពន្ធត្រូវត្រៀមឯកសារដែលពាក់ព័ន្ធ ទាំងអស់ដើម្បីផ្តល់ឲ្យសវនករពន្ធដារតាមការស្នើ។ ជាមួយគ្នានេះដែរ អ្នកជាប់ពន្ធគួរធ្វើការពិនិត្យលើលិខិតប្រកាសពន្ធ និងឯកសារពាក់ព័ន្ធរបស់ខ្លួន។

អ្នកជាប់ពន្ធត្រូវផ្តល់ឯកសារជូនសវនករពន្ធដារយ៉ាងយឺតបំផុតត្រឹម៖

- ៧ថ្ងៃក្រោយការស្នើសុំចំពោះការធ្វើសវនកម្មពេញលេញ ឬសវនកម្មមានកម្រិត
- ១៥ថ្ងៃក្រោយទទួលបានលិខិតជូនដំណឹងចំពោះការធ្វើសវនកម្មលើលិខិតស្នាម ការខកខានមិនបានផ្តល់ឯកសារដែលបានស្នើសុំសវនករពន្ធដារ អាចនឹងធ្វើការកំណត់ពន្ធដោយផ្អែកលើព័ត៌មានដែលសវនករពន្ធដារមាន។

### ៣.៣.៣. ការផ្តល់បទសម្ភាសន៍

ការធ្វើបទសម្ភាសន៍គឺដើម្បីផ្តល់ឱកាសដល់សវនករពន្ធដារជួបផ្ទាល់ជាមួយអ្នកជាប់ពន្ធ ឬតំណាងអ្នកជាប់ពន្ធដែលមានការយល់ដឹងច្បាស់លាស់អំពីសកម្មភាពអាជីវកម្មរបស់អ្នកជាប់ពន្ធដើម្បីស្វែងយល់ពីទិដ្ឋភាពទូទៅនៃអាជីវកម្មរបស់សហគ្រាស។ អ្នកជាប់ពន្ធ ឬអ្នកតំណាងនឹងត្រូវបានសុំឱ្យពន្យល់ពីសកម្មភាពអាជីវកម្ម ការកត់ត្រាបញ្ជីកាគណនេយ្យ និងប្រព័ន្ធនៃការកត់ត្រាទិន្នន័យរបស់សហគ្រាស។ ក្នុងដំណើរការសវនកម្ម អ្នកដែលទទួលបន្ទុកតាមផ្នែកនីមួយៗនៃប្រតិបត្តិការអាជីវកម្ម ត្រូវទទួលការធ្វើបទសម្ភាសន៍តាមការតម្រូវរបស់សវនករពន្ធដារ។ ក្រោយពីការធ្វើបទសម្ភាសន៍ចប់សវនករពន្ធដារ ត្រូវមានកំណត់ហេតុបឋមមួយជាមួយអ្នកជាប់ពន្ធ ឬតំណាងអ្នកជាប់ពន្ធ។

### ៣.៣.៤. ការត្រួតពិនិត្យឯកសារ

យោងតាមច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធត្រូវកាន់កត់ត្រា និងរក្សាទុកបញ្ជីលិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុផ្សេងៗដូចដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានកំណត់ និងត្រូវដាក់បញ្ជី និងឯកសារទាំងនោះតាមការតម្រូវជូនរដ្ឋបាលសារពើពន្ធដើម្បីពិនិត្យ។ សហគ្រាសត្រូវរក្សាទុកបញ្ជីគណនេយ្យ ទិនានុប្បវត្តិនិងឯកសារនានាដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារឬបទប្បញ្ញត្តិដទៃក្នុងរយៈពេល១០ឆ្នាំគិតពីដំណាច់ឆ្នាំជាប់ពន្ធចរន្ត។ មិនត្រឹមតឯកសារដូចរៀបរាប់ខាងលើនោះទេ មាត្រា៩៨នៃច្បាប់ស្តីពីសារពើពន្ធ តម្រូវឱ្យសហគ្រាសផ្តល់នូវឯកសារមួយចំនួនដូចខាងក្រោមសម្រាប់សវនករបន្ថែមទៀតដែលមានជាអាទិ៍៖

- ព័ត៌មានរបស់សហគ្រាស (វិញ្ញាបនប័ត្រចុះបញ្ជីក្រុមហ៊ុន វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម)
- លក្ខន្តិកៈក្រុមហ៊ុន និងវិញ្ញាបនប័ត្រផ្សេងៗ
- របាយការណ៍គណនេយ្យ (របាយការណ៍ចលនាសាច់ប្រាក់ តារាងតុល្យការងារ បញ្ជីទ្រព្យសកម្ម បញ្ជីបំណុល របាយការណ៍ចំណេញ ឬខាត)
- ឯកសារផ្សេងៗ (តារាងបើកប្រាក់បៀវត្សកម្មករនិយោជិត កិច្ចសន្យាការងារជនបរទេស កិច្ចសន្យាជួល លក់ លិខិតប្រកាសពន្ធប្រចាំខែ ប្រចាំឆ្នាំ តារាងកែតម្រូវការគណនាប្រាក់ពន្ធ)

### ៣.៣.៥. ការពន្យល់ពីលទ្ធផលធ្វើសវនកម្ម

ក្រោយពីការបញ្ចប់ការត្រួតពិនិត្យឯកសារ សវនករពន្ធដារត្រូវរៀបចំសេចក្តីព្រាងរបាយការណ៍លទ្ធផលសវនកម្ម ដោយត្រូវពិភាក្សាជាមួយអ្នកជាប់ពន្ធអំពី៖

- បញ្ហាដែលរកឃើញ
- មូលហេតុ និងបទប្បញ្ញត្តិពន្ធដារពាក់ព័ន្ធដែលជាមូលដ្ឋានក្នុងការកំណត់ពន្ធ
- ប្រាក់ពន្ធដែលនឹងត្រូវកំណត់ឡើងវិញ។ក្នុងនោះផងដែរអ្នកជាប់ពន្ធអាចធ្វើការបញ្ចេញមតិយោបល់ឬជំទាស់លើសេចក្តីព្រាងរបាយការណ៍ លទ្ធផលសវនកម្មដូចចំណុចខាងលើទាំង៣នេះ ដោយត្រូវបង្ហាញឯកសារបន្ថែមដែលគាំទ្រាការជំទាស់របស់ខ្លួន។ ល្គឹកណាដែលការជំទាស់របស់អ្នកជាប់ពន្ធលើសេចក្តីព្រាងរបាយការណ៍លទ្ធផលសវនកម្ម មិនមានមូលដ្ឋាន និងភ័ស្តុតាងគាំទ្រសវនករនឹងជូនដំណឹងផ្ទាល់មាត់ពីការមិនឯកភាពចំពោះការជំទាស់ របស់អ្នកជាប់ពន្ធ។

### ៣.៣.៦. នីតិវិធីនៃការកំណត់ពន្ធឡើងវិញ

ផ្អែកតាមប្រកាសលេខ០៧៣ប្រក.សហវ.ព ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៩៨ ស្តីពីការកំណត់ពន្ធឡើងវិញ និងការប្រមូលពន្ធរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងច្បាប់ស្តីពីសារពើពន្ធ ការកំណត់ពន្ធត្រូវបានបែងចែកជា៖

ក. ការកំណត់ពន្ធដោយជាឯកតោភាគី៖ រដ្ឋបាលសារពើពន្ធអាចធ្វើការកំណត់ពន្ធជាឯកតោភាគីក្នុងករណីដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក៖

- មិនបានដាក់លិខិតប្រកាសសារពើពន្ធតាមតម្រូវនៃច្បាប់
- មិនបានធ្វើការចុះបញ្ជី
- មិនបានកាន់កាប់ កត់ត្រារក្សាទុកបានត្រឹមត្រូវនូវបញ្ជីការគណនេយ្យ ឯកសារផ្សេងៗទៀតទៅតាមការតម្រូវ
- មិនបានផ្តល់ព័ត៌មានចាំបាច់ជូនរដ្ឋបាលសារពើពន្ធដើម្បីកំណត់ពន្ធឱ្យបានត្រឹមត្រូវក្នុងរយៈពេល៣០ថ្ងៃក្រោយការិយបរិច្ឆេទប្រគល់លិខិតរបស់រដ្ឋបាលសារពើពន្ធ ស្នើសុំឱ្យអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកឆ្លើយតបឬផ្តល់លិខិតយុត្តិការបញ្ជាក់លើចំណុចណាមួយនៃលិខិតប្រកាសសារពើពន្ធ
- រដ្ឋបាលសារពើពន្ធអាចធ្វើការកំណត់ពន្ធជាឯកតោភាគីក្នុងរយៈពេល១០ឆ្នាំក្រោយកាលបរិច្ឆេទដែលតម្រូវឱ្យលិខិតប្រកាសសារពើពន្ធប្រសិនបើមានភ័ស្តុតាងបញ្ជាក់ថាមានអំពើរាំងស្ទះដល់ការអនុវត្តន៍បទបញ្ញត្តិស្តីពីសារពើពន្ធ
- ក្នុងករណីដែលអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកមិនបានបំពេញកាតព្វកិច្ចតាមការតម្រូវនៃច្បាប់សារពើពន្ធដែលជាហេតុបណ្តាលឱ្យមានការកំណត់ពន្ធជាឯកតោភាគីការមិនបានបំពេញកាតព្វកិច្ចនេះត្រូវចាត់ទុកថាមានលក្ខណៈធ្ងន់ធ្ងរធ្វើឲ្យការប្រមូលពន្ធអាចជួបឧបសគ្គ។ក្នុងករណីនេះប្រាក់ពន្ធត្រូវដល់កំណត់ និងត្រូវបង់ក្នុងរយៈពេល៣ថ្ងៃ ក្រោយកាលបរិច្ឆេទប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធ។

ខ. ការកំណត់ពន្ធឡើងវិញ៖ អនុវត្តចំពោះអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកដែលត្រូវបានដាក់លិខិតប្រកាសពន្ធការកំណត់ពន្ធឡើងវិញអាចត្រូវធ្វើឡើងក្នុងករណីដែលរដ្ឋបាលសារពើពន្ធកំណត់ថាព័ត៌មានសម្រាប់កំណត់ឱ្យបានត្រឹមត្រូវនូវប្រាក់ពន្ធ ដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីសារពើពន្ធមានលក្ខណៈមិនគ្រប់គ្រាន់មិនត្រឹមត្រូវ ឬមានការភ្លាំងភ្លេច ដែលនាំឱ្យប្រាក់ពន្ធត្រូវបង់បានបង់មានចំនួនតិចជាងប្រាក់ពន្ធដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីសារពើពន្ធ។ រយៈពេលនៃការកំណត់ពន្ធឡើងវិញគឺ៖

- រដ្ឋបាលសារពើពន្ធអាចធ្វើការកំណត់ពន្ធឡើងវិញក្នុងរយៈពេលបីឆ្នាំបន្ទាប់ពីឆ្នាំប្រតិទិនដែលការកាត់ទុកបានកើតឡើង
- ក្នុងរយៈពេលបីឆ្នាំ ក្រោយថ្ងៃដាក់លិខិតប្រកាសសារពើពន្ធ
- ក្នុងរយៈពេលប១០ឆ្នាំក្រោយកាលបរិច្ឆេទដែលតម្រូវឱ្យដាក់លិខិតប្រកាសសារពើពន្ធប្រសិនបើមានភស្តុតាងបញ្ជាក់ថាមានអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីសារពើពន្ធ
- ក្នុងរយៈពេលណាមួយក៏បាន តាមការយល់ព្រមជាលាយលក្ខអក្សររបស់អ្នកជាប់ពន្ធ

### ៣.៣.៧. លិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញ

ក្រោយពីធ្វើការកំណត់ពន្ធ និងការកំណត់ពន្ធឡើងវិញ សវនករពន្ធដារត្រូវប្រគល់លិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញឱ្យអ្នកជាប់ពន្ធ។ យោងតាមមាត្រា ១១៨ កថាខណ្ឌទី២ នៃច្បាប់ស្តីពីសារពើពន្ធ អង្គភាពពន្ធដារដែលទទួលបន្ទុកធ្វើការកំណត់ពន្ធ ឬកំណត់ពន្ធឡើងវិញនោះ។ ក្នុងរយៈពេលនេះ អ្នកជាប់ពន្ធអាចទទួលយក ឬជំទាស់ចំពោះការកំណត់ពន្ធឡើងវិញ។ អ្នកជាប់ពន្ធត្រូវចាត់ទុកថាយល់ព្រមចំពោះការកំណត់ពន្ធ ឬកំណត់ពន្ធឡើងវិញបើសិនជាពុំបានឆ្លើយតបក្នុងថេរវេលានេះ។

### ៣.៣.៨. ការតវ៉ាចំពោះការកំណត់ពន្ធឡើងវិញ

អ្នកជាប់ពន្ធដែលមិនយល់ស្របនូវចំណែកណាមួយឬទាំងស្រុងនៃការកំណត់ពន្ធដែលបានតវ៉ាទៅអង្គភាពកំណត់ពន្ធដារមានចែង ក្នុងកថាខណ្ឌ៣នៃប្រការ១៥នៃប្រកាស មានសិទ្ធិតវ៉ាជាលាយលក្ខណ៍អក្សរទៅអគ្គនាយកដ្ឋានពន្ធក្នុងកំឡុងពេល៣០ថ្ងៃ ក្រោយទទួលបានលិខិតជូនដំណឹងទារបំណុលពន្ធ ដោយភ្ជាប់មកជាមួយនូវលិខិតដែលបានតវ៉ាទៅអង្គភាពកំណត់ពន្ធ និងភ័ស្តុតាងនានាដែលបានបញ្ជាក់ថាការកំណត់ពន្ធមិនត្រឹមត្រូវ។ វិធាននិងនីតិវិធីនៃការតវ៉ាត្រូវអនុវត្តតាមខ្លឹមសារ នៃប្រកាសលេខ១៤៧០សហវ.ប្រក ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីវិធាន និងនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាពន្ធដារ។

### ៣.៣.៩. ពន្ធបន្ថែម និងការប្រាក់

ចំពោះការកំណត់ពន្ធឡើងវិញ ពន្ធបន្ថែម និងការប្រាក់ត្រូវបានកំណត់ដូចខាងក្រោម៖

- ពន្ធបន្ថែម ១០% និងបូកបន្ថែមការប្រាក់ ១.៥% ក្នុង១ខែ អនុវត្តទៅលើ៖
  - ការធ្វេសប្រហែសដោយប្រកាសនៃខែប្រាក់ពន្ធដែលបានបង់ខ្វះ
  - បង់ប្រាក់ពន្ធខ្វះតិចជាងឬស្មើ១០% នៃប្រាក់ពន្ធដែលត្រូវបង់តាមច្បាប់កំណត់
- ពន្ធបន្ថែម ២៥% និង ការប្រាក់ ១.៥% ក្នុង១ខែ អនុវត្តទៅលើ៖
  - ការធ្វេសប្រហែសធ្ងន់ធ្ងរដោយប្រកាសនៃខែប្រាក់ពន្ធដែលបានបង់ខ្វះ
  - បង់ប្រាក់ពន្ធខ្វះច្រើនជាង១០% នៃប្រាក់ពន្ធដែលត្រូវបង់តាមច្បាប់កំណត់
- ពន្ធបន្ថែម ៤០% និង ការប្រាក់ ១.៥% ក្នុង១ខែ អនុវត្តទៅលើ៖
  - ករណីដែលអ្នកជាប់ពន្ធគ្មានបញ្ជីកាគណនេយ្យឬកាន់កាប់បញ្ជីកាគណនេយ្យក្លែងបន្លំ
  - មិនសហការផ្តល់ឯកសារនានាទាក់ទិននឹងការធ្វើសវនកម្ម

### ៣.៣.១០.ការបង់ប្រាក់ពន្ធ

យោងតាមមាត្រា៩១ កថាខណ្ឌទី២ នៃច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធត្រូវបង់ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់ផ្សេងៗក្នុងរយៈពេល ៣០ថ្ងៃ ក្រោយទទួលបានលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធ ឬការកំណត់ពន្ធឡើងវិញ។

### ៣.៣.១១.ការទូទាត់បំណុលពន្ធ

ក្នុងករណីអ្នកជាប់ពន្ធពុំមានលទ្ធភាពទូទាត់បំណុលបានគ្រប់ចំនួនភ្លាមៗ អ្នកជាប់ពន្ធអាចទូទាត់បំណុលពន្ធតាមវិធីដូចខាងក្រោម៖[៣២]

- ធ្វើការទូទាត់បំណុលពន្ធអោយបានគ្រប់ចំនួនក្នុងពេលតែមួយលើក
- ធ្វើការទូទាត់បំណុលពន្ធជាដំណាក់កាលក្នុងករណីអ្នកជាប់ពន្ធពុំមានលទ្ធភាពទូទាត់បំណុលពន្ធបាន
- គ្រប់ចំនួនក្នុងពេលតែមួយលើកព្រមទាំងទទួលបានការអនុញ្ញាតពីអគ្គនាយដ្ឋានពន្ធដារតាមរយៈកិច្ចព្រមព្រៀងទូតទាត់ដំណាក់កាល
- ធ្វើការទូទាត់បំណុលពន្ធតែប្រភេទពន្ធ ពន្ធបន្ថែម ការប្រាក់យឺតយ៉ាវដែលបានយល់ស្រប ដោយរក្សាទុកប្រភេទពន្ធ ពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវ ដែលមិនយល់ស្របដើម្បីធ្វើកាតវ៉ា
- ធ្វើការទូទាត់បំណុលពន្ធតាមចំណែកភាគហ៊ុនរបស់រូបវន្តបុគ្គលណាម្នាក់ជាម្ចាស់ភាគហ៊ុនដែលទទួលខុសត្រូវតាមចំនួនសមាមាត្រភាគហ៊ុនដូចមានចែងក្នុងលក្ខន្តិកៈក្រុមហ៊ុន ក្នុងករណីដែលម្ចាស់ភាគហ៊ុនមានបំណងធ្វើការទូទាត់បំណុលពន្ធតែលើចំណែកបំណុលពន្ធរបស់ខ្លួន តាមរយៈសំណើសុំរបស់ម្ចាស់ហ៊ុន ព្រមទាំងទទួលបានការអនុញ្ញាតិពីអគ្គនាយដ្ឋានពន្ធដារ។

[៣២]ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការគ្រប់គ្រងបំណុលពន្ធដារ, លេខ៩៦២ សហវ. ប្រក, ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ២០២០ ,ប្រការ៦

## ៤.១. ចំណុចខ្លាំងនៃការធ្វើសវនកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើនីតិវិធីសវនកម្ម របស់អគ្គនាយកដ្ឋានពន្ធដារ និងការតវ៉ាលើការកំណត់ពន្ធ របស់អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចមកយើងបានរកឃើញនូវចំណុចខ្លាំងក្នុងការធ្វើសវនកម្មសារពើពន្ធមួយចំនួនដូចជាៈ

- មានមូលដ្ឋានច្បាស់លាស់ក្នុងការធ្វើសវនកម្មនៅតាសហគ្រាស
- មាននីតិវិធីជាក់លាក់សមស្របទៅតាមប្រភេទនៃសវនកម្មហើយក៏ស្របទៅតាមការចង់បានសំណាក់អ្នកជាប់ពន្ធ
- មានច្បាប់បទបញ្ញត្តិ បទដ្ឋានគតិយុទ្ធគ្រប់គ្រាន់សម្រាប់ជួយគាំទ្រដល់ការធ្វើសវនកម្ម
- មានចែងពីនីតិវិធី និងបែបបទដាក់ពាក្យបណ្តឹងតវ៉ា ក្នុងករណីដែលអ្នកជាប់ពន្ធមិនយល់ស្របតាមអ្វីដែលអ្នកជាប់ពន្ធបានកំណត់
- មន្ត្រីសវនកម្មទទួកបានបណ្តុះបណ្តាលនិងទទួលបានចំណេះដឹងថ្មីៗដែលអាចមានសមត្ថភាពចាប់កំហុសអ្នកជាប់ពន្ធជាងមុន។
- មានយន្តការរឹងមាំដើម្បីចាប់កំហុសអ្នកជាប់ពន្ធឱ្យមកដោះស្រាយជាមួយរដ្ឋបាលសារពើពន្ធក្នុងករណីមន្ត្រីសវនកររកឃើញកំហុសឆ្គងរបស់អ្នកជាប់ពន្ធ
- ទទួលបានការលើកទឹកចិត្តជាប្រាក់រង្វាន់ នៅក្រោយពេលសវនកម្ម ក្នុងករណីដែលមន្ត្រីអាចរកឃើញកំហុសនានា ហើយសហគ្រាសព្រមបង់នូវប្រាក់ពន្ធដែលត្រូវបានពិន័យ
- មានកិច្ចសហការជាមួយមន្ត្រីក្នុងអង្គភាព និងនិងស្ថាប័នពាក់ពន្ធមួយចំនួន។

## ៤.២. ចំណុចខ្សោយនៃការអនុវត្តន៍សវនកម្ម

ទន្ទឹមនឹងការរកឃើញនូវចំណុចខ្លាំងមួយចំនួនខាងលើ ទៅលើនីតិវីធីសវនកម្មសារពើពន្ធនេះ យើងក៏បានរកឃើញនូវចំណុចអសកម្មមួយចំនួនផងដែរ ដែលបានរារាំងដល់ការធ្វើសវនកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ។ ចំណុចខ្សោយទាំងទាំងនោះគឺមានដូចខាងក្រោមៈ

- នីតិវីធីសវនកម្មមួយចំនួនមានលក្ខណសាំញាំនិងស្មុគស្មាញពេកដែលធ្វើឱ្យអ្នកជាប់ពន្ធមួយចំនួនមិនសប្បាយចិត្ត និងមិនចង់សហការ
- ទោះជាមានច្បាប់ បទបញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តិគ្រប់គ្រាន់ក៏ដោយ ក៏ការអនុវត្តនៅតែមានភាពខ្វះចន្លោះ

- មន្ត្រីសវនកម្មមួយចំនួននៅមានកម្រិតទាប ជាពិសេសពាក់ព័ន្ធនិងជំនាញគណនេយ្យ និងព័ត៌មានវិជ្ជា ដែលកំពុងតែមានការវិវត្តន៍ជារៀងរាល់ថ្ងៃ
- មិនទាន់ទទួលបានកិច្ចសហការល្អស្ថាប័ពាក់ព័ន្ធផ្សេងៗ
- អ្នកជាប់ពន្ធមួយចំនួនមិនអាចមានការយល់ដឹងពីច្បាប់ពន្ធជាហេតុធ្វើឲ្យពួកគាត់មិនបានផ្តល់កិច្ចសហការជាមួយមន្ត្រីសវនកម្ម
- ចំនួនមន្ត្រីមានតិចធៀបទៅនឹងសហគ្រាសដែលមានច្រើន និងកំពុងតែបង្កើតថ្មីបន្ថែមជារៀងរាល់ថ្ងៃ។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១.សេចក្តីសន្និដ្ឋាន

តាមរយៈការសិក្សាស្រាវជ្រាវទៅប្រធានបទ នីតិវិធីសវនកម្មសារពើពន្ធរួចមកធ្វើឱ្យយើងអាចសន្និដ្ឋានបានថា ការធ្វើសវនកម្មសារពើពន្ធគឺជាយុទ្ធសាស្ត្រដ៏សំខាន់មួយក្នុងការបង្កើតនូវចំណូលថវិការសម្រាប់ទ្រទ្រង់ប្រទេសជាតិ ហើយសម្រាប់បង្កឱ្យអ្នកជាប់ពន្ធគោរពច្បាប់ និងបទបញ្ញត្តិស្តីពីពន្ធដារឱ្យមានប្រសិទ្ធភាព និងតម្លាភាព។ ទោះជាយ៉ាងណាក៏ដោយច្បាប់សារពើពន្ធ និងបទបញ្ញត្តិពាក់ព័ន្ធ គឺបានចែងមិនបានគ្រប់ជ្រុងជ្រោយនៅឡើយនោះពោលគឺនៅភាពខ្វះចន្លោះមួយចំនួនទៀតដែលត្រូវបំពេញបន្ថែម។ អ្នកជាប់ពន្ធនៅមានការយល់ដឹងតិចតួចនៅឡើយពីកាតព្វកិច្ចសារពើពន្ធ។ សរុបមកក្នុងការិយបរិច្ឆេទនេះ ការបំពេញកាតព្វកិច្ចពីសំណាក់អ្នកជាប់ពន្ធកាន់តែប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំតាមរយៈការកែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារដោយបញ្ជៀសវប្បធម៌បង់ពន្ធឲ្យបានកាន់តែទូលំទូលាយ។ ចំណែកនីតិវិធីនៃការធ្វើសវនកម្មត្រូវបានកែលម្អហើយមន្ត្រីសវនកម្មក៏បានកែប្រែអត្តចរិតរបស់ខ្លួនព្រមទាំងបានពង្រឹងសមត្ថភាពរបស់ខ្លួនឱ្យកាន់តែប្រសើរជាងមុន។

## ២.ការផ្តល់អនុសាសន៍

ក្រោយពីបានពិភាក្សាទៅលើលទ្ធផលនៃការស្រាវជ្រាវ ដោយមានចំណុចខ្លាំង និងចំណុចខ្សោយ យើងសូមផ្តល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

- កិច្ចប្រតិបត្តិការសវនកម្មត្រួតពិនិត្យការកំណត់ពន្ធឡើងវិញ ត្រូវតែធ្វើឡើងដោយឥតឈប់ឈរ
- បង្កើតនូវកម្មវិធីបណ្តុះបណ្តាលសវនកម្មពន្ធដារផ្នែកសវនកម្មឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀតដោយធ្វើឡើងតាមរយៈវគ្គបណ្តុះបណ្តាលខ្លីតាមរយៈសិក្ខាសាលានិងតាមរយៈការបញ្ជូនសវនករពន្ធដារទៅសិក្សានៅក្រៅប្រទេស។
- ពង្រឹងនិងលម្អអភិបាលកិច្ចកាន់តែមានប្រសិទ្ធភាពខ្ពស់ដោយផ្តល់នូវការលើកទឹកចិត្តដល់មន្ត្រីពន្ធដារដែលស្នាដៃ
- បណ្តុះផ្នត់គំនិតអ្នកជាប់ពន្ធតាមរយៈការផ្សព្វផ្សាយតាមបណ្តាលសារព័ត៌មានតាមការធ្វើបទម្កាសន៍ខ្លីៗនិងតាមគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារដើម្បីឱ្យអ្នកជាប់ពន្ធយល់ច្បាស់ពីច្បាប់ពន្ធដារ និងយល់ពីការបំពេញកាតព្វកិច្ចសារពើពន្ធថាជាកាតព្វកិច្ចរបស់អ្នកជាប់ពន្ធទាំងអស់ ធ្វើយ៉ាងនេះដើម្បីបង្កើនកាត់បន្ថយការគេចវេះពន្ធការបន្លំពន្ធ និងការមិនមកប្រកាសពន្ធ
- ជ្រើសរើសមន្ត្រីដែលមានសមត្ថភាពបន្ថែមទៀតដើម្បីបង្កើនការធ្វើសវនកម្ម

- ត្រូវរៀបចំផែនការសកម្មភាព និងកម្មវិធីការងារសវនកម្មឱ្យបានច្បាស់លាស់ ដើម្បីងាយស្រួលចាត់ចែងដាក់ឱ្យមន្ត្រីក្រោមឱវាទអនុវត្តដោយតម្លាភាព ស៊ីចង្វាក់ និងប្រទាក់ក្រឡាគ្នាសំដៅធានានូវប្រសិទ្ធភាពនៃការប្រមូលពន្ធ និងការធ្វើវិចារណកម្មប្រព័ន្ធលើកទឹកចិត្តមន្ត្រីពន្ធដារ
- ជំរុញការអនុវត្តន៍ផែនការយុទ្ធសាស្ត្រដោយប្រើបច្ចេកវិជ្ជាព័ត៌មានវិទ្យាជាពិសេសការធ្វើសវនកម្មនិងការត្រួតពិនិត្យប្រទាក់ក្រលាគ្នា
- ជំរុញបណ្តុះបណ្តាល និងបង្កើតសមត្ថភាពវិជ្ជាជីវៈ និងក្រមសីលធម៌របស់មន្ត្រីពន្ធដារដើម្បីពង្រឹងស្ថាប័នឱ្យបានរឹងមាំក្នុងគោលដៅគ្រប់គ្រងឱ្យបានល្អនូវស្ថិតិរបស់អ្នកបង់ពន្ធដែលមានកម្រិតត្រឹមត្រូវខ្ពស់ និងអ្នកបង់ពន្ធទាបជាងនេះ
- អនុវត្តន៍សីលធម៌ កែលម្អស្ថាប័នប្រព័ន្ធការងារការគ្រប់គ្រងការងារ និងរបៀបធ្វើការរបស់មន្ត្រីពន្ធដារតាមរយៈការផ្លាស់ប្តូរផ្នត់គំនិតពីមន្ត្រីគ្រប់គ្រងមកជាមន្ត្រីបំរើសេវាកម្មសាធារណៈវិញ។

# គន្ថនិទ្ទេស

១.ច្បាប់ស្តីពីពន្ធដារប្រកាសឲ្យប្រើដោយព្រះរាជក្រម នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

២.អនុក្រឹត្យ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាការរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អោយទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករគយកម្ពុជា អគ្គនាយដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ១៣៤ អនក្រ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨

៣.ប្រកាសស្តី ពីវិធាននិងនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាពន្ធដារនៅអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ,លេខ១៤៧០ សហវ.ប្រក ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៦

៤.គេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh

៥. ឯកសារបទបង្ហាញស្តីពីសេចក្តីផ្តើមនៃការយកពន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់កម្ពុជា របស់សាលាជាតិពន្ធដារ

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ...២៧០...សហវ.ប្រក

# ប្រកាស
# ស្ដីពី
# សវនកម្មពន្ធដារ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងធ្វើឱ្យប្រសើរឡើងនូវនីតិវិធីនៃការធ្វើសវនកម្ម ដើម្បីធានានូវតម្លាភាពក្នុងការបង់ពន្ធ និងបង្កើនបរិយាកាសប្រកួតប្រជែងដោយស្មើភាពក្នុងការប្រកបអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.- គោលដៅ**

ប្រកាសនេះ មានគោលដៅកំណត់នូវវិធាននិងនីតិវិធី ព្រមទាំងសិទ្ធិនិងកាតព្វកិច្ចរបស់រដ្ឋបាលសារពើពន្ធនិងអ្នកជាប់ពន្ធ ពាក់ព័ន្ធនឹងការធ្វើសវនកម្មពន្ធដារ។

**ប្រការ៣.- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តលើអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.- និយមន័យ**

សវនកម្មពន្ធដារ សំដៅដល់ការពិនិត្យបញ្ជាក់លើបញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់អ្នកជាប់ពន្ធ ដើម្បីបញ្ជាក់ថាការគណនា ការប្រកាស និងការបង់ប្រាក់ពន្ធ បានត្រឹមត្រូវតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ។ សវនកម្មពន្ធដារគឺជាវិធានការដ៏សំខាន់ក្នុងការគ្រប់គ្រង និងប្រមូលពន្ធឱ្យមានតម្លាភាព និងប្រសិទ្ធភាព ដើម្បីធានាសមធម៌ក្នុងការបង់ពន្ធ។

**ប្រការ៥.- សវនកម្មលើលិខិតស្នាម**

សវនកម្មលើលិខិតស្នាមត្រូវបានធ្វើឡើងនៅទីកន្លែងរដ្ឋបាលសារពើពន្ធ។ ការធ្វើសវនកម្មលើលិខិតស្នាម គឺជាការពិនិត្យវិនិច្ឆ័យលើលិខិតប្រកាសសារពើពន្ធ ដែលមានភាពមិនប្រក្រតី ឬភាពមិនស៊ីសង្វាក់គ្នារវាងលិខិតប្រកាសសារពើពន្ធ ដើម្បីធានាបាននូវភាពត្រឹមត្រូវក្នុងការប្រកាសបង់ពន្ធរបស់អ្នកជាប់ពន្ធ។ ជាទូទៅសវនកម្មនេះ ត្រូវផ្តោតសំខាន់ទៅលើចំណុចមិនប្រក្រតីច្បាស់លាស់និងងាយស្រួលដោះស្រាយដែលបានរកឃើញលើលិខិតប្រកាសសារពើពន្ធ ដូចជាការផ្ទៀងផ្ទាត់លិខិតប្រកាសពន្ធជាមួយនឹងព័ត៌មានដែលរដ្ឋបាលសារពើពន្ធទទួលបានពីប្រភពផ្សេងៗជាដើម។ ក្នុងនោះរដ្ឋបាលសារពើពន្ធអាចអញ្ជើញអ្នកជាប់ពន្ធមកបំភ្លឺនិងបង្ហាញឯកសារទាក់ទិននឹងភាពមិនប្រក្រតីដែលបានរកឃើញលើលិខិតប្រកាសសារពើពន្ធ។ ក្នុងករណីដែលហានិភ័យទាំងឡាយដែលរកឃើញមានលក្ខណៈស្មុគស្មាញជាប្រព័ន្ធ ឬមានហានិភ័យខ្ពស់ ការធ្វើសវនកម្មលើលិខិតស្នាមត្រូវបញ្ឈប់និងផ្ទេរទៅជាការធ្វើសវនកម្មដល់ទីកន្លែងវិញ។ សវនកម្មប្រភេទនេះ ត្រូវធ្វើក្នុងអំឡុងពេល ១២ ខែ ក្រោយថ្ងៃដាក់លិខិតប្រកាសសារពើពន្ធ។

**ប្រការ៦.- សវនកម្មដល់ទីកន្លែង**

សវនកម្មដល់ទីកន្លែង គឺជាការចុះធ្វើសវនកម្មដល់ទីតាំងប្រកបអាជីវកម្មរបស់សហគ្រាសដែលជាកម្មវត្ថុនៃការធ្វើសវនកម្ម ដើម្បីពិនិត្យស្ថានភាពអាជីវកម្មជាក់ស្តែង បញ្ជីគណនេយ្យ លិខិតយុត្តិការ និងឯកសារផ្សេងៗ។ សវនកម្មនេះរួមមាន÷

១- សវនកម្មមានកម្រិត÷ គឺជាការធ្វើសវនកម្មរយៈពេលខ្លីនិងភ្លាមៗទៅលើប្រភេទពន្ធអាករមួយចំនួន ជាអាទិ៍មាន អាករពិសេសលើទំនិញនិងសេវាមួយចំនួន អាករសម្រាប់បំភ្លឺសាធារណៈ អាករលើតម្លៃបន្ថែមរួមទាំងការបង្វិលសង និង ពន្ធអាករផ្សេងទៀតវៀរលែងតែពន្ធលើប្រាក់ចំណូល ដោយពិនិត្យទៅលើចំណុចដែលជាហានិភ័យទាំងឡាយក្នុងបញ្ជី គណនេយ្យ និងឯកសារពាក់ព័ន្ធ។ សវនកម្មនេះអាចធ្វើឡើងចំពោះតែរយៈពេលជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធចរន្ត (N) និងឆ្នាំ ជាប់ពន្ធមុនឆ្នាំជាប់ពន្ធចរន្ត (N-1)។

២- សវនកម្មពេញលេញ÷ គឺជាការធ្វើសវនកម្មលើពន្ធអាករគ្រប់ប្រភេទ និងវាយតម្លៃលើការកាន់កាប់បញ្ជីគណនេយ្យ របស់សហគ្រាស ដោយត្រូវធ្វើការត្រួតពិនិត្យជាក់ស្តែងលើប្រតិបត្តិការអាជីវកម្ម ផ្ទៀងផ្ទាត់ទៅនឹងបញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ ឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងអាជីវកម្ម ដើម្បីធានាថាសហគ្រាសបានរៀបចំរបាយការណ៍ គណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុបានត្រឹមត្រូវតាមច្បាប់ជាធរមាន និងបានបំពេញកាតព្វកិច្ចបង់ពន្ធត្រឹមត្រូវតាម ច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ។ សវនកម្មនេះអាចធ្វើឡើងក្នុងរង្វង់៣ឆ្នាំជាប់ពន្ធថយក្រោយ (N-3) ប៉ុណ្ណោះ។ ក្នុងករណី មានភស្តុតាងច្បាស់លាស់អំពីការគេចវេះពន្ធ ឬមានការយោងការខាតបង់ ឬមានឥណទានយោងពីឆ្នាំជាប់ពន្ធឬរយៈពេល ជាប់ពន្ធមុន ដែលតម្រូវឱ្យមានការធ្វើសវនកម្មពេញលេញលើសពី៣ឆ្នាំជាប់ពន្ធថយក្រោយ សវនកម្មពេញលេញអាច ធ្វើឡើងក្នុងរង្វង់៥ឆ្នាំជាប់ពន្ធថយក្រោយ។ ក្នុងករណីចាំបាច់និងមានភស្តុតាងច្បាស់លាស់អំពីការគេចវេះពន្ធ ដែលតម្រូវឱ្យ មានការធ្វើសវនកម្មពេញលេញលើសពី៥ឆ្នាំជាប់ពន្ធថយក្រោយ សវនកម្មពេញលេញអាចធ្វើឡើងស្របតាមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីសារពើពន្ធ ដោយត្រូវស្នើសុំការអនុញ្ញាតធ្វើសវនកម្មជាមុនពីរដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើករណី ជាក់ស្តែងនីមួយៗ។

៣- វៀរលែងតែក្នុងករណីមានភស្តុតាងច្បាស់លាស់ មូលដ្ឋានគិតពន្ធតែមួយ ប្រភេទពន្ធតែមួយ ដែលបានធ្វើការ កំណត់ពន្ធរួចហើយមិនត្រូវជាកម្មវត្ថុនៃការធ្វើសវនកម្មជាថ្មីម្តងទៀតទេ។

៤- វៀរលែងតែក្នុងករណីដូចខាងក្រោម ការធ្វើសវនកម្មដូចមានចែងក្នុងប្រការនេះ មិនតម្រូវឱ្យធ្វើលើគ្រប់ឆ្នាំជាប់ ពន្ធឬរយៈពេលជាប់ពន្ធទេ គឺត្រូវធ្វើឡើងតែចំពោះឆ្នាំជាប់ពន្ធឬរយៈពេលជាប់ពន្ធណាដែលមានហានិភ័យដល់ចំណូល ពន្ធតែប៉ុណ្ណោះ÷

ក- មានការស្នើសុំពីអ្នកជាប់ពន្ធ

ខ- សហគ្រាសដែលមានការយោងការខាតបង់ ឬមានឥណទានយោងពីឆ្នាំជាប់ពន្ធឬរយៈពេលជាប់ពន្ធមុន

គ- មានភស្តុតាងថាសហគ្រាសបានគេចវេះពន្ធ។

៥- ក្នុងករណីដែលរកឃើញជាយថាហេតុនូវភស្តុតាង ឬបទល្មើសជាក់ស្តែងដែលបញ្ជាក់ថាពិតជាមានអំពើគេចវេះពន្ធ ដែលកើតមានឡើងដោយចេតនារៀបចំរបស់សហគ្រាស អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារអាចចាត់ឱ្យអង្គភាពណាមួយ ធ្វើសវនកម្មពិសេស ឬធ្វើការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារទៅលើសហគ្រាស។ ក្នុងករណី នេះ អង្គភាពដែលកំពុងធ្វើសវនកម្មលើលិខិតស្នាម សវនកម្មមានកម្រិត ឬសវនកម្មពេញលេញ ត្រូវបញ្ឈប់និងដកចេញ ពីកម្មវិធីសវនកម្មរបស់ខ្លួន ហើយប្រសិនបើការស៊ើបអង្កេតបទល្មើសពន្ធដារមិនឈានដល់ការប្តឹងចោទទៅតុលាការ អង្គភាព ដែលធ្វើការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារត្រូវបង្វែរករណីនេះទៅអង្គភាពពាក់ព័ន្ធដើម្បីបន្ត នីតិវិធីសវនកម្មវិញ។

**ប្រការ៧.- ការជ្រើសរើសសហគ្រាសធ្វើសវនកម្ម**

ការជ្រើសរើសសហគ្រាសធ្វើសវនកម្មត្រូវធ្វើឡើងដោយផ្អែកលើលក្ខណវិនិច្ឆ័យដូចខាងក្រោម÷

- ការវិភាគហានិភ័យ
- លទ្ធផលបានមកពីការផ្ទៀងផ្ទាត់ផ្គួងព័ត៌មាន (Crosscheck)
- ព័ត៌មានទទួលបានពីតតិយជន
- ព័ត៌មានអំពីប្រភេទពន្ធឬវិស័យជាក់លាក់ណាមួយ
- ព័ត៌មានរបស់ក្រុមអ្នកជាប់ពន្ធណាមួយ
- ទីតាំងរបស់សហគ្រាស។ល។

**ប្រការ៨.- ការរៀបចំកម្មវិធីសវនកម្ម**

១- ដើម្បីចៀសវាងការធ្វើសវនកម្មត្រួតជាន់គ្នា អគ្គនាយកដ្ឋានពន្ធដារត្រូវបង្កើតគណៈកម្មការរៀបចំបែងចែកសហគ្រាសមួយដែលមានភារកិច្ចរៀបចំបញ្ជីឈ្មោះនិងចំនួនសហគ្រាស ដើម្បីបែងចែកសម្រាប់ការធ្វើសវនកម្មលើលិខិតស្នាម សវនកម្មមានកម្រិត និងសវនកម្មពេញលេញ សម្រាប់ឆ្នាំជាប់ពន្ធនីមួយៗ។ សមាសភាពនៃគណៈកម្មការនេះ ត្រូវកំណត់ដោយលិខិតបង្គាប់ការរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ។

២- ក្រោយពីបានទទួលការបែងចែកចំនួនសហគ្រាស នាយកដ្ឋានសវនកម្មសហគ្រាស នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម ទីចាត់ការពន្ធដាររាជធានីភ្នំពេញ និងសាខាពន្ធដារខេត្ត-ខណ្ឌ ត្រូវជ្រើសរើសសហគ្រាសសម្រាប់ធ្វើសវនកម្មដោយផ្អែកលើលក្ខណវិនិច្ឆ័យដែលបានកំណត់ក្នុងប្រការ៧ នៃប្រកាសនេះ និងរៀបចំកម្មវិធីនិងផែនការសវនកម្មទៅតាមប្រភេទនៃសវនកម្មនីមួយៗឱ្យបានច្បាស់លាស់ តាមសមត្ថកិច្ចរៀងៗខ្លួន ហើយត្រូវផ្ញើមកអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារធ្វើការពិនិត្យសម្រេច។

៣- ដើម្បីធានានូវនិរន្តរភាពនៃការធ្វើសវនកម្ម គណៈកម្មការរៀបចំបែងចែកសហគ្រាសសម្រាប់ធ្វើសវនកម្មពន្ធដារត្រូវរៀបចំបញ្ជីឈ្មោះសហគ្រាសសម្រាប់ធ្វើសវនកម្មឱ្យបានមុនខែមករា នៃឆ្នាំផែនការសវនកម្ម។ អង្គភាពដែលមានភារកិច្ចធ្វើសវនកម្មត្រូវរៀបចំអនុវត្តកម្មវិធីសវនកម្មឱ្យរួចរាល់ស្រេចបាច់នៅដំណាច់ឆ្នាំនៃផែនការសវនកម្ម ឬយ៉ាងយឺតបំផុតនៅដំណាច់ត្រីមាសទី ១ នៃឆ្នាំបន្ទាប់។ ក្នុងករណីមិនអាចរកឃើញថាអ្នកជាប់ពន្ធមិនបានធ្វេសប្រហែសឬធ្វេសប្រហែសធ្ងន់ធ្ងរទេ សវនករពន្ធដារដែលធ្វើសវនកម្មត្រូវសរុបលទ្ធផលនិងបិទបញ្ចប់ការធ្វើសវនកម្មរបស់ខ្លួន។ ក្នុងករណីចាំបាច់ដែលមិនអាចបិទបញ្ចប់ការធ្វើសវនកម្មបាន ប្រធានអង្គភាពត្រូវស្នើសុំការសម្រេចពីអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារដោយបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់។

៤- ក្នុងករណីពិសេសណាមួយ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អាចចាត់ឱ្យអង្គភាពមួយឬច្រើនចុះធ្វើសវនកម្មរួមគ្នាលើសហគ្រាស។

**ប្រការ៩.- ការជូនដំណឹងស្ដីពីការធ្វើសវនកម្ម**

១- មុនពេលចាប់ផ្ដើមសវនកម្ម រដ្ឋបាលសារពើពន្ធត្រូវជូនដំណឹងស្ដីពីការធ្វើសវនកម្មដល់អ្នកជាប់ពន្ធ ឬតំណាងអ្នកជាប់ពន្ធជាមុន។ លិខិតជូនដំណឹងត្រូវមានសេចក្ដីបញ្ជាក់អំពី÷

- ឈ្មោះ អាសយដ្ឋាន លេខអត្តសញ្ញាណកម្មសារពើពន្ធរបស់សហគ្រាស

- កាលបរិច្ឆេទនៃការចុះធ្វើសវនកម្ម
- ការិយបរិច្ឆេទ (រយៈពេលជាប់ពន្ធ ឬឆ្នាំជាប់ពន្ធ) ដែលត្រូវធ្វើសវនកម្ម
- ប្រភេទសវនកម្ម (សវនកម្មលើលិខិតស្នាម សវនកម្មមានកម្រិត ឬសវនកម្មពេញលេញ)
- ឈ្មោះមន្ត្រីដែលទទួលភារកិច្ចធ្វើសវនកម្ម។

លិខិតជូនដំណឹងត្រូវភ្ជាប់មកជាមួយនូវបញ្ជីឯកសារឬលិខិតស្នាមដែលត្រូវត្រៀមសម្រាប់ការធ្វើសវនកម្ម។

២- លិខិតជូនដំណឹងត្រូវបានចាត់ទុកថាបានប្រគល់យ៉ាងត្រឹមត្រូវនៅពេលដែលបានប្រគល់ជូនអ្នកជាប់ពន្ធ ឬតំណាងអ្នកជាប់ពន្ធ ឬក៏បានផ្ញើតាមប្រៃសណីយ៍ជាលិខិតអនុសិដ្ឋទៅអាសយដ្ឋានតាមផ្លូវច្បាប់របស់អ្នកជាប់ពន្ធ ទោះបីជាអ្នកជាប់ពន្ធដែលត្រូវបានជូនដំណឹងនោះ បដិសេធការប្រគល់ឬការទទួលលិខិតអនុសិដ្ឋនេះក្តី។

៣- កាលបរិច្ឆេទនៃលិខិតជូនដំណឹង គឺជាកាលបរិច្ឆេទនៃការប្រគល់ជូនអ្នកជាប់ពន្ធ។ ក្នុងករណីលិខិតជូនដំណឹងត្រូវបានផ្ញើតាមលិខិតអនុសិដ្ឋ កាលបរិច្ឆេទនៃការជូនដំណឹងគឺជាកាលបរិច្ឆេទនៃការបោះត្រាលើលិខិតអនុសិដ្ឋរបស់ការិយាល័យប្រៃសណីយ៍។

៤- ក្នុងករណីដែលអ្នកជាប់ពន្ធបានផ្លាស់ប្តូរអាសយដ្ឋានអាជីវកម្ម ហើយមិនបានជូនដំណឹងដល់រដ្ឋបាលសារពើពន្ធ លិខិតជូនដំណឹងដែលបានបញ្ជូនទៅអាសយដ្ឋានដែលអ្នកជាប់ពន្ធបានប្រកាសចុងក្រោយត្រូវចាត់ទុកថាបានប្រគល់ទទួលត្រឹមត្រូវ។

៥- ក្នុងករណីដោយមូលហេតុណាមួយ ដែលលិខិតជូនដំណឹងមិនអាចផ្តល់ដល់អ្នកជាប់ពន្ធតាមវិធីដូចមានចែងក្នុងកថាខណ្ឌ២ កថាខណ្ឌ៣ និងកថាខណ្ឌ៤ នៃប្រការនេះ លិខិតជូនដំណឹងត្រូវបានចាត់ទុកថាបានប្រគល់យ៉ាងត្រឹមត្រូវប្រសិនបើរដ្ឋបាលសារពើពន្ធបាន÷

- បិទលិខិតជូនដំណឹងភ្ជាប់ទៅនឹងទ្វារនិវាសនដ្ឋានឬទីកន្លែងប្រកបអាជីវកម្មរបស់អ្នកជាប់ពន្ធ ឬ
- ផ្សព្វផ្សាយតាមសារព័ត៌មាន ដោយតម្រូវឱ្យអ្នកជាប់ពន្ធចូលមករដ្ឋបាលសារពើពន្ធមិនឱ្យលើសពី ១៥ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទផ្សព្វផ្សាយ។

៦- សវនកម្មអាចត្រូវបានចាប់ផ្តើម ១០ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីការប្រគល់លិខិតជូនដំណឹងស្តីពីការធ្វើសវនកម្មដល់អ្នកជាប់ពន្ធ ឬឆាប់ជាងនេះដោយយោងតាមសំណើរបស់អ្នកជាប់ពន្ធ។ ក្នុងករណីពិសេសដោយផ្អែកតាមមាត្រា ១០០ និងមាត្រា១១៦ នៃច្បាប់ស្តីពីសារពើពន្ធ រដ្ឋបាលសារពើពន្ធអាចចុះធ្វើសវនកម្មដោយមិនចាំបាច់ជូនដំណឹងជាមុនដល់អ្នកជាប់ពន្ធ។

៧- ក្នុងករណីដែលមានឯកសារគ្រប់គ្រាន់ រយៈពេលធ្វើសវនកម្មត្រូវបានកំណត់យ៉ាងយូរបំផុត ០៣ ខែ សម្រាប់សវនកម្មលើលិខិតស្នាមនិងសវនកម្មមានកម្រិត និងរយៈពេល ០៦ ខែ សម្រាប់សវនកម្មពេញលេញ។

## ប្រការ១០.~ ការស្នើសុំពន្យារពេលធ្វើសវនកម្ម

ក្នុងករណីមិនអាចទទួលការធ្វើសវនកម្មដូចមានចែងក្នុងប្រការ៩ នៃប្រកាសនេះ អ្នកជាប់ពន្ធអាចស្នើសុំពន្យារពេលចុះធ្វើសវនកម្មដោយផ្អែកលើមូលហេតុសមស្រប ដោយមិនឱ្យលើសពី ៣០ថ្ងៃ ក្រោយថ្ងៃត្រូវចុះធ្វើសវនកម្មដែល

មានចែងក្នុងលិខិតជូនដំណឹងស្តីពីការធ្វើសវនកម្មឡើយ។ ក្នុងករណីរយៈពេលស្នើសុំតិចជាង ១០ថ្ងៃ អ្នកជាប់ពន្ធអាចធ្វើឡើងដោយផ្ទាល់មាត់មកសវនករពន្ធដារ។ ក្នុងករណីរយៈពេលស្នើសុំចាប់ពី ១០ថ្ងៃ ដល់ ៣០ថ្ងៃ អ្នកជាប់ពន្ធត្រូវធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមកប្រធាននាយកដ្ឋាន ឬប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ។

**ប្រការ១១.- ឯកសារតម្រូវសម្រាប់ការធ្វើសវនកម្ម**

ក្រោយពីបានទទួលលិខិតជូនដំណឹងស្តីពីការចុះធ្វើសវនកម្ម អ្នកជាប់ពន្ធត្រូវត្រៀមឯកសារពាក់ព័ន្ធនឹងអាជីវកម្មទាំងអស់ដើម្បីទុកផ្តល់ឱ្យសវនករពន្ធដារក្នុងករណីមានការស្នើសុំ។ ឯកសារដែលត្រូវត្រៀមជាអាទិ៍មាន÷

១- ព័ត៌មានសហគ្រាស÷

- របនាសម្ព័ន្ធគ្រប់គ្រង
- វិញ្ញាបនប័ត្រចុះបញ្ជី
- វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម (អតប)
- លក្ខន្តិកៈ
- វិញ្ញាបនប័ត្រផ្សេងៗ សម្រាប់ធ្វើសកម្មភាពអាជីវកម្មពីអាជ្ញាធរផ្សេងៗ ដូចជាក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងទេសចរណ៍ ជាដើម។ល។

២- ឯកសារគណនេយ្យ÷

- របាយការណ៍ហិរញ្ញវត្ថុ
- តារាងលម្អិតគណនីនីមួយៗនៃទ្រព្យសកម្ម
- តារាងលម្អិតគណនីនីមួយៗនៃទុនម្ចាស់ទ្រព្យនិងបំណុល
- តារាងលម្អិតគណនីនីមួយៗនៃរបាយការណ៍លទ្ធផល (ចំណេញ/ខាត)
- សក្ខីបត្រដើមនៃឯកសារផ្សេងៗ÷
    - តារាងបើកប្រាក់បៀវត្សប្រចាំខែ
    - កិច្ចសន្យាការងាររបស់បុគ្គលិកបរទេសនិងថ្នាក់គ្រប់គ្រង
    - កិច្ចសន្យាជួលឬលក់ផ្សេងៗ
    - កិច្ចសន្យាដេញថ្លៃផ្សេងៗ បើមាន
    - លិខិតប្រកាសពន្ធប្រចាំខែនិងប្រចាំឆ្នាំ
    - ទិនានុប្បវត្តិទិញ-លក់ប្រចាំខែ
    - តារាងកែតម្រូវការគណនាប្រាក់ពន្ធ
    - វិក្កយបត្រទិញ-លក់។ល។

ក្នុងពេលធ្វើសវនកម្ម ប្រសិនបើពិនិត្យឃើញថាមានឯកសារមួយចំនួនដែលមានការចាំបាច់សម្រាប់ប្រើប្រាស់ជាមូលដ្ឋានក្នុងការកំណត់ពន្ធ សវនករអាចធ្វើការថតចម្លងឬស្នើសុំឱ្យអ្នកជាប់ពន្ធផ្តល់ឱ្យនូវឯកសារទាំងនោះ។ អ្នកជាប់ពន្ធត្រូវផ្តល់ឯកសារដែលបានស្នើសុំយ៉ាងយឺតបំផុត ៧ ថ្ងៃ ក្រោយការស្នើសុំ។ ការខកខានមិនបានផ្តល់ឯកសារដែលបានស្នើសុំ សវនករពន្ធដារអាចធ្វើការកំណត់ពន្ធដោយផ្អែកលើព័ត៌មានដែលសវនករពន្ធដារមានស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ។

**ប្រការ១២.- សិទ្ធិប្រមូលព័ត៌មាន**

១- យោងតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ ក្នុងគោលដៅកំណត់ប្រាក់ពន្ធត្រូវបង់ ឬដើម្បីប្រមូលពន្ធ រដ្ឋបាលសារពើពន្ធអាចធ្វើលិខិតជូនដំណឹងដល់អ្នកជាប់ពន្ធ ឬតតិយជនឱ្យ÷

- ផ្តល់ព័ត៌មានដែលទាក់ទិននឹងអាជីវកម្មរបស់អ្នកជាប់ពន្ធ ដូចមានចែងក្នុងលិខិតជូនដំណឹង ដូចជា ព័ត៌មានស្តីពីអ្នកផ្គត់ផ្គង់ អតិថិជន ឬគណនីនៅធនាគារ ឬឯកសារពាក់ព័ន្ធដទៃទៀត
- បង្ហាញខ្លួនទៅតាមពេលវេលា និងទីកន្លែងដែលមានបញ្ជាក់នៅក្នុងលិខិតជូនដំណឹងដើម្បីផ្តល់ព័ត៌មាន និងដើម្បីបង្ហាញឬផ្តល់ឯកសារ ឬទិន្នន័យដែលបុគ្គលនោះគ្រប់គ្រង ដែលមានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងលិខិតជូនដំណឹង។

២- សម្រាប់ការធ្វើសវនកម្មនីមួយៗ រដ្ឋបាលសារពើពន្ធមានសិទ្ធិចូលគ្រឹះស្ថានអាជីវកម្ម ទីកន្លែងដែលបានចាត់ទុកជាគ្រឹះស្ថានអាជីវកម្ម ឬជាកន្លែងដែលបើកជាសាធារណៈ ឬទីកន្លែងដទៃទៀត ដើម្បីធ្វើការកំណត់ប្រាក់ពន្ធត្រូវបង់របស់បុគ្គលណាម្នាក់ ឬដើម្បីប្រមូលពន្ធ នៅក្នុងពេលប្រកបអាជីវកម្ម ឬគ្រប់ពេលទាំងអស់ក្នុងករណីមានដីកាដែលព្រះរាជអាជ្ញា ឬចៅក្រមបានចេញឱ្យ។

៣-រដ្ឋបាលសារពើពន្ធដែលបានចូលដោយស្របច្បាប់ទៅក្នុងទីកន្លែងដូចដែលមានចែងខាងលើអាច÷

- ធ្វើសម្រង់ ឬចម្លងឯកសារនានាដែលស្ថិតនៅក្នុងកន្លែងទាំងនោះ
- រឹបអូសឯកសារនានាឬវត្ថុតាងដទៃទៀតដែលអាចក្លាយជាព័ត៌មានសម្រាប់កំណត់ប្រាក់ពន្ធត្រូវបង់របស់បុគ្គលណាម្នាក់
- ដាក់ឧបករណ៍សម្រាប់ត្រួតពិនិត្យផ្សេងៗ ឬបោះត្រាបិទសំគាល់ ឃាត់ទុកទំនិញ បើសិនជាមានជាប់ទាក់ទងដល់ការអនុវត្តពន្ធណាមួយ
- ធ្វើសារពើភ័ណ្ឌទ្រព្យសកម្ម វត្ថុធាតុដើម ផលិតផលកំពុងផលិត ផលិតផលសម្រេច និងស្តុកដទៃទៀត។

៤- សវនករពន្ធដារអាចទាមទារឱ្យអ្នកជាប់ពន្ធផ្តល់ឯកសារផ្សេងក្រៅពីឯកសារអាជីវកម្ម (ឧទាហរណ៍ គណនីផ្ទាល់ខ្លួននៅធនាគារ ការទិញ- លក់ទ្រព្យសម្បត្តិ ចំណាយផ្ទាល់ខ្លួន ឬចំណាយផ្សេងៗទៀត) ក្នុងករណីសហគ្រាសជាសហគ្រាសឯកបុគ្គល។

៥- ក្នុងករណីដែលទីតាំងការងារដែលផ្តល់ដោយអ្នកជាប់ពន្ធមិនសមស្របសម្រាប់ធ្វើសវនកម្ម ឬមិនមានម៉ាស៊ីនថតចម្លង សវនករពន្ធដារអាចយកឯកសារទៅពិនិត្យនៅការិយាល័យរបស់ខ្លួន ដោយមានការឯកភាពពីអ្នកជាប់ពន្ធ។ ក្នុងករណីនេះ ឯកសារទាំងអស់ត្រូវប្រគល់ជូនអ្នកជាប់ពន្ធវិញនៅពេលដែលការធ្វើសវនកម្មត្រូវបានបញ្ចប់។ ឯកសារដែលត្រូវប្រគល់ឱ្យអ្នកជាប់ពន្ធវិញត្រូវមានតារាងប្រគល់និងទទួលត្រឹមត្រូវ។

៦- ក្នុងករណីឯកសារនិងបញ្ជីគណនេយ្យបានរក្សាទុកជាទម្រង់អេឡិចត្រូនិក សហគ្រាសត្រូវមានឯកសារច្បាប់ដើមជាក្រដាសស្នាមសម្រាប់ការត្រួតពិនិត្យ។ ប្រសិនបើនៅពេលត្រួតពិនិត្យ អ្នកជាប់ពន្ធមិនអាចផ្តល់ឯកសារជាក្រដាសស្នាម អ្នកជាប់ពន្ធត្រូវអនុញ្ញាតឱ្យសវនករពន្ធដារត្រួតពិនិត្យប្រព័ន្ធកុំព្យូទ័រ និងថតចម្លងឯកសារជាទម្រង់អេឡិចត្រូនិកតាមរយៈឧបករណ៍ថតចម្លង។

**ប្រការ១៣.- ការពិនិត្យឯកសារ**

១- អ្នកជាប់ពន្ធត្រូវផ្តល់ឯកសារសម្រាប់ការធ្វើសវនកម្មដូចមានចែងក្នុងប្រការ១១ នៃប្រកាសនេះ តាមការតម្រូវរបស់សវនករពន្ធដារ។ ក្នុងករណីអ្នកជាប់ពន្ធមិនបានផ្តល់ឯកសារឬព័ត៌មានតាមការតម្រូវ សវនករពន្ធដារអាចធ្វើការកំណត់ពន្ធដោយផ្អែកលើមូលដ្ឋាននៃព័ត៌មានជាក់លាក់ដែលរដ្ឋបាលសារពើពន្ធមានដូចជា÷

- ព័ត៌មានដែលមានចុះនៅក្នុងលិខិតប្រកាសសារពើពន្ធនានា ឬឯកសារផ្សេងៗដែលអ្នកជាប់ពន្ធបានដាក់ជូនរដ្ឋបាលសារពើពន្ធ
- ព័ត៌មានដែលមានចុះនៅក្នុងលិខិតប្រកាសព័ត៌មាន
- ព័ត៌មានផ្សេងៗទៀតដែលរដ្ឋបាលសារពើពន្ធបានទទួល។

២- ប្រសិនបើប្រាក់ចំណូលជាប់ពន្ធឬប្រាក់ចំណូលដែលបានប្រកាសដោយអ្នកជាប់ពន្ធមានភាពខុសគ្នាច្រើនធៀបទៅនឹងការទិញទ្រព្យសកម្មឬវត្ថុនានា ដែលធ្វើឱ្យឃើញចំណាយរបស់អ្នកជាប់ពន្ធលេចធ្លោ នោះសវនករពន្ធដារមានសិទ្ធិកំណត់ពន្ធដោយផ្អែកលើមូលដ្ឋាននៃប្រាក់ចំណូលប៉ាន់ស្មានសមស្របទៅនឹងទំហំនៃចំណាយដើម្បីទិញទ្រព្យសកម្មឬវត្ថុនានានោះ។ ការស្វែងរកភស្តុតាងនានាដើម្បីបញ្ជាក់ថាប្រាក់ពន្ធដែលរដ្ឋបាលសារពើពន្ធកំណត់មិនត្រឹមត្រូវ គឺជាបន្ទុករបស់អ្នកជាប់ពន្ធ។

**ប្រការ១៤.- ការពន្យល់អំពីលទ្ធផលសវនកម្ម**

១- ក្រោយការត្រួតពិនិត្យឯកសារ សវនករពន្ធដារត្រូវធ្វើការបូកសរុបលទ្ធផលសវនកម្មដោយត្រូវពន្យល់អ្នកជាប់ពន្ធអំពី÷

ក- ការយល់ស្របឬមិនយល់ស្របនូវចំណែកណាមួយឬទាំងស្រុងនៃការប្រកាសបង់ពន្ធរបស់អ្នកជាប់ពន្ធ
ខ- ការប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិស្តីពីពន្ធដារដែលបានរកឃើញ
គ- មូលដ្ឋាននិងបទប្បញ្ញត្តិពន្ធដារពាក់ព័ន្ធដែលទាក់ទិននឹងការកំណត់ពន្ធ
ឃ- ប្រាក់ពន្ធដែលនឹងត្រូវកំណត់ឡើងវិញ។

២- អ្នកជាប់ពន្ធអាចធ្វើការបញ្ចេញយោបល់ ដែលក្នុងនោះអាចយល់ស្របឬជំទាស់នូវចំណែកណាមួយឬទាំងស្រុងនៃលទ្ធផលសវនកម្មដូចក្នុងកថាខណ្ឌ១ នៃប្រការនេះ ដោយត្រូវបង្ហាញឯកសារបន្ថែមដែលគាំទ្រដល់ការជំទាស់របស់ខ្លួន។

៣- ប្រសិនបើអ្នកជាប់ពន្ធពុំមានការអះអាងសមស្រប និងបង្ហាញនូវឯកសារគាំទ្រគ្រប់គ្រាន់ដល់ការជំទាស់របស់ខ្លួន សវនករពន្ធដារត្រូវបញ្ជាក់ជូនអ្នកជាប់ពន្ធអំពីការមិនឯកភាពលើការជំទាស់នោះ។

**ប្រការ១៥.- លិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញ**

១- ក្រោយពីបញ្ចប់ការធ្វើសវនកម្ម សវនករពន្ធដារត្រូវធ្វើរបាយការណ៍អំពីលទ្ធផលសវនកម្ម ដែលក្នុងនោះអាចមានឬគ្មានទឹកប្រាក់កំណត់ពន្ធឡើងវិញ ហើយលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញត្រូវបានប្រគល់ជូនអ្នកជាប់ពន្ធឬអ្នកតំណាង ស្របតាមវិធានដូចមានចែងក្នុងកថាខណ្ឌ២ កថាខណ្ឌ៣ កថាខណ្ឌ៤ និងកថាខណ្ឌ៥ នៃប្រការ៩ នៃប្រកាសនេះ។

២- ក្នុងករណីយល់ស្របតាមការកំណត់ពន្ធឡើងវិញរបស់រដ្ឋបាលសារពើពន្ធ អ្នកជាប់ពន្ធត្រូវបង់ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់ដែលបានកំណត់ តាមកាលបរិច្ឆេទនៃការជូនដំណឹងជាលាយលក្ខណអក្សរ ដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ។

៣-ក្នុងករណីមិនយល់ស្រប អ្នកជាប់ពន្ធមានរយៈពេល ៣០ ថ្ងៃ ដើម្បីឆ្លើយតបជាលាយលក្ខអក្សរចំពោះការកំណត់ពន្ធឡើងវិញទៅអង្គភាពពន្ធដារដែលទទួលបន្ទុកធ្វើសវនកម្មនោះ។ ក្នុងរយៈពេលនេះ អ្នកជាប់ពន្ធអាចទទួលយកឬជំទាស់នូវចំណែកណាមួយឬទាំងស្រុងនៃការកំណត់ពន្ធឡើងវិញ។ អ្នកជាប់ពន្ធត្រូវចាត់ទុកថា យល់ព្រមចំពោះការកំណត់ពន្ធឡើងវិញ បើសិនជាពុំបានឆ្លើយតប។

៤- អង្គភាពដែលបានកំណត់ពន្ធត្រូវរក្សាទុកពេលវេលាចំនួន ៣០ ថ្ងៃ មុននឹងបញ្ជូនលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញទៅឱ្យអង្គភាពប្រមូលពន្ធ។ នៅពេលទទួលលិខិតជូនដំណឹងពីអង្គភាពកំណត់ពន្ធ អង្គភាពប្រមូលពន្ធត្រូវកត់ត្រាជាបំណុលពន្ធត្រូវទារ និងត្រូវចេញលិខិតជូនដំណឹងស្តីពីការទារបំណុលពន្ធទៅអ្នកជាប់ពន្ធ។

**ប្រការ១៦.- ការតវ៉ាចំពោះការកំណត់ពន្ធឡើងវិញ**

អ្នកជាប់ពន្ធដែលមិនយល់ស្របនូវចំណែកណាមួយឬទាំងស្រុងនៃការកំណត់ពន្ធដែលបានតវ៉ាទៅអង្គភាពកំណត់ពន្ធដូចមានចែងក្នុងកថាខណ្ឌ៣ នៃប្រការ១៥ នៃប្រកាសនេះ មានសិទ្ធិតវ៉ាជាលាយលក្ខណ៍អក្សរទៅអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារក្នុងអំឡុងពេល ៣០ ថ្ងៃ ក្រោយពេលទទួលបានលិខិតជូនដំណឹងទារបំណុលពន្ធ ដោយភ្ជាប់មកជាមួយនូវលិខិតដែលបានតវ៉ាទៅអង្គភាពកំណត់ពន្ធ និងភស្តុតាងនានាដែលបញ្ជាក់ថាការកំណត់ពន្ធមិនត្រឹមត្រូវ។ វិធាននិងនីតិវិធីនៃការតវ៉ាត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសលេខ ១៤៧០ សហវ.ប្រក ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីវិធាន និងនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាពន្ធដារ។

**ប្រការ១៧.- ពន្ធបន្ថែម និងការប្រាក់**

ចំពោះការកំណត់ពន្ធឡើងវិញ ពន្ធបន្ថែម និងការប្រាក់ ត្រូវបានកំណត់ដូចខាងក្រោម÷

១- ក្នុងករណីដែលប្រាក់ពន្ធដែលបានកំណត់មានចំនួនតិចជាងឬស្មើ ១០% នៃប្រាក់ពន្ធដែលត្រូវបង់តាមច្បាប់កំណត់ អ្នកជាប់ពន្ធត្រូវបានចាត់ទុកថាបានធ្វេសប្រហែស និងត្រូវទទួលរងពន្ធបន្ថែម ១០% នៃប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ ១,៥% ក្នុងមួយខែ ឬចំណែកនៃខែដែលប្រាក់ពន្ធនៅខ្វះមិនទាន់បានបង់។

២- ក្នុងករណីដែលប្រាក់ពន្ធដែលបានកំណត់មានចំនួនលើសពី ១០% នៃប្រាក់ពន្ធដែលត្រូវបង់តាមច្បាប់កំណត់ អ្នកជាប់ពន្ធត្រូវបានចាត់ទុកថាបានធ្វេសប្រហែសធ្ងន់ធ្ងរ និងត្រូវទទួលរងពន្ធបន្ថែម ២៥% នៃប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ ១,៥% ក្នុងមួយខែ ឬចំណែកនៃខែដែលប្រាក់ពន្ធនៅខ្វះមិនទាន់បានបង់។

៣-ក្នុងករណីដែលអ្នកជាប់ពន្ធគ្មានបញ្ជិកាគណនេយ្យ ឬកាន់បញ្ជីគណនេយ្យក្លែងបន្លំ ឬមិនសហការផ្តល់ឯកសារនានាទាក់ទិននឹងការធ្វើសវនកម្ម អ្នកជាប់ពន្ធត្រូវបានចាត់ទុកថាបានគេចវេះពន្ធ និងត្រូវទទួលរងពន្ធបន្ថែម ៤០% នៃប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ ១,៥% ក្នុងមួយខែ ឬចំណែកនៃខែដែលប្រាក់ពន្ធនៅខ្វះមិនទាន់បានបង់។

ក្រៅពីពន្ធបន្ថែមនិងការប្រាក់ដូចមានចែងក្នុងកថាខណ្ឌ១ កថាខណ្ឌ២ និងកថាខណ្ឌ៣ នៃប្រការនេះ អ្នកជាប់ពន្ធត្រូវទទួលរងទោសទណ្ឌដទៃទៀតស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

**ប្រការ១៨.- ភារកិច្ចរបស់សវនករពន្ធដារនៅពេលចុះធ្វើសវនកម្ម**

នៅពេលចុះធ្វើសវនកម្ម សវនករពន្ធដារត្រូវបង្ហាញលិខិតបញ្ជាបេសកកម្ម ដែលចេញដោយអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ឬតំណាងដែលបានទទួលសិទ្ធិ និងត្រូវពន្យល់អ្នកជាប់ពន្ធឱ្យបានច្បាស់លាស់អំពីសិទ្ធិនិងភារកិច្ចរបស់រដ្ឋបាលសារពើពន្ធក្នុងការធ្វើសវនកម្ម នីតិវិធីនៃការធ្វើសវនកម្ម និងសិទ្ធិនិងភារកិច្ចរបស់អ្នកជាប់ពន្ធដែលទទួលរងការធ្វើសវនកម្មពន្ធដារ ដោយអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈខ្ពស់។

**ប្រការ១៩.- សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ**

ក្នុងអំឡុងពេលធ្វើសវនកម្ម អ្នកជាប់ពន្ធមានសិទ្ធិនិងកាតព្វកិច្ច ដូចខាងក្រោម÷

- សិទ្ធិជ្រើសរើសតំណាងស្របច្បាប់ដោយមានការបញ្ជាក់ជាលាយលក្ខណអក្សរ
- សិទ្ធិទទួលបានការពន្យល់អំពីច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារនានា
- សិទ្ធិទទួលបានការពន្យល់អំពីហេតុផលនិងមូលដ្ឋាននៃការកំណត់ពន្ធឡើងវិញ
- ត្រូវផ្តល់ឯកសារតាមការតម្រូវរបស់រដ្ឋបាលសារពើពន្ធ ដូចមានចែងក្នុងប្រការ១១ នៃប្រកាសនេះ
- ត្រូវបង្ហាញខ្លួនតាមកាលបរិច្ឆេទនិងទីកន្លែងដែលមានបញ្ជាក់ក្នុងលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ។

**ប្រការ២០.- ការតវ៉ាចំពោះការប្រព្រឹត្តខុសឆ្គងនឹងនីតិវិធីសវនកម្មរបស់សវនករ**

ក្នុងករណីសវនករពន្ធដារមិនគោរពតាមវិធាននិងនីតិវិធីដូចមានចែងក្នុងប្រកាសនេះ អ្នកជាប់ពន្ធអាចតវ៉ាទៅអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ។

**ប្រការ២១.- ការទុកជានិរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ២២.- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាល ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំច សំរិទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចប្រការ ២២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ..៩៦២..............សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការគ្រប់គ្រងបំណុលពន្ធដារ

## ឧបនាយករដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៥៧១ សហវ.ប្រក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការទូទាត់បំណុលពន្ធតាមរយៈកិច្ចព្រមព្រៀងទូទាត់ជាដំណាក់កាល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- គោលបំណង**

ប្រកាសនេះមានគោលបំណងកំណត់នូវវិធាននិងនីតិវិធីក្នុងការគ្រប់គ្រងបំណុលពន្ធដារ ដើម្បីគាំទ្រដល់ដំណើរការប្រមូលបំណុលពន្ធឱ្យកាន់តែមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងតម្លាភាព។

**ប្រការ ២.- វិសាលភាព**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធដែលជំពាក់បំណុលពន្ធ។

**ប្រការ ៣.- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះ÷

១- ពាក្យ "បំណុលពន្ធ" សំដៅដល់ប្រាក់ពន្ធនិងអាករគ្រប់ប្រភេទ ដែលអ្នកជាប់ពន្ធមិនបានបង់នៅពេលដល់កំណត់ត្រូវបង់។ បំណុលពន្ធរួមបញ្ចូលទាំងប្រាក់ពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវ។

២- ពាក្យ "ឥណទេយ្យពន្ធ" សំដៅដល់គណនីបំណុលពន្ធដែលអ្នកជាប់ពន្ធជំពាក់។

៣- ពាក្យ "ប្រធានសក្តិ" សំដៅដល់បាតុភូត ឬជាព្រឹត្តិការណ៍ដែលកើតឡើង ដោយមិនដឹងជាមុន មិនអាចប៉ាន់ស្មានជាមុនបាន និងមិនអាចជម្នះបាន ដូចជា គ្រោះធម្មជាតិ (ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី) សង្គ្រាម កុបកម្ម អគ្គិភ័យ ឬគ្រោះមហន្តរាយជាយថាហេតុ។

## ជំពូកទី ២

## ការកត់ត្រា និងការទូទាត់បំណុលពន្ធ

**ប្រការ ៤.- ប្រភពបំណុលពន្ធ**

១- បំណុលពន្ធកើតឡើងដោយសារការធ្វេសប្រហែស ធ្វេសប្រហែសធ្ងន់ធ្ងរ ការគេចវេះពន្ធ ឬការប្រព្រឹត្តអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដាររបស់អ្នកជាប់ពន្ធ ដែលក្នុងនោះមាន÷

- ក- ការយឺតយ៉ាវក្នុងការដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ ឬការកែតម្រូវលិខិតប្រកាសពន្ធដែលនាំឱ្យមានប្រាក់ពន្ធត្រូវបង់
- ខ- ការរកឃើញប្រាក់ពន្ធដែលអ្នកជាប់ពន្ធបានបង់ខ្វះតាមរយៈការធ្វើសវនកម្មពន្ធដារគ្រប់ប្រភេទ រួមមានសវនកម្មលើលិខិតស្នាម សវនកម្មមានកម្រិត សវនកម្មពេញលេញ និងការស៊ើបអង្កេតបទល្មើសពន្ធដារ។

២- ក្នុងករណី÷

- ក- បំណុលពន្ធដូចមានចែងក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌ ១ នៃប្រការនេះ រដ្ឋបាលសារពើពន្ធត្រូវចេញលិខិតបញ្ជាក់ការទទួលលិខិតប្រកាសពន្ធដល់អ្នកជាប់ពន្ធ ដែលនៅក្នុងលិខិតនោះមានបញ្ជាក់អំពីប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវប្រសិនបើមាន
- ខ- បំណុលពន្ធដូចមានចែងក្នុងវាក្យខណ្ឌ ខ នៃកថាខណ្ឌ ១ នៃប្រការនេះ រដ្ឋបាលសារពើពន្ធត្រូវចេញលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញដល់អ្នកជាប់ពន្ធ ដែលនៅក្នុងលិខិតនោះមានបញ្ជាក់អំពីប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវ។

៣- ក្នុងករណីអ្នកជាប់ពន្ធធ្វើការតវ៉ាចំពោះការកំណត់ពន្ធ ដូចមានចែងក្នុងកថាខណ្ឌ ២ នៃប្រការនេះ រដ្ឋបាលសារពើពន្ធឬអង្គភាពកំណត់ពន្ធ ត្រូវពិនិត្យ និងធ្វើការសម្រេចជាថ្មីចំពោះការកំណត់ពន្ធរបស់ខ្លួន។

៤- ក្នុងករណីអ្នកជាប់ពន្ធមិនយល់ស្របនូវចំណែកណាមួយនៃការកំណត់ពន្ធដូចមានចែងក្នុងកថាខណ្ឌ ១ នៃប្រការនេះ អ្នកជាប់ពន្ធអាចធ្វើការទូទាត់តែប្រភេទពន្ធដែលបានយល់ស្រប ដោយរក្សាទុកប្រភេទពន្ធដែលមិនយល់ស្របដើម្បីធ្វើការតវ៉ា។ ក្នុងករណីនេះរដ្ឋបាលសារពើពន្ធឬអង្គភាពកំណត់ពន្ធ ត្រូវរៀបចំសលាកបត្រកំណត់ពន្ធបញ្ជូនទៅអង្គភាពប្រមូលបំណុលពន្ធ តែប្រភេទពន្ធដែលនៅខ្វះមិនទាន់បានទូទាត់ប៉ុណ្ណោះ។

៥- ក្នុងករណីអ្នកជាប់ពន្ធមិនធ្វើការតវ៉ា ឬមិនបានទូទាត់ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃទទួលលិខិតបញ្ជាក់ការទទួលលិខិតប្រកាសពន្ធ ដូចមានចែងក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌ ២ នៃប្រការនេះ ឬលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញ ដូចមានចែងក្នុងវាក្យខណ្ឌ ខ នៃកថាខណ្ឌ ២ នៃប្រការនេះ រដ្ឋបាលសារពើពន្ធឬអង្គភាពកំណត់ពន្ធ ត្រូវរៀបចំសលាកបត្រកំណត់ពន្ធបញ្ជូនទៅអង្គភាពប្រមូលបំណុលពន្ធ។

**ប្រការ ៥.- ការកត់ត្រាឥណទេយ្យពន្ធ និងលិខិតជូនដំណឹងទារបំណុលពន្ធ**

១- ក្រោយទទួលបានសលាកបត្រកំណត់ពន្ធ ដូចមានចែងក្នុងកថាខណ្ឌ ៤ និងកថាខណ្ឌ ៥ នៃប្រការ ៤ នៃប្រកាសនេះ អង្គភាពប្រមូលបំណុលពន្ធត្រូវកត់ត្រាឥណទេយ្យពន្ធ និងផ្ញើលិខិតជូនដំណឹងទារបំណុលពន្ធទៅឱ្យអ្នកជាប់ពន្ធ ដែលមានបញ្ជាក់នូវចំនួនប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវ។ អ្នកជាប់ពន្ធមានរយៈពេល ៣០ថ្ងៃ ដើម្បីតវ៉ាទៅអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ឬទូទាត់បំណុលពន្ធដូចមានបញ្ជាក់ក្នុងលិខិតជូនដំណឹងទារបំណុលពន្ធ។

២- ក្នុងករណីអ្នកជាប់ពន្ធធ្វើការតវ៉ាចំពោះបំណុលពន្ធ ដូចមានចែងក្នុងកថាខណ្ឌ ១ នៃប្រការនេះ អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវពិនិត្យ និងធ្វើការសម្រេចជាថ្មីចំពោះបំណុលពន្ធដែលអ្នកជាប់ពន្ធបានតវ៉ា។

៣- ក្នុងករណីអ្នកជាប់ពន្ធមិនបានតវ៉ាទៅអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ឬមិនបានទូទាត់បំណុលពន្ធដូចមានចែងក្នុងកថាខណ្ឌ ១ នៃប្រការនេះ ក្នុងអំឡុងពេល ៣០ថ្ងៃក្រោយថ្ងៃប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធដល់អ្នកជាប់ពន្ធ អង្គភាពប្រមូលបំណុលពន្ធត្រូវផ្ញើលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធទៅឱ្យអ្នកជាប់ពន្ធ។

៤- ក្នុងករណីដែលអ្នកជាប់ពន្ធមិនបានទូទាត់បំណុលពន្ធក្នុងរយៈពេល ១៥ថ្ងៃ ក្រោយពីបានទទួលលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ ដូចមានចែងក្នុងកថាខណ្ឌ ៣ នៃប្រការនេះ បំណុលពន្ធនឹងទទួលរងពន្ធបន្ថែម ២៥% នៃទឹកប្រាក់ពន្ធបង់យឺត និងការប្រាក់ ១,៥% ក្នុងមួយខែ នៃទឹកប្រាក់ពន្ធបង់យឺតសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធនោះនៅមិនទាន់បានបង់។

៥- លិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ ជាលិខិតដែលអង្គភាពប្រមូលបំណុលពន្ធត្រូវចេញទៅឱ្យអ្នកជាប់ពន្ធ ដើម្បីធ្វើការរំលឹកអ្នកជាប់ពន្ធឱ្យមកទូទាត់បំណុលពន្ធក្នុងរយៈពេល ១៥ថ្ងៃក្រោយពេលទទួលលិខិត មុននឹងរដ្ឋបាលសារពើពន្ធអនុវត្តវិធានការតឹងទារបំណុលពន្ធ។

៦- ការអនុវត្តពន្ធបន្ថែមនិងការប្រាក់នៃបំណុលពន្ធ ដូចមានចែងក្នុងកថាខណ្ឌ ៤ នៃប្រការនេះ មិនមានផលប៉ះពាល់ដល់ពន្ធបន្ថែមនិងការប្រាក់ នៃការកំណត់ពន្ធឡើងវិញឡើយ។

**ប្រការ ៦.- ការទូទាត់បំណុលពន្ធ**

១- អ្នកជាប់ពន្ធ អាចទូទាត់បំណុលពន្ធតាមវិធីដូចខាងក្រោម÷

- ក- ធ្វើការទូទាត់បំណុលពន្ធឱ្យគ្រប់ចំនួនក្នុងពេលតែមួយលើក
- ខ- ធ្វើការទូទាត់បំណុលពន្ធជាដំណាក់កាល ក្នុងករណីដែលអ្នកជាប់ពន្ធពុំមានលទ្ធភាពទូទាត់បំណុលពន្ធបានគ្រប់ចំនួនក្នុងពេលតែមួយលើក ព្រមទាំងទទួលបានការអនុញ្ញាតពីអគ្គនាយកដ្ឋានពន្ធដារតាមរយៈកិច្ចព្រមព្រៀងទូទាត់ជាដំណាក់កាល
- គ- ធ្វើការទូទាត់បំណុលពន្ធតែប្រភេទពន្ធ ពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវដែលបានយល់ស្រប ដោយរក្សាទុកប្រភេទពន្ធ ពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវ ដែលមិនយល់ស្របដើម្បីធ្វើការតវ៉ា

ឃ- ធ្វើការទូទាត់បំណុលពន្ធតាមចំណែកភាគហ៊ុនរបស់រូបវន្តបុគ្គលណាម្នាក់ជាម្ចាស់ភាគហ៊ុនដែលទទួលខុសត្រូវតាមចំនួនសមាមាត្រភាគហ៊ុនដូចមានចែងក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ក្នុងករណីដែលម្ចាស់ភាគហ៊ុនមានបំណងធ្វើការទូទាត់បំណុលពន្ធតែលើចំណែកបំណុលពន្ធរបស់ខ្លួន តាមរយៈសំណើសុំរបស់ម្ចាស់ហ៊ុន ព្រមទាំងទទួលបានការអនុញ្ញាតពីអគ្គនាយកដ្ឋានពន្ធដារ។

២- រូបវន្តបុគ្គលជាម្ចាស់ភាគហ៊ុនដែលបានទូទាត់បំណុលតាមវាក្យខណ្ឌ ឃ នៃកថាខណ្ឌ ១ នៃប្រការនេះ អាចរួចផុតការអនុវត្តវិធានការទារ និងវិធានការតឹងទារបំណុលពន្ធពីរដ្ឋបាលសារពើពន្ធ ដូចមានចែងក្នុងប្រការ ៩ និងប្រការ ១០ នៃប្រកាសនេះ ប៉ុន្តែរូបវន្តបុគ្គលជាម្ចាស់ភាគហ៊ុននោះនៅតែត្រូវទទួលខុសត្រូវនូវបំណុលពន្ធរួមទាំងឡាយរបស់ក្រុមហ៊ុន។ ចំពោះប្រាក់ពន្ធដែលបានទូទាត់រួច ពុំមានលក្ខណៈប្រតិសកម្មឡើយ ក្នុងករណីមានសេចក្តីសម្រេចពីរដ្ឋបាលសារពើពន្ធជាថ្មី ដែលប្រាក់ពន្ធនោះតូចជាងប្រាក់ពន្ធដែលបានទូទាត់រួច។

៣- ដើម្បីទូទាត់បំណុលពន្ធតាមវិធី ដូចមានចែងក្នុងកថាខណ្ឌ ១ នៃប្រការនេះ អ្នកជាប់ពន្ធត្រូវប្រើប្រាស់លិខិតជូនដំណឹងទារបំណុលពន្ធ ឬលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ ឬសេចក្តីសម្រេចដោះស្រាយបណ្តឹងតវ៉ាដែលអ្នកជាប់ពន្ធបានទទួលពីរដ្ឋបាលសារពើពន្ធទៅកាន់ធនាគារដើម្បីទូទាត់បំណុលពន្ធនោះ។ ក្រោយពីបានទូទាត់បំណុលពន្ធនិងទទួលបានបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ អ្នកជាប់ពន្ធត្រូវភ្ជាប់ជាមួយនូវបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធទៅកាន់រដ្ឋបាលសារពើពន្ធដែលសហគ្រាសស្ថិតនៅ ដើម្បីទទួលបានលិខិតបញ្ជាក់ការទូទាត់បំណុលពន្ធ។ ទឹកប្រាក់ដែលបានទូទាត់ ត្រូវបានដកចេញពីចំនួនទឹកប្រាក់បំណុលពន្ធសរុប។

**ប្រការ ៧.- ការទទួលខុសត្រូវលើបំណុលពន្ធ**

១- អភិបាល បណ្ណាធិការ កម្មសិទ្ធិករ របស់សហគ្រាស ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះបំណុលពន្ធដែលត្រូវបង់។

២- បំណុលពន្ធពុំអាចផ្ទេរទៅឱ្យតតិយជនទទួលខុសត្រូវជំនួសឡើយ វៀរលែងតែបុគ្គលនោះជាទាយាទទទួលមរតក ឬទទួលសិទ្ធិតាមនីតិវិធីផ្ទេរភាគហ៊ុន ឬបុគ្គលណាមួយដែលត្រូវបានរដ្ឋបាលសារពើពន្ធរកឃើញថាបានទទួលប្រយោជន៍ពីការគេចវេះនៃការបង់ប្រាក់ពន្ធនិងបង្កើតបានជាបំណុលនោះ។ រដ្ឋបាលសារពើពន្ធមានសិទ្ធិបដិសេធការផ្ទេរបំណុលពន្ធក្នុងករណីរកឃើញថាការផ្ទេរបំណុលពន្ធ ឬការលក់អាជីវកម្មក្នុងគោលបំណងគេចវេះពីការទទួលខុសត្រូវបំណុលពន្ធ។

## ជំពូកទី ៣
## វិធានការទារ និងតឹងទារបំណុលពន្ធ

**ប្រការ ៨.- ការជូនដំណឹងពាក់ព័ន្ធនឹងការទារបំណុលពន្ធ**

អនុលោមតាមមាត្រា ៩៥ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ការជូនដំណឹងពាក់ព័ន្ធនឹងការទារបំណុលពន្ធ ត្រូវអនុវត្តដូចខាងក្រោម÷

១- លិខិតស្នាមឬលិខិតជូនដំណឹងដែលពាក់ព័ន្ធនឹងបំណុលពន្ធ ដែលរដ្ឋបាលសារពើពន្ធប្រគល់ជូនអ្នកជាប់ពន្ធមានលក្ខណៈជាការដាក់ឱ្យអ្នកជាប់ពន្ធមានកាតព្វកិច្ចចំពោះរដ្ឋបាលសារពើពន្ធ លុះត្រាតែលិខិតស្នាមឬលិខិតជូនដំណឹងនោះត្រូវបានធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវបានប្រគល់ឱ្យអ្នកជាប់ពន្ធ។

២- លិខិតស្នាមឬលិខិតជូនដំណឹងនោះត្រូវបានចាត់ទុកថាបានប្រគល់យ៉ាងត្រឹមត្រូវ លុះត្រាតែបានប្រគល់ជូនអ្នកជាប់ពន្ធ ឬអ្នកតំណាងអ្នកជាប់ពន្ធ ឬផ្ញើតាមប្រៃសណីយ៍ជាលិខិតអនុសិដ្ឋតាមអាសយដ្ឋានដែលអ្នកជាប់ពន្ធផ្តល់មករដ្ឋបាលសារពើពន្ធនៅពេលចុះបញ្ជីពន្ធដារឬធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសចុងក្រោយ ទោះបីជាអ្នកជាប់ពន្ធដែលត្រូវបានជូនដំណឹងនោះបដិសេធការប្រគល់ឬទទួលលិខិតអនុសិដ្ឋនោះក្តី។

៣- កាលបរិច្ឆេទនៃលិខិតស្នាមឬលិខិតជូនដំណឹងផ្សេងៗ គឺជាកាលបរិច្ឆេទនៃការប្រគល់ជូនអ្នកជាប់ពន្ធ។ ក្នុងករណីលិខិតស្នាមឬលិខិតជូនដំណឹងត្រូវបានផ្ញើតាមលិខិតអនុសិដ្ឋ កាលបរិច្ឆេទនៃការជូនដំណឹង គឺជាកាលបរិច្ឆេទនៃការបោះត្រាលើលិខិតអនុសិដ្ឋរបស់ការិយាល័យប្រៃសណីយ៍។

៤- ក្នុងករណីដែលអាសយដ្ឋានរបស់អ្នកជាប់ពន្ធត្រូវបានផ្លាស់ប្តូរ ហើយអ្នកជាប់ពន្ធមិនបានជូនដំណឹងដល់រដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្តូរនោះទេ លិខិតស្នាមឬលិខិតជូនដំណឹងដែលបានបញ្ជូនទៅអាសយដ្ឋានដែលរដ្ឋបាលសារពើពន្ធបានទទួលព័ត៌មានចុងក្រោយបង្អស់ ត្រូវបានចាត់ទុកថាបានប្រគល់ទទួលត្រឹមត្រូវ។

៥- ក្នុងករណីដោយមូលហេតុណាមួយ ដែលលិខិតស្នាមឬលិខិតជូនដំណឹងមិនអាចប្រគល់ជូនអ្នកជាប់ពន្ធតាមវិធីដូចមានចែងក្នុងកថាខណ្ឌ ១ កថាខណ្ឌ ២ កថាខណ្ឌ ៣ និងកថាខណ្ឌ ៤ នៃប្រការនេះ លិខិតស្នាមឬលិខិតជូនដំណឹងត្រូវបានចាត់ទុកថាបានប្រគល់យ៉ាងត្រឹមត្រូវ ប្រសិនបើរដ្ឋបាលសារពើពន្ធបាន÷

ក- បិទផ្សាយនូវលិខិតស្នាមឬលិខិតជូនដំណឹងភ្ជាប់ទៅនឹងទ្វារនិវាសនដ្ឋាន ឬទីកន្លែងប្រកបអាជីវកម្មរបស់អ្នកជាប់ពន្ធ ឬ

ខ- ផ្សព្វផ្សាយតាមសារព័ត៌មាន ដោយតម្រូវឱ្យអ្នកជាប់ពន្ធចូលមករដ្ឋបាលសារពើពន្ធមិនឱ្យលើសពី ១៥ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទផ្សព្វផ្សាយ។

**ប្រការ ៩.- វិធានការទារបំណុលពន្ធ**

១- ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងនិងទារបំណុលពន្ធ អគ្គនាយកដ្ឋានពន្ធដារត្រូវអនុវត្តវិធានការទារបំណុលពន្ធចំពោះបុគ្គលពាក់ព័ន្ធនឹងបំណុលពន្ធដូចខាងក្រោម÷

ក- ធ្វើការទំនាក់ទំនង ឬចុះដល់ទីតាំងដើម្បីជំរុញឬផ្តល់ដំណឹងបន្ថែមឱ្យមកទូទាត់បំណុលពន្ធ

ខ- មិនអនុញ្ញាតឱ្យផ្ទេរកម្មសិទ្ធិអចលនទ្រព្យ ឬចលនទ្រព្យជាបណ្តោះអាសន្ន

គ- ដកហូតមកវិញនូវការលើកទឹកចិត្តផ្នែកសារពើពន្ធដែលបានផ្តល់ដោយរដ្ឋបាលសារពើពន្ធ

ឃ- ព្យួរទុក ឬទុកជាមោឃៈនូវលិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណផ្សេងៗដែលចេញដោយរដ្ឋបាលសារពើពន្ធ

ង- មិនអនុញ្ញាតឱ្យចុះបញ្ជីពន្ធដារ

ច- ធ្វើការផ្សព្វផ្សាយជាសាធារណៈ នៅលើគេហទំព័រអគ្គនាយកដ្ឋានពន្ធដារ នៅលើបណ្តាញសង្គម និងនៅតាមទំព័រសារព័ត៌មាននានា។

២- វិធានការទារបំណុលពន្ធ ត្រូវបានអនុវត្តភ្លាមៗបន្ទាប់ពីចេញលិខិតជូនដំណឹងទារបំណុលពន្ធ ក្នុងករណីអគ្គនាយកដ្ឋានពន្ធដាររកឃើញការប្រមូលបំណុលពន្ធអាចនឹងត្រូវមានឧបសគ្គ។

**ប្រការ ១០.- វិធានការតឹងទារបំណុលពន្ធ**

ដើម្បីបញ្ចៀសនូវចេតនាគេចវេះការទូទាត់បំណុលពន្ធ អគ្គនាយកដ្ឋានពន្ធដារត្រូវអនុវត្តវិធានការតឹងទារបំណុលពន្ធចំពោះបុគ្គលពាក់ព័ន្ធនឹងបំណុលពន្ធដូចខាងក្រោម÷

ក- ស្នើសុំទុកជាមោឃៈនូវលិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណផ្សេងៗដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច

ខ- ស្នើសុំបញ្ឈប់សកម្មភាពអាជីវកម្ម ឬផ្អាកដំណើរការសហគ្រាសជាបណ្តោះអាសន្ន

គ- ការឃាត់ទុកគណនីធនាគាររបស់សហគ្រាស ឬ/និង បុគ្គលពាក់ព័ន្ធនឹងបំណុលពន្ធ

ឃ- ឃាត់ទុកទំនិញ សន្និធិទំនិញ បញ្ឈប់ប្រតិបត្តិការនាំចេញ-នាំចូល

ង- រឹបអូសទ្រព្យសម្បត្តិរបស់សហគ្រាស ឬ/និង បុគ្គលពាក់ព័ន្ធនឹងបំណុលពន្ធ

ច- ដាក់ពាក្យបណ្តឹងទៅតុលាការ បន្ទាប់ពីមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី ៤
## ការចាត់ទុកបំណុលពន្ធមិនអាចប្រមូលបាន

**ប្រការ ១១.- ការចាត់ថ្នាក់បំណុលពន្ធ**

អគ្គនាយកដ្ឋានពន្ធដារ ត្រូវពិនិត្យ តាមដានបំណុលពន្ធ ដែលអ្នកជាប់ពន្ធជំពាក់ ដោយធ្វើការវិភាគលើអាយុកាលបំណុលពន្ធ, ស្ថានភាពអ្នកជាប់ពន្ធ, និងទឹកប្រាក់បំណុលពន្ធ និងធ្វើចំណាត់ថ្នាក់បំណុលពន្ធជា ០២ប្រភេទ ដូចខាងក្រោម÷

១- បំណុលពន្ធដែលអាចប្រមូលបានដែលជាអាទិភាពនៃការអនុវត្តវិធានការទារនិងតឹងទារបំណុលពន្ធ។

២- បំណុលពន្ធដែលមិនអាចប្រមូលបានដែលអ្នកជាប់ពន្ធពុំមានលទ្ធភាពពិតប្រាកដក្នុងការទូទាត់សង ដែលអាចចាត់ទុកបំណុលពន្ធមិនអាចប្រមូលបាន។

**ប្រការ ១២.- លក្ខណៈវិនិច្ឆ័យ**

១- បំណុលពន្ធណាមួយ អាចត្រូវបានចាត់ទុកថាជាបំណុលពន្ធមិនអាចប្រមូលបាន លុះត្រាតែបំណុលពន្ធនោះមានអាយុកាលលើសពី ១០ឆ្នាំឡើងទៅ ឬជាបំណុលពន្ធដែលមានលក្ខណៈវិនិច្ឆ័យគ្រប់គ្នាទាំងបីដូចខាងក្រោម÷

ក- បំណុលពន្ធមានអាយុកាលយ៉ាងតិចបីឆ្នាំ

ខ- អ្នកជាប់ពន្ធមានអសាធនភាព ឬគ្មានទ្រព្យសម្បត្តិសម្រាប់ទូទាត់បំណុលពន្ធ

គ- អ្នកជាប់ពន្ធមានស្ថានភាពយ៉ាងតិចមួយក្នុងចំណោមស្ថានភាពខាងក្រោម÷

គ១. ចំពោះរូបវន្តបុគ្គល ឬម្ចាស់សហគ្រាសឯកបុគ្គល ឬម្ចាស់សហគ្រាសសហកម្មសិទ្ធិ ÷

- បានទទួលមរណភាព ដែលមានលិខិតបញ្ជាក់ពីមន្ត្រីអត្រានុកូលដ្ឋាន ឬ
- មានជំងឺ ពិការភាព ជរាភាព ឬជាប់ពន្ធនាគារដែលមិនអាចធ្វើការ និងមិនអាចរកចំណូលបានគ្រប់គ្រាន់សម្រាប់ទូទាត់ចំណាយរស់នៅជាមូលដ្ឋាន ឬក្នុងករណីទទួលរងគ្រោះដោយប្រធានសក្តិ ឬ
- ក្ស័យធន ដែលត្រូវបានប្រកាសដោយសេចក្តីសម្រេចរបស់តុលាការ ឬ
- បាត់រកមិនឃើញ ដែលមានរបាយការណ៍ចុះពិនិត្យរបស់រដ្ឋបាលសារពើពន្ធ។

គ២. ចំពោះសហគ្រាសនីតិបុគ្គល÷

- ក្ស័យធន ដែលត្រូវបានប្រកាសដោយសេចក្តីសម្រេចរបស់តុលាការ ឬ
- ទទួលរងគ្រោះដោយប្រធានសក្តិ ដែលមានការបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ច ឬ
- បាត់រកមិនឃើញ ដែលមានរបាយការណ៍ចុះពិនិត្យរបស់រដ្ឋបាលសារពើពន្ធ។

២- វិធាននិងនីតិវិធីនៃការចាត់ទុកបំណុលពន្ធមិនអាចប្រមូលបាន ត្រូវកំណត់ដោយសេចក្តីណែនាំរបស់អគ្គនាយកដ្ឋានពន្ធដារ។

៣- អាយុកាលបំណុលពន្ធ ត្រូវចាប់ផ្តើមគិតចាប់ពីកាលបរិច្ឆេទដែលអ្នកជាប់ពន្ធទទួលលិខិតជូនដំណឹងទារបំណុលពន្ធ។ ឧទាហរណ៍÷ អ្នកជាប់ពន្ធទទួលលិខិតជូនដំណឹងទារបំណុលពន្ធ នៅក្នុងថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៩ មកដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០ អាយុកាលបំណុលពន្ធស្មើនឹង ១ឆ្នាំ។

**ប្រការ ១៣.- អានុភាព**

១- ការចាត់ទុកជាបំណុលពន្ធមិនអាចប្រមូលបាន មានអានុភាពធ្វើឱ្យបំណុលពន្ធរួចផុតពីការអនុវត្តប្រាក់ពន្ធបន្ថែម ការប្រាក់ និងការពិន័យផ្សេងៗដែលអាចកើតឡើង នៅក្រោយពេលចាត់ទុកជាបំណុលពន្ធមិនអាចប្រមូលបាន។

២- ការចាត់ទុកជាបំណុលពន្ធមិនអាចប្រមូលបាន ពុំមានអានុភាពលុបចោលបំណុលពន្ធរបស់អ្នកជាប់ពន្ធឡើយ។

៣- បំណុលពន្ធមិនអាចប្រមូលបាន ត្រូវកត់ត្រាក្នុងបញ្ជីមួយដោយឡែក និងត្រូវធ្វើជាកម្មវត្ថុនៃការតាមដានដោយអង្គភាពប្រមូលបំណុលពន្ធ។

៤- ការទារបំណុលពន្ធ អាចអនុវត្តបានគ្រប់ពេលវេលា នៅពេលដែលអ្នកជាប់ពន្ធមានសាធនភាព និងបំណុលពន្ធស្ថិតនៅក្នុងរយៈពេលនៃអាជ្ញាយុកាល។

៥- ម្ចាស់សហគ្រាសដែលត្រូវបានចាត់ទុកជាបំណុលពន្ធមិនអាចប្រមូលបាន ត្រូវបានកត់ត្រាចូលក្នុងបញ្ជីអវិជ្ជមានសម្រាប់ការចុះបញ្ជីពន្ធដារ។

**ប្រការ ១៤.- ការសម្រេចចាត់ទុកបំណុលពន្ធមិនអាចប្រមូលបាន**

ការសម្រេចចាត់ទុកបំណុលពន្ធ ជាបំណុលពន្ធមិនអាចប្រមូលបាន ត្រូវបានកំណត់ដូចខាងក្រោម÷

១- អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ពិនិត្យនិងសម្រេចចំពោះបំណុលពន្ធនីមួយៗ ដែលមានទឹកប្រាក់តិចជាង ឬស្មើនឹង ២ ០០០ ០០០ ០០០ (ពីរពាន់លាន) រៀល ផ្អែកតាមសំណើរបស់អង្គភាពប្រមូលបំណុលពន្ធ។

២- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យនិងសម្រេចចំពោះបំណុលពន្ធនីមួយៗ ដែលមានទឹកប្រាក់លើសពី ២ ០០០ ០០០ ០០០ (ពីរពាន់លាន) រៀល ផ្អែកតាមសំណើរបស់អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**ប្រការ ១៥.- និរាករណ៍**

ប្រកាសលេខ ៦២៣ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីវិធាននិងនីតិវិធីចាត់ទុកបំណុលពន្ធមិនអាចប្រមូលបាន និងបទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៦.- ការអនុវត្តប្រកាស**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក និងអគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់សហគ្រាសនិងស្ថាប័នពាក់ព័ន្ធនានា ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៦កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចប្រការ ១៦ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :....០.៣....អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅ
## នៃគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ

### រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិង បំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ រៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីគយ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សារពើពន្ធ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងធានាតម្លាភាព អព្យាក្រឹតភាព នីត្យានុកូលភាពហិរញ្ញវត្ថុ និងភាពជឿទុកចិត្តបាន នៃការដោះស្រាយវិវាទសារពើពន្ធ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ ដែលសរសេរជាអក្សរកាត់ថា "គ.វ.ស." ស្របតាមមាត្រា២៤ នៃច្បាប់ស្តីពីគយ និងមាត្រា១២៣ នៃច្បាប់ស្តីពីសារពើពន្ធ។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្ត ចំពោះវិវាទគយ រដ្ឋាករ និងពន្ធដារ ដែលកើតចេញពីការមិនពេញចិត្តរបស់អ្នកជាប់ពន្ធ ចំពោះសេចក្តីសម្រេច ឬវិធានការចុងក្រោយ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គ-នាយកដ្ឋានពន្ធដារ។

## ជំពូកទី២

## សមាសភាព និងភារកិច្ច

**មាត្រា៤.-**

គ.វ.ស. មានសមាសភាព ដូចតទៅ÷

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ០១ រូប | អនុប្រធាន |
| ៣-តំណាងក្រុមប្រឹក្សាជាតិគណនេយ្យ ០១ រូប | សមាជិក |
| ៤-អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ៥-អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ **គ.វ.ស.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៥.-**

**គ.វ.ស.** មានភារកិច្ច ដូចតទៅ÷

- ពិនិត្យ ដោះស្រាយ និងសម្រេច លើបណ្តឹងតវ៉ារបស់អ្នកជាប់ពន្ធ ដែលមិនពេញចិត្ត ចំពោះសេចក្តីសម្រេច ឬវិធានការចុងក្រោយ របស់អគ្គនាយកដ្ឋានពន្ធដារ ពាក់ព័ន្ធវិវាទពន្ធដារ ដែលបង្កើតជាកាតព្វកិច្ចចំពោះសាមីអ្នកប្តឹងតវ៉ាផ្ទាល់

- ពិនិត្យ ដោះស្រាយ និងសម្រេច លើបណ្តឹងតវ៉ារបស់អ្នកជាប់ពន្ធ ដែលមិនពេញចិត្ត ចំពោះសេចក្តីសម្រេច ឬ វិធានការចុងក្រោយ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ពាក់ព័ន្ធវិវាទគយនិងរដ្ឋាករ ដែលបង្កើតជាកាតព្វកិច្ចចំពោះសាមីអ្នកប្តឹងតវ៉ាផ្ទាល់
- ពិនិត្យ ដោះស្រាយ និងសម្រេច លើសេចក្តីសម្រេចឬវិធានការពាក់ព័ន្ធវិវាទសារពើពន្ធចុងក្រោយផ្សេងទៀត ដែលបង្កើតជាកាតព្វកិច្ចចំពោះសាមីអ្នកប្តឹងតវ៉ាផ្ទាល់។

## ជំពូកទី៣
## កិច្ចដំណើរការ

**មាត្រា៦.-**

សមាសភាព **គ.ទ.ស.** ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានត្រូវកោះអញ្ជើញ និងដឹកនាំការប្រជុំ **គ.ទ.ស.** តាមការប្រគល់សិទ្ធិរបស់ប្រធាន។

**មាត្រា៧.-**

**គ.ទ.ស.** មានសិទ្ធិអញ្ជើញមន្ត្រីជំនាញពាក់ព័ន្ធ នៃក្រសួង ស្ថាប័ន សវនករ តំណាងវិស័យឯកជនពាក់ព័ន្ធ ដើម្បីបំភ្លឺ ឬផ្តល់យោបល់ តាមការចាំបាច់។

អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានភារកិច្ចបំភ្លឺលើពាក្យបណ្តឹងតវ៉ារបស់អ្នកជាប់ពន្ធ តាមការអញ្ជើញរបស់ **គ.ទ.ស.**។

**មាត្រា៨.-**

**គ.ទ.ស.** មានលេខាធិការដ្ឋានមួយ ជាសេនាធិការ ក្នុងការបំពេញមុខងាររបស់ខ្លួន។

លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាលេខាធិការដ្ឋាន **គ.ទ.ស.** ដោយមានភារកិច្ច ដូចខាងក្រោម÷

- សម្របសម្រួលការងាររដ្ឋបាល និងធានាកិច្ចដំណើរការរបស់ **គ.ទ.ស.**
- ទទួល ចុះបញ្ជី និងគ្រប់គ្រងពាក្យបណ្តឹងតវ៉ារបស់អ្នកជាប់ពន្ធ
- ពិនិត្យនិងសិក្សាស្រាវជ្រាវ លើពាក្យបណ្តឹងតវ៉ា ឯកសារ ព័ត៌មាន និងភ័ស្តុតាងពាក់ព័ន្ធ
- តាមការអញ្ជើញរបស់ **គ.ទ.ស.** ធ្វើការជាមួយមន្ត្រីជំនាញពាក់ព័ន្ធ នៃក្រសួង ស្ថាប័ន សវនករ តំណាងវិស័យឯកជនពាក់ព័ន្ធ និងអ្នកប្តឹងតវ៉ា ដើម្បីទទួលបានការបំភ្លឺ ឬការផ្តល់ភ័ស្តុតាងបន្ថែម សម្រាប់ជាមូលដ្ឋាននៃការរៀបចំរបាយការណ៍ជូន **គ.ទ.ស.**
- លើកសំណើដោះស្រាយបណ្តឹងតវ៉ា ជូនប្រធាន **គ.ទ.ស.** ពិនិត្យ និងសម្រេច។

**មាត្រា៩.-**

**គ.ទ.ស.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបំពេញការងាររបស់ខ្លួន។

## ជំពូកទី៤
## នីតិវិធីដោះស្រាយបណ្តឹងតវ៉ា

**មាត្រា១០.-**

អ្នកជាប់ពន្ធដែលមិនពេញចិត្តនឹងសេចក្តីសម្រេច ឬវិធានការ ដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ មានសិទ្ធិដាក់ពាក្យបណ្តឹង ទៅអគ្គនាយកដ្ឋានពន្ធដារ ក្នុងរយៈពេល ៣០ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទ ដែលអ្នកជាប់ពន្ធបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេច ឬវិធានការ របស់អគ្គនាយកដ្ឋានពន្ធដារ។

អ្នកជាប់ពន្ធដែលមិនពេញចិត្តនឹងសេចក្តីសម្រេច ឬវិធានការ ដែលចេញដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានសិទ្ធិដាក់ពាក្យបណ្តឹង ទៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងរយៈពេល ៣០ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទ ដែលអ្នកជាប់ពន្ធបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេច ឬវិធានការ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

**មាត្រា១១.-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឬអគ្គនាយកដ្ឋានពន្ធដារ ត្រូវពិនិត្យ ដោះស្រាយ សម្រេច ឬមានវិធានការឆ្លើយតប លើពាក្យបណ្តឹងរបស់អ្នកជាប់ពន្ធ ក្នុងរយៈពេលមិនលើសពី ៦០ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទ នៃការទទួលពាក្យបណ្តឹង។

វិធាននិងនីតិវិធីនៃការដោះស្រាយវិវាទគយនិងរដ្ឋាករ នៅកម្រិតអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ព្រមទាំងវិធាននិងនីតិវិធីនៃការដោះស្រាយវិវាទពន្ធដារ នៅកម្រិតអគ្គនាយកដ្ឋានពន្ធដារ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១២.-**

អ្នកជាប់ពន្ធដែលមិនពេញចិត្ត ចំពោះសេចក្តីសម្រេច ឬវិធានការចុងក្រោយរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឬអគ្គនាយកដ្ឋានពន្ធដារ មានសិទ្ធិប្តឹងតវ៉ាមក **គ.ទ.ស.** ក្នុងរយៈពេល ៣០ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលលិខិតជូនដំណឹងស្តីពីសេចក្តីសម្រេចដោះស្រាយបណ្តឹងតវ៉ា ឬវិធានការចុងក្រោយរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឬអគ្គនាយកដ្ឋានពន្ធដារ ដោយចម្លងជូនសាមីអគ្គនាយកដ្ឋាន។

**មាត្រា១៣.-**

អ្នកជាប់ពន្ធ ត្រូវដាក់ពាក្យបណ្តឹងតវ៉ាជាលាយលក្ខណ៍អក្សរ នៅលេខាធិការដ្ឋាន **គ.ទ.ស.**។

ពាក្យបណ្តឹងតវ៉ា ត្រូវមានព័ត៌មាន កម្មវត្ថុ និងមូលហេតុនៃបណ្តឹង ជាអាទិ៍ ដូចខាងក្រោម÷

- ឈ្មោះ អាសយដ្ឋាន និងលេខអត្តសញ្ញាណកម្មសារពើពន្ធ នៃអ្នកជាប់ពន្ធដែលធ្វើការតវ៉ា
- ព័ត៌មានលម្អិតនៃសេចក្តីសម្រេច ឬវិធានការ ដែលជាកម្មវត្ថុនៃការតវ៉ា
- ដើមហេតុ ឬអំពើដែលជាកម្មវត្ថុនៃការតវ៉ា
- ហេតុផល ឬមូលដ្ឋានគតិយុត្តនៃការតវ៉ា
- កាលបរិច្ឆេទ និងហត្ថលេខារបស់អ្នកជាប់ពន្ធ ឬអ្នកតំណាងរបស់អ្នកជាប់ពន្ធ
- ឯកសារ ព័ត៌មាន លិខិតយុត្តិការ និងភស្តុតាងចាំបាច់ដែលជាមូលដ្ឋាន នៃការតវ៉ា

- ឯកសារ ព័ត៌មាន លិខិតយុត្តិការ និងភ័ស្តុតាងផ្សេងទៀត ពាក់ព័ន្ធនឹងការតវ៉ា តាមការកំណត់របស់ **គ.ទ.ស.**។

គំរូនៃពាក្យបណ្ដឹងតវ៉ា ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៤.-**

ក្នុងករណីពាក្យបណ្ដឹងតវ៉ាពុំបំពេញតាមលក្ខខណ្ឌកំណត់ក្នុងមាត្រា១៣ នៃអនុក្រឹត្យនេះ លេខាធិការដ្ឋាន **គ.ទ.ស.** ត្រូវស្នើសុំឱ្យអ្នកប្ដឹងតវ៉ា បំពេញចំណុចដែលខ្វះខាត។

**គ.ទ.ស.** អាចចេញសេចក្ដីសម្រេចបដិសេធពាក្យបណ្ដឹងតវ៉ា ក្នុងករណីលក្ខខណ្ឌនៃការដាក់ពាក្យបណ្ដឹងតវ៉ាពុំត្រូវបានបំពេញគ្រប់គ្រាន់ដោយអ្នកប្ដឹងតវ៉ា។

**មាត្រា១៥.-**

បន្ទាប់ពីទទួលបានពាក្យបណ្ដឹងតវ៉ា លេខាធិការដ្ឋាន **គ.ទ.ស.** ពិនិត្យ ស្រាវជ្រាវ និងរៀបចំរបាយការណ៍ស្ដីពីបណ្ដឹងតវ៉ា ជូន **គ.ទ.ស.**។

**មាត្រា១៦.-**

ការដោះស្រាយវិវាទសារពើពន្ធ អាចឆ្លងកាត់ការសម្រុះសម្រួលជាមុន ទៅតាមកម្រិត ដូចខាងក្រោម÷

- ក្នុងកម្រិតអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឬអគ្គនាយកដ្ឋានពន្ធដារ ការសម្រុះសម្រួលត្រូវសម្រេចដោយអគ្គនាយកនៃសាមីអគ្គនាយកដ្ឋាននីមួយៗ។
- ក្នុងកម្រិត **គ.ទ.ស.** ការសម្រុះសម្រួលត្រូវសម្រេចដោយប្រធាន **គ.ទ.ស.**។

ការសម្រុះសម្រួល ត្រូវធ្វើឡើងក្នុងរយៈពេលមិនលើសពី ៣០ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទ នៃការទទួលពាក្យបណ្ដឹង ឬក្នុងរយៈពេលសមស្រប អាស្រ័យលើទំហំនិងប្រភេទរឿងនីមួយៗ។

**មាត្រា១៧.-**

ក្នុងការដោះស្រាយវិវាទ **គ.ទ.ស.** ពិនិត្យទាំងលើអង្គហេតុ និងអង្គច្បាប់។

ក្នុងករណីចាំបាច់ ប្រធាន **គ.ទ.ស.** អាចសម្រេចឱ្យមានការស្រាវជ្រាវបន្ថែមឬអធិការកិច្ចលើពាក្យបណ្ដឹងតវ៉ា ដើម្បីបញ្ជាក់ ឬប្រមូលព័ត៌មាន ឬភ័ស្តុតាងបន្ថែមពាក់ព័ន្ធអង្គហេតុ។

**មាត្រា១៨.-**

**គ.ទ.ស.** ត្រូវពិនិត្យនិងសម្រេចដោះស្រាយបណ្ដឹងតវ៉ា ក្នុងរយៈពេលមិនលើសពី ៦០ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទ នៃការទទួលពាក្យបណ្ដឹង ឬក្នុងរយៈពេលសមស្រប អាស្រ័យលើទំហំនិងប្រភេទរឿងនីមួយៗ។

**មាត្រា១៩.-**

ក្នុងករណីមិនពេញចិត្តនឹងសេចក្ដីសម្រេចរបស់ **គ.ទ.ស.** អ្នកជាប់ពន្ធអាចដាក់ពាក្យបណ្ដឹងតវ៉ា ទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល ៣០ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទ នៃការទទួលលិខិតជូនដំណឹងស្ដីពីសេចក្ដីសម្រេចរបស់ **គ.ទ.ស.** ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

បណ្ដឹងរបស់អ្នកជាប់ពន្ធ ទៅតុលាការ ពុំមានអានុភាពផ្អាកការអនុវត្តសេចក្ដីសម្រេចរបស់ **គ.ទ.ស.** ឡើយ។

**មាត្រា២០.-**

**គ.ទ.ស.** ត្រូវចាត់តំណាងរបស់ខ្លួន នៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការ ក្រោមការដឹកនាំនិងសម្របសម្រួលរបស់ក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ជំពូកទី៥**

**អវសានប្បញ្ញត្តិ**

**មាត្រា២១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែ មករា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ